ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សៀវភៅណែនាំស្តីពី

# ការងារដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅថ្មី ដោយមិនស្ម័គ្រចិត្តសម្រាប់គម្រោងអភិវឌ្ឍន៍ឯកជន

## នៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

ក្រសួងបរិស្ថាន
ឆ្នាំ ២០២០

American Friends Service Committee

© **ក្រសួងបរិស្ថាន** និង **គណៈកម្មាធិការបម្រើក្វេគ័រអាមេរិកកាំង** (AFSC)

ឯកសារនេះត្រូវបានបោះពុម្ពដោយនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (វ.ហ.ប្ថ) នៃក្រសួងបរិស្ថាន ដោយមានការគាំទ្របច្ចេកទេស និងមូលនិធិពីគណៈកម្មាធិការបម្រើក្វេគ័រអាមេរិកកាំង (AFSC)។ របាយការណ៍នេះត្រូវបានរក្សាសិទ្ធិគ្រប់យ៉ាង។ បុគ្គល ទីភ្នាក់ងារ និងស្ថាប័ននានាដែលមានបំណងក្នុងការបោះពុម្ពផ្សាយឡើងវិញ ត្រូវទាក់ទងជាមួយក្រសួងបរិស្ថាន និងគណៈកម្មាធិការបម្រើក្វេគ័រអាមេរិកកាំង (AFSC) តាមអាស័យដ្ឋានដូចខាងក្រោម៖

**ក្រសួងបរិស្ថាន**
អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ប្រទេសកម្ពុជា

**គណៈកម្មាធិការបម្រើក្វេគ័រអាមេរិកកាំង**
ការិយាល័យប្រចាំតំបន់អាស៊ី
ផ្ទះលេខ #៧៨A ផ្លូវលេខ៥០៤ សង្កាត់ផ្សារដើមថ្កូវ
ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ៖ ៨៥៥ (0) ៧៨ ៦៣៨ ២៣៦
អ៊ីម៉ែល៖ cambodia@afsc.org

# មាតិកា


**បុព្វកថា** ........ v

**អារម្ភកថា** ........ vi

**គោលបំណង និងផ្នែកសំខាន់ៗនៃសៀវភៅណែនាំ** ........ viii

**សារៈសំខាន់នៃសៀវភៅណែនាំ** ........ ix

**ផ្នែកទី១៖ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម** ........ 2

១.១ សេចក្តីផ្តើម ........ 2

១.២ ក្របខ័ណ្ឌគតិយុត្តគោលដែលពាក់ព័ន្ធកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ........ 3

១.៣ ដំណើរការពិនិត្យ និងឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ........ 4

១.៤ ការចូលរួមពីសាធារណជននៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ........ 8

**ផ្នែកទី២៖ ស្ថានភាពនៃការអភិវឌ្ឍ និងហេតុប៉ះពាល់សំខាន់ៗ** ........ 13

២.១ ស្ថានភាពនៃការអភិវឌ្ឍ ........ 13

២.២ ស្ថានភាពហេតុប៉ះពាល់បរិស្ថាន-សង្គម ........ 17

២.៣ តំបន់ដែលងាយរងគ្រោះ ........ 18

២.៤ ក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះពីគម្រោងវិនិយោគ ........ 25

**ផ្នែកទី៣៖ បញ្ហាប្រឈម និងនីតិវិធីក្នុងការដោះស្រាយលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត** ........ 30

៣.១ សេចក្តីផ្តើម ........ 30

៣.២ ក្របខ័ណ្ឌគតិយុត្តដែលពាក់ព័ន្ធការងារគ្រប់គ្រង និងដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត ........ 31

៣.៣ គោលការណ៍អន្តរជាតិស្តីអំពីការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត ........ 34

៣.៣.១ ធនាគារអភិវឌ្ឍន៍អាស៊ី ( Asian Development Bank ) ........ 34

៣.៣.២ ធនាគារពិភពលោក ( World Bank ) ........ 37

៣.៣.៣ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ( International Financial Corporation ) ........ 39

៣.៤ ការងារដោះស្រាយទំនាស់ដីធ្លី និងអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជា ........ 42

៣.៥ បទពិសោធន៍នៃវិធីសាស្ត្រដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងវិនិយោគឯកជន ........ 44

៣.៦ ឯកសារគោលសម្រាប់ម្ចាស់គម្រោងក្នុងការងារដោះស្រាយផលប៉ះពាល់ ........ 48

៣.៧ នីតិវិធីរៀបចំរបាយការណ៍ផលប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋ ........ 48

៣.៨ ជម្រើសសំណង ........ 50

៣.៩ភាគីពាក់ព័ន្ធមានសមត្ថកិច្ចក្នុងការអនុវត្ត តាមដាន និងពិនិត្យការងារដោះស្រាយផលប៉ះពាល់ ........ 52

៣.១០ យន្តការដោះស្រាយបណ្តឹងតវ៉ា ........ 54

៣.១១ បញ្ហាមួយចំនួនសម្រាប់ការដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ........ 57

**ផ្នែកទី៤៖ អនុសាសន៍សម្រាប់បញ្ចូលព័ត៌មានបន្ថែមអំពីយន្តការដោះស្រាយ ការតាំងលំនៅដ្ឋានដោយស្ម័គ្រចិត្ត** ........ 61

**សន្ទានុក្រមពាក្យគន្លឹះ** ........ 65

**បញ្ជីតារាង**

តារាងទី១៖ តារាងសង្ខេបនូវដំណើរការពិនិត្យ និងឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ........ ៥

តារាងទី២៖ តារាងស្ថិតិប្រជាពលរដ្ឋសរុបក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៩ ........ ១៨

តារាងទី៣៖ ស្ថិតិទិន្នន័យធនធានគម្របព្រៃឈើឆ្នាំ២០១៦ (ព្រៃឈើជាតិ) ........ ២០

តារាងទី៤៖ ទិន្នន័យធនធានគម្របព្រៃឈើជាតិតាមបណ្តាខេត្តឆ្នាំ២០១៦ ........ ២២

តារាងទី៥៖ ខេត្តនិងក្រុងដែលប្រឈមមុខនឹងទឹកជំនន់ ........ ២៤

តារាងទី៦៖ សន្ទស្សន៍សម្រាប់ការវាយតម្លៃភាពងាយរងគ្រោះ ........ ២៤

តារាងទី៧៖ ប្រភេទ និងតំបន់នៃជនជាតិភាគតិចរស់នៅ ........ ២៧

**បញ្ជីផែនទី**

ផែនទីទី១៖ ចំនួនប្រជាជនសរុបតាមរាជធានីខេត្ត ឆ្នាំ២០១៩ ........ ២០

ផែនទីទី២៖ ការបែងចែករបាយភាគរយប្រជាជន ឆ្នាំ២០១៩ ........ ២១

**បញ្ជីដ្យាក្រាម**

ដ្យាក្រាមទី១៖ កិច្ចដំណើរការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ........ ៤

ដ្យាក្រាមទី២៖ ដំណាក់កាលនៃការចូលរួមពីសាធារណជននៅក្នុងកិច្ចការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ........ ៨

ដ្យាក្រាមទី៣៖ រូបតំនួសបង្ហាញពីហេតុប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តពីវិស័យអភិវឌ្ឍន៍នានា ........ ១៥

ដ្យាក្រាមទី ៤៖ រូបតំនួសបង្ហាញផលប៉ះពាល់អវិជ្ជមានពីវិស័យអភិវឌ្ឍន៍ជាតិសំខាន់ៗ ........ ១៧

ដ្យាក្រាមទី ៥៖ ឥទ្ធិពលនៃគម្រោងអភិវឌ្ឍន៍ឯកជនទៅលើតំបន់ និងក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះ ........ ២៨

ដ្យាក្រាមទី ៦៖ យន្តការដោះស្រាយទំនាស់ដីធ្លី និងអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជា ........ ៤៤

ដ្យាក្រាមទី ៧៖ លំហូរការងារដោះស្រាយផលប៉ះពាល់សម្រាប់វិស័យអភិវឌ្ឍន៍ឯកជន ........ ៤៧

ដ្យាក្រាមទី ៨៖ ជម្រើសសំណង ........ ៥១

ដ្យាក្រាមទី ៩៖ គំរូអនុវត្តរូបមន្តស្បែកខ្លា ........ ៥២

ដ្យាក្រាមទី ១០៖ ភាគីពាក់ព័ន្ធសំខាន់ៗ ........ ៥៣

ដ្យាក្រាមទី ១១៖ នីតិវិធីសង្ខេបក្នុងការដោះស្រាយបណ្តឹងតវ៉ា ........ ៥៧

**បញ្ជីក្រាហ្វិក**

ក្រាហ្វិកទី១៖ អានុភាពដំឡើងតាមប្រភេទពីឆ្នាំ២០១២-២០១៧ ........ ១៥

ក្រាហ្វិកទី២៖ ការផលិតថាមពលតាមប្រភេទ នៅឆ្នាំ២០១៧ ........ ១៥

ក្រាហ្វិកទី៣៖ ព័ត៌មានអំពីហានិភ័យនិងគ្រោះមហន្តរាយធម្មជាតិសម្រាប់ប្រទេសកម្ពុជា ........ ២៧

## បញ្ជីរូបភាព


រូបភាពទី១៖ សកម្មភាពចុះប្រមូលព័ត៌មាន ទិន្នន័យនិងពិភាក្សាជាមួយភាគីពាក់ព័ន្ធនៅក្នុងតំបន់មូលដ្ឋាន .......... ៧
រូបភាពទី២៖ សកម្មភាពចុះពិនិត្យទីតាំង និងកិច្ចប្រជុំផ្តល់មតិយោបល់លើរបាយការណ៍ .................................. ៨
រូបភាពទី៣៖ សកម្មភាពពិគ្រោះយោបល់ជាសាធារណៈនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ........................................................................................................................................ ១១
រូបភាពទី៤៖ សកម្មភាពជួបពិភាក្សាជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់អំពីសំណង និងផែនការរុះរើលំនៅដ្ឋាន... ........................................................................................................................................ ៥៨
រូបភាពទី៥៖ សកម្មភាពជួបពិភាក្សាជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់អំពីសំណងនិងផែនរុះរើលំនៅដ្ឋាន ...... ៦២

## បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | Asian Development Bank (ធនាគារអភិវឌ្ឍន៍អាស៊ី) |
| AFSC | American Friends Service Committee (គណៈកម្មាធិការបម្រើក្វេគ័រអាមេរិកកាំង) |
| CEDM&HA | Center for Excellence in Disaster Management and Humance Assistance (មជ្ឈមណ្ឌលសម្រាប់ភាពល្អឥតខ្ចោះនៅក្នុងការគ្រប់គ្រងមហន្តរាយ និងជំនួយមនុស្ស) |
| DMS | Detailed Measurement Survey (ការអង្កេតវាស់វែងលម្អិត) |
| GDR/MEF | General Directorate of Resettlment/Ministry of Economy and Finance (អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) |
| IFC | International Financial Corporation (សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ) |
| IOL | Inventory of Loss (សារពើភ័ណ្ឌទ្រព្យសម្បត្តិដែលត្រូវបាត់បង់) |
| IWGIA | International Work Group for Indigenous Affairs (ក្រុមការងារអន្តរជាតិសម្រាប់កិច្ចការជនជាតិដើមភាគតិច) |
| LRP | Livelihood Restoration Plan (ផែនការស្តារជីវភាពឡើងវិញ) |
| MoP | Ministry of Planning (ក្រសួងផែនការ) |
| PS | Performance Standard (បទដ្ឋានស្តង់ដារអនុវត្តន៍) |
| RAP | Resettlement Action Plan (ផែនការដោះស្រាយផលប៉ះពាល់) |
| RCS | Replacement Cost Study (ការសិក្សាថ្លៃជំនួស) |
| SPS | Safeguard Policy Statement (សេចក្តីថ្លែងគោលនយោបាយការពារ) |
| WB | World Bank (ធនាគារពិភពលោក) |

# បុព្វកថា

ការងារដោះស្រាយផលប៉ះពាល់ជាពិសេសទៅលើការតាំងទីលំនៅថ្មានដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋានមិនមែនជាបញ្ហា ឬការងារថ្មីនោះទេ។ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានខិតខំធ្វើការយ៉ាងសកម្មក្នុងការកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានពីគម្រោងអភិវឌ្ឍធំនានា ដែលជាគម្រោងសាធារណៈរបស់រដ្ឋ។ បទប្បញ្ញត្តិ ស្ថាប័នទទួលខុសត្រូវ និងយន្តការដោះស្រាយជាច្រើនត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលដល់ការងារដោះស្រាយ និងជួយរួមចំណែកកាត់បន្ថយនូវផលប៉ះពាល់ធ្ងន់ធ្ងរនានាទៅលើការតាំងទីលំនៅថ្មាន និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

បទពិសោធន៍អភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជាបានបង្ហាញថាសម្រាប់គម្រោងអភិវឌ្ឍន៍ជាច្រើន ការផ្លាស់ប្តូរទីតាំងរបស់សហគមន៍ និងការទាមទារដី និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋដែលរងគ្រោះបានកើតឡើងជារឿយៗ។ ដោយឆ្លើយតបទៅនឹងនិន្នាការនេះ រាជរដ្ឋាភិបាលកម្ពុជានៅក្នុងឆ្នាំ២០០៧ បានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីដោះស្រាយផលប៉ះពាល់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលខុសត្រូវលើបញ្ហាការតាំងទីលំនៅឡើងវិញរបស់គម្រោងអភិវឌ្ឍន៍សាធារណៈ ឬគម្រោងចម្រុះរដ្ឋនៅទូទាំងប្រទេស។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើតនាយកដ្ឋានដោះស្រាយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ ហើយក្រោយមកបានដំឡើងទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ ដើម្បីគាំពារដល់ការងាររបស់គណៈកម្មការអន្តរក្រសួង។ ដោយឡែក យន្តការនិងនីតិវិធីការងារក្នុងការដោះស្រាយផលប៉ះពាល់ជាមួយគម្រោងអភិវឌ្ឍន៍ ឬវិនិយោគឯកជននៅមិនទាន់មានរូបភាព យន្តការ និងប្រព័ន្ធច្បាស់លាស់ជាផ្លូវការនៅឡើយទេ។ ជាទូទៅប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ច្រើនតែពឹងពាក់អាជ្ញាធរ ឬក្រុមអង្គការមិនមែនរដ្ឋាភិបាលក្នុងការពាំនាំ និងជួយរកដំណោះស្រាយទៅតាម លទ្ធភាពដែលភាគីទាំងនោះអាចធ្វើបាន។

ដោយឡែកនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានសន្ទុះកើនឡើងគួរឱ្យចាប់អារម្មណ៍ ហើយបានទាក់ទាញនូវអ្នកវិនិយោគបរទេសជាច្រើនឱ្យចូលមកបណ្តាក់ទុនដោយផ្ទាល់។ កំណើនការវិនិយោគ ជាពិសេសការវិនិយោគគម្រោងអភិវឌ្ឍន៍ឯកជនអាចបង្កឱ្យមាននូវហានិភ័យនៃផលប៉ះពាល់ទៅលើប្រជាពលរដ្ឋនៅតាមតំបន់មូលដ្ឋានដែលគម្រោងអនុវត្តន៍។ គម្រោងវិនិយោគមួយភាគធំតម្រូវឱ្យមាននូវការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាមុនសិនមុននឹងអាចអនុវត្តន៍បាន។ ការសិក្សានេះក៏តម្រូវឱ្យមានការចងក្រងនូវហេតុប៉ះពាល់ទៅលើការតាំងទីលំនៅនិងជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋានផងដែរ។ ប៉ុន្តែកន្លងមកប្រទេសកម្ពុជាយើងមិនទាន់មាននូវបទដ្ឋានគតិយុត្ត និងយន្តការជាក់លាក់ណាមួយក្នុងការជួយដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅរបស់ប្រជាពលរដ្ឋដែលរងគ្រោះពីគម្រោងអភិវឌ្ឍន៍ឯកជននៅឡើយទេ។ ការខ្វះខាតនេះជាបញ្ហាប្រឈមមួយយ៉ាងសំខាន់ សម្រាប់ម្ចាស់គម្រោងអភិវឌ្ឍន៍ឯកជនក្នុងការរួមចំណែកដល់ការដោះស្រាយ និងកាត់បន្ថយនូវផលប៉ះពាល់ទៅលើការតាំងទីលំនៅនិងជីវភាពរបស់ប្រជាពលរដ្ឋ។

កូនសៀវភៅនេះ ត្រូវបានរៀបចំឡើងក្នុងការផ្តល់ជូនម្ចាស់គម្រោងអភិវឌ្ឍឯកជននូវព័ត៌មានជាមូលដ្ឋានអំពីបទប្បញ្ញត្តិ និងនីតិវិធីដោះស្រាយនានាដែលមាន និងធ្លាប់បានអនុវត្តន៍ជាពិសេសជាមួយគម្រោងសាធារណៈរបស់រដ្ឋដែលអាចដកស្រង់បានជាមេរៀន និងបទពិសោធន៍សម្រាប់ជាជំនួយស្មារតីក្នុងការរៀបចំការងារដោះស្រាយផលប៉ះពាល់នានាពីគម្រោងអភិវឌ្ឍន៍ឯកជននៅក្នុងប្រទេសកម្ពុជា។

# អារម្ភកថា

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាឧបករណ៍យ៉ាងសំខាន់សម្រាប់ការសម្រេចចិត្ត និងការគ្រប់គ្រងទៅលើគម្រោងអភិវឌ្ឍន៍ទាំងឡាយដែលអាចបង្កជាហេតុប៉ះពាល់ទៅលើធនធានបរិស្ថានធម្មជាតិ និងធនធានសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងបរិស្ថានបានខិតខំធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យកិច្ចការពារ និងអភិរក្សធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធសំខាន់ៗ។

ជាការពិតណាស់ ការអភិវឌ្ឍបាននាំមកនូវអត្ថប្រយោជន៍ជាច្រើនសម្រាប់សេដ្ឋកិច្ចជាតិយ៉ាងធំធេង សំដៅដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ក្រៅអំពីផលវិជ្ជមានទាំងនេះ គម្រោងអភិវឌ្ឍន៍ឯកជនធំៗមួយចំនួនក៏បានបង្កជាហេតុប៉ះពាល់ និងការប៉ះទង្គិចទៅលើធនធានធម្មជាតិ ជាពិសេសទៅលើការតាំងទីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋដែលបានរស់នៅពឹងអាស្រ័យទៅលើធនធាននានាដែលនៅជុំវិញ។ ផលប៉ះពាល់ទៅលើការតាំងទីលំនៅរបស់ប្រជាពលរដ្ឋជាផលវិបាកសង្គម និងសេដ្ឋកិច្ចយ៉ាងសំខាន់ដែលចាំបាច់ត្រូវមានការឆ្លើយតបឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់បំផុត។ ក្នុងបរិបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ការសិក្សាចងក្រងនូវហេតុប៉ះពាល់ និងស្នើឱ្យមាននូវយន្តការដើម្បីដំណោះស្រាយទៅលើការខូចខាតទ្រព្យសម្បត្តិ និងការស្តារឡើងវិញនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាចំណុចគន្លឹះសំខាន់ដែលម្ចាស់គម្រោងអភិវឌ្ឍន៍ និងក្រុមហ៊ុនទីប្រឹក្សាត្រូវរៀបចំ និងលើកឡើងបញ្ជាក់ឱ្យបានច្បាស់នូវទិន្នន័យផលប៉ះពាល់ និងផែនការយុទ្ធសាស្ត្រក្នុងការដោះស្រាយទៅលើបញ្ហានៃការតាំងទីលំនៅដ្ឋានដែលអាចបណ្តាលមកពីសកម្មភាពរបស់គម្រោង។ ក្រសួងបរិស្ថានបានប្តេជ្ញាយ៉ាងមុតមាំក្នុងការអនុវត្តនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រជាតិសម្រាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដោយខិតខំជំរុញ និងលើកទឹកចិត្តឱ្យម្ចាស់គម្រោងអភិវឌ្ឍន៍ធ្វើការសិក្សានិងវាយតម្លៃឱ្យបានជាក់ស្តែងទៅលើហេតុប៉ះពាល់បរិស្ថាន និងសង្គមដូចមានការណែនាំនៅក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (ឆ្នាំ១៩៩៦) អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ឆ្នាំ១៩៩៩) និងប្រកាសដែលពាក់ព័ន្ធមួយចំនួនទៀត។

នីតិវិធី និងបទពិសោធន៍ការងារត្រូវបានបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់អនុវត្តន៍តែគម្រោងសាធារណៈរបស់រដ្ឋ និងមិនមានវិសាលភាពទៅលើការងារដោះស្រាយសម្រាប់គម្រោងវិនិយោគឯកជនទេ។ ប៉ុន្តែនីតិវិធី និងយន្តការដោះស្រាយដែលប្រើប្រាស់ដោយស្ថាប័នរដ្ឋាភិបាលអាចត្រូវបានប្រើប្រាស់ឡើងវិញផងដែរសម្រាប់ការដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តសម្រាប់គម្រោងវិនិយោគ ឬអភិវឌ្ឍន៍ឯកជនផងដែរ គ្រាន់តែធ្វើការកែសម្រួលទៅតាមស្ថានភាពគម្រោង ភាគីពាក់ព័ន្ធ និងការសម្របសម្រួលជាក់ស្តែងដែលមាននៅតាមទីតាំង និងលក្ខណៈនៃផលប៉ះពាល់របស់គម្រោងនីមួយៗ។ ម្យ៉ាងទៀត ការអនុវត្តត្រូវតែរក្សាឱ្យបាននូវការចូលរួម

ពេញលេញរបស់ភាគីពាក់ព័ន្ធនានា និងគោលការណ៍សំណងយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋរងនូវផលប៉ះពាល់។

សៀវភៅណែនាំនេះជាឯកសារសំខាន់ណាស់ ក្នុងការផ្តល់នូវព័ត៌មានគោលអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន វិស័យអភិវឌ្ឍន៍ធំៗដែលអាចបង្កជាហេតុប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋាន នីតិវិធីក្នុងការដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានសម្រាប់គម្រោងអភិវឌ្ឍន៍ឯកជន និងអនុសាសន៍សំខាន់ៗសម្រាប់ការរៀបចំព័ត៌មាន ឬទិន្នន័យអំពីហេតុប៉ះពាល់លើការតាំងទីលំនៅដ្ឋាននៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ **សៀវភៅណែនាំនេះមិនផ្តោតលើយន្តការ និងដំណោះស្រាយសម្រាប់ការងារដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត សម្រាប់គម្រោងសាធារណៈ ឬគម្រោងចំណុះរដ្ឋនោះ។** សៀវភៅណែនាំនេះត្រូវបានបង្កើតឡើង ដើម្បីជាជំនួយដល់ម្ចាស់គម្រោងអភិវឌ្ឍន៍ឯកជនក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីធានាឱ្យមាននូវព័ត៌មាន និងទិន្នន័យគ្រប់គ្រាន់ប្រកបដោយសក្តានុពលភាព និងប្រសិទ្ធភាពខ្ពស់សម្រាប់ការងារដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋរងគ្រោះ។

ជាចុងក្រោយនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំក្រសួងបរិស្ថាន ថ្នាក់ដឹកនាំ និងមន្ត្រីនៃនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គណៈកម្មាធិការបម្រើក្វេគ័រអាមេរិកកាំង (AFSC) និងអ្នកពាក់ព័ន្ធនានាក្នុងការចូលរួមរៀបចំ និងផ្តល់មតិយោបល់កែលម្អសៀវភៅណែនាំដ៏សំខាន់នេះ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៣ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

# គោលបំណង និងផ្នែកសំខាន់ៗនៃសៀវភៅណែនាំ

គោលបំណងជាក់លាក់ដែលមាននៅក្នុងសៀវភៅនេះមានដូចខាងក្រោម៖



- *រៀបរាប់អំពីបទបញ្ញត្តិនិងដំណើរការនានាដែលមានសុពលភាពក្នុងការអនុវត្តកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងក្នុងការជួយដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍ឯកជន*
- *លើកឡើងអំពីស្ថាប័នទទួលខុសត្រូវ និងយន្តការចាំបាច់សម្រាប់ការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៏ឯកជន*
- *បង្ហាញជូននូវបទពិសោធន៍ជាក់ស្តែងដែលបានអនុវត្តន៍កន្លងមកជាមួយការដោះស្រាយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៏ឯកជននៅក្នុងប្រទេសកម្ពុជា*
- *ផ្តល់ជូននូវអនុសាសន៍សំខាន់ៗដែលគួរពិចារណាក្នុងការរៀបចំការដោះស្រាយផលប៉ះពាល់ និងសម្រាប់រៀបចំព័ត៌មានបន្ថែមនៅក្នុងរបាយការណ៍*

សៀវភៅណែនាំនេះនឹងលើកឡើងអំពី៖

- និយមន័យ និងទស្សនទានសំខាន់ៗអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងផលប៉ះពាល់ទៅលើការតាំងទីលំនៅនិងជីវភាពរបស់ប្រជាពលរដ្ឋ
- ដំណើរការសំខាន់ៗនៃកិច្ចការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម រួមទាំងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- នីតិវិធីគោលក្នុងការរៀបចំឯកសារសម្រាប់ការចងក្រងនូវទិន្នន័យ និងព័ត៌មានអំពីប្រជាពលរដ្ឋរងគ្រោះ និងទ្រព្យសម្បត្តិដែលត្រូវបាត់បង់
- វិធីសាស្ត្រនិងនីតិវិធីក្នុងការដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋាន និងជីវភាពរបស់ប្រជាពលរដ្ឋ រួមបញ្ចូលទាំងភាគីពាក់ព័ន្ធសំខាន់ៗ
- គំនិតគួរពិចារណាមួយចំនួនក្នុងការរៀបចំ និងដោះស្រាយនូវផលប៉ះពាល់លើការតាំងទីលំនៅនិងជីវភាពរបស់ប្រជាពលរដ្ឋ
- អនុសាសន៍សម្រាប់ការបញ្ចូលនូវព័ត៌មានចាំបាច់មួយចំនួនទៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងជាពិសេសសម្រាប់ម្ចាស់គម្រោងអភិវឌ្ឍន៍ឯកជន សាធារណជន និងក្រសួងបរិស្ថាន ក្នុងការស្វែងយល់បន្ថែមនូវការដោះស្រាយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៏ឯកជនទៅលើការតាំងទីលំនៅដ្ឋាន និងការស្តារជីវភាពឡើងវិញរបស់ប្រជាពលរដ្ឋដែលរងគ្រោះ។ សាធារណជនទូទៅអាចប្រើប្រាស់សៀវភៅនេះសម្រាប់ជាការសិក្សារៀនសូត្រ និងអនុវត្តន៍តាមតម្រូវការដែលពាក់ព័ន្ធ និងចាំបាច់។

# សារៈសំខាន់នៃសៀវភៅណែនាំ

ការរៀបចំសៀវភៅណែនាំនេះនឹងនាំមកនូវសារៈប្រយោជន៍យ៉ាងច្រើនដូចជា៖

- បញ្ហា និងផលប៉ះពាល់ទៅលើការតាំងទីលំនៅរបស់ប្រជាពលរដ្ឋនឹងត្រូវបានសិក្សា និងធ្វើផែនការសកម្មភាពដោះស្រាយច្បាស់លាស់ និងបានត្រៀមយន្តការឆ្លើយតបរួចរាល់ជាមុននៅក្នុងបរិបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការសម្រេចចិត្តទៅលើរបាយការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមមានសុក្រឹត្យភាព និងភាពប្រាកដនិយមច្រើនជាងមុនដើម្បីរួមចំណែកដល់ការកាត់បន្ថយនូវហេតុ និងផលប៉ះពាល់អវិជ្ជមានពីសកម្មភាពគម្រោងទៅលើការតាំងទីលំនៅ និងជីវភាពរបស់ប្រជាពលរដ្ឋ
- ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងបញ្ហានៃផលប៉ះពាល់ការតាំងទីលំនៅ និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង
- ខ្លឹមសារ បទពិសោធន៍ និងចំណេះដឹងទាំងឡាយដែលមាននៅក្នុងសៀវភៅណែនាំនេះនឹងក្លាយជាប្រភពព័ត៌មាន និងផ្តល់នូវការយល់ដឹងបន្ថែមទៀតដល់អ្នកពាក់ព័ន្ធទាំងឡាយ ក៏ដូចជាអ្នកសិក្សារៀនសូត្រ និងអ្នកស្រាវជ្រាវផ្សេងៗទៀត អំពីកិច្ចការដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តសម្រាប់គម្រោងអភិវឌ្ឍន៍ឯកជន
- ចូលរួមចំណែកដល់ការលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការចូលរួមប្រកបដោយគុណភាពនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងនៅក្នុងកិច្ចដំណើរការដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត និងការស្តារជីវភាពឡើងវិញរបស់ប្រជាពលរដ្ឋរងគ្រោះ
- ចូលរួមចំណែកជាធាតុចូលសម្រាប់ការងាររៀបចំផែនការអភិវឌ្ឍជាតិ និងផែនការអភិវឌ្ឍមូលដ្ឋានដែលនឹងនាំមកនូវការរីកចម្រើនដល់ស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ។

# ជំពូកទី១



## កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

# ផ្នែកទី១៖ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

## ១.១ សេចក្តីផ្តើម

*ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម* គឺជាការសិក្សាព្យាករនូវហេតុប៉ះពាល់នានាពីគម្រោងវិនិយោគ ឬគម្រោងអភិវឌ្ឍន៍ទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គមនៅក្នុងនិងជុំវិញតំបន់គម្រោង ព្រមទាំងលើកឡើងនូវវិធានការទប់ស្កាត់ និងកាត់បន្ថយសំដៅធានាឱ្យមាននូវហេតុប៉ះពាល់អវិជ្ជមានតិចតួច លើកកម្ពស់កិច្ចការពារបរិស្ថាន និងបង្កើនអត្ថប្រយោជន៍សម្រាប់សហគមន៍ និងប្រទេសជាតិទាំងមូល។

ច្បាប់ស្តីពីកិច្ចការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិក្នុងឆ្នាំ១៩៩៦ បានចែងអំពីតម្រូវការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់គម្រោងអភិវឌ្ឍន៍នានា។ កិច្ចដំណើរការវាយតម្លៃនេះក៏ត្រូវបានចែងលម្អិតនៅក្នុងអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងឆ្នាំ១៩៩៩ និងក្រោយមកនៅក្នុងគោលការណ៍ណែនាំទូទៅឆ្នាំ២០០៩ សម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ឥឡូវនេះក្រសួងបរិស្ថានកំពុងធ្វើសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម សេចក្តីព្រាងអនុក្រឹត្យស្តីពីការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងចុងក្រោយ គឺសេចក្តីព្រាងក្រមបរិស្ថានដែលមានបញ្ចូលអំពីការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះផងដែរ។ បន្ថែមពីលើនេះ ក្រសួងបរិស្ថានបានរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រកាសស្តីពីគំរូលក្ខខណ្ឌការងារសម្រាប់គម្រោងអភិវឌ្ឍមួយចំនួនទៀតផង[1]។ បទប្បញ្ញត្តិទាំងនេះទាមទារឱ្យម្ចាស់គម្រោងវិនិយោគឯកជន ឬសាធារណៈណាមួយស្ថិតក្រោមលក្ខណៈវិនិច្ឆ័យដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យឆ្នាំ១៩៩៩ ឱ្យរៀបចំនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង ឬពេញលេញ[2] ហើយដាក់ជូនក្រសួងបរិស្ថានត្រួតពិនិត្យផ្តល់យោបល់ និងផ្តល់លិខិតឯកភាពជាមុនសិន មុនពេលដែលគម្រោងនោះត្រូវបានអនុវត្តន៍បន្ត។ ផ្អែកទៅលើបទពិសោធន៍ជាក់ស្តែងដំណើរការសិក្សាវាយតម្លៃរបស់ក្រុមហ៊ុនទីប្រឹក្សា និងការត្រួតពិនិត្យរបាយការណ៍ និងការផ្តល់លិខិតឯកភាពរបស់ក្រសួងបរិស្ថានអាចនឹងត្រូវចំណាយពេលពី ៣ ទៅ ៤ខែ សម្រាប់ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងអាចត្រូវការពេលវេលាយូរជាងនេះប្រមាណពី ៥ ទៅ ៦ខែ ឬរហូតដល់ឆ្នាំសម្រាប់ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។ រយៈពេលនេះអាចនឹងច្រើនជាងនេះទៀត ដោយអាស្រ័យទៅលើស្ថានភាពនយោបាយ បញ្ហាបច្ចេកទេសរបស់គម្រោង និងស្ថានភាពការងាររបស់ក្រសួងបរិស្ថាន។ ដោយផ្អែកលើប្រកាសរបស់ក្រសួងបរិស្ថាន[3]ឆ្នាំ២០០៩ ដំណើរការពិនិត្យ និងផ្តល់លិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនេះ មានបង្ហាញដោយសង្ខេបតាមដ្យាក្រាមទី១ ក្នុងចំណុច ១.៣ខាងក្រោម។

[1] គិតត្រឹមឆ្នាំ២០១៨ ក្រសួងបរិស្ថានបានដាក់ឱ្យប្រើប្រាស់ប្រកាសចំនួន ៥ដែលរួមមាន៖ (១) ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គំរូលក្ខខណ្ឌការងារសម្រាប់គម្រោងអាជីវកម្មខ្សាច់សំណង់ និងដីល្បាប់ខ្សាច់ (លេខ ១១៩ ប្រ.ក.ប.ស្ត ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨) (២) ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គំរូលក្ខខណ្ឌការងារសម្រាប់គម្រោងអាជីវកម្មថ្មសម្ភារសំណង់ (លេខ ១១៨ ប្រ.ក.ប.ស្ត ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨) (៣) ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គំរូលក្ខខណ្ឌការងារសម្រាប់គម្រោងបង្កើតរោងចក្រ និងសិប្បកម្ម (លេខ ១១៦ ប្រ.ក.ប.ស្ត ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨) (៤) ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គំរូលក្ខខណ្ឌការងារសម្រាប់គម្រោងអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍ (លេខ ១២០ ប្រ.ក.ប.ស្ត ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨) និង (៥) ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គំរូលក្ខខណ្ឌការងារសម្រាប់គម្រោងអភិវឌ្ឍន៍វិស័យដំណាំកសិ-ឧស្សាហកម្ម (លេខ ០៩២ ប្រ.ក.ប.ស្ត ចុះថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០១៨)។

[2] ការកំណត់គម្រោងមួយដែលតម្រូវឱ្យមានការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន គឺផ្អែកទៅលើប្រកាសលេខ ០២១ ប្រក.ប.ស្ត ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីអំពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ របស់ក្រសួងបរិស្ថាន។

[3] ប្រកាសលេខ ៣៧៦ ប្រក.បស្ត របស់ក្រសួងបរិស្ថាន ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។

## ១.២ ក្របខ័ណ្ឌគតិយុត្តគោលដែលពាក់ព័ន្ធកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

រដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលច្បាប់នេះបានធានាឱ្យមានស្ថេរភាព សមភាព សេចក្តីថ្លៃថ្នូរ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ រដ្ឋធម្មនុញ្ញជាមូលដ្ឋានគ្រឹះនៃឯកសារគតិយុត្តផ្សេងៗ (មានដូចជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណ៍ ប្រកាស។ល។)។ មាត្រា៥៨នៃរដ្ឋធម្មនុញ្ញបានបញ្ជាក់យ៉ាងច្បាស់ថាទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀត ដែលបានកំណត់ថាជារបស់រដ្ឋ។ ការគ្រប់គ្រង ការចាត់ចែងលើទ្រព្យសម្បត្តិ នឹងត្រូវកំណត់ដោយច្បាប់។ រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល។ មាត្រា ៦១បានលើកទឹកចិត្តឱ្យរដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម ឧស្សាហកម្មចាប់តាំងពីតំបន់ដាច់ស្រយាល ដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទានជាដើម។

ដោយឡែកនិងយោងតាមបញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ហើយប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស.រកម.១២៩៦.៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦។ ច្បាប់នេះបង្កើតឡើងក្នុងគោលបំណងធានាថាធនធានទាំងអស់ដែលជាទ្រព្យសម្បត្តិរដ្ឋត្រូវបានគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងប្រកបដោយចីរភាព។ មាត្រា៦នៃច្បាប់នេះបានចែងថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុននឹងដាក់ជូនរាជរដ្ឋាភិបាលសម្រេច។ ការវាយតម្លៃនេះក៏ត្រូវបានអនុវត្តផងដែរចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការហើយដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។ ជាងនេះទៅទៀតមាត្រា៧បានសង្កត់ធ្ងន់ថា ចំពោះរាល់ពាក្យសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលរដ្ឋស្នើឡើងត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញដូចមានចែងក្នុងមាត្រា៦។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអង្គភាពមានសមត្ថកិច្ចក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីលើនេះ មាត្រា៨នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិបានលើកឡើងវិញថា ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល ត្រូវបានអភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រង ប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ។

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានអនុម័តឱ្យប្រើប្រាស់ជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជា។ អនុក្រឹត្យនេះមានគោលបំណង (១). កំណត់វាយតម្លៃហេតុប៉ះពាលបរិស្ថាន លើរាល់គម្រោង និងសកម្មភាពឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថាន ដាក់ជូនរាជរដ្ឋាភិបាលសម្រេច (២). កំណត់ប្រភេទ និងទំហំគម្រោង សកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ទាំងឯកជន ទាំងសាធារណៈ

ដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង (៣). បំផុសឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងដំណើរការអនុម័តគម្រោង។

ក្រៅអំពីបទបញ្ញត្តិសំខាន់ៗខាងលើ ការគ្រប់គ្រងការបំពុលបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយទំនួលខុសត្រូវខ្ពស់ និងឱ្យប្រកបដោយចីរភាព ក្រសួងបរិស្ថាន និងបណ្តាក្រសួងពាក់ព័ន្ធមួយចំនួនទៀតបានជំរុញឱ្យមានច្បាប់ និងប្បញ្ញត្តិជាច្រើនទៀត (ដោយរៀបរាប់មួយចំនួនតូច) ដូចជា ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (ឆ្នាំ២០០៨) ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៤) ច្បាប់ភូមិបាល (ឆ្នាំ២០០១) ច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ២០០២)ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៧) ច្បាប់ស្តីពីការងារ (ឆ្នាំ១៩៩៧) អនុក្រឹត្យស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម (ឆ្នាំ២០១៦) អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (ឆ្នាំ១៩៩៩) អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក (ឆ្នាំ១៩៩៩) និងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង (ឆ្នាំ២០០០) ជាដើមដែលម្ចាស់គម្រោងអភិវឌ្ឍន៍ត្រូវមានកាតព្វកិច្ចបំពេញឱ្យបានម៉ត់ចត់ និងទៀងទាត់បំផុត។

## ១.៣ ដំណើរការពិនិត្យ និងឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

តាមប្រកាសរបស់ក្រសួងបរិស្ថាន ម្ចាស់គម្រោងត្រូវអនុវត្តន៍តាមជំហាន និងដំណាក់កាលនីមួយៗដូចដែលមានបង្ហាញតាមដ្យាក្រាមទី១ ខាងក្រោម។ ពេលវេលាអាចនឹងត្រូវការច្រើនជាងនេះ ដោយអាស្រ័យទៅលើ ១) ភាពស្មុគស្មាញនៃបញ្ហាបរិស្ថាននិងសង្គមដែលគម្រោងអាចបង្កឡើង ២) ចំនួនរបាយការណ៍ដែលដាក់ជូនក្រសួងបរិស្ថានពីម្ចាស់គម្រោងផ្សេងៗទៀត និង ៣) ផែនការសកម្មភាពមមាញឹករបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងថ្នាក់ដឹកនាំរបស់ក្រសួងបរិស្ថាន ក្នុងការដឹកនាំកិច្ចប្រជុំអន្តរក្រសួងពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

ជំហានទាំងនេះជាបទពិសោធន៍ជាក់ស្តែង ដែលកើតមានក្នុងការអនុវត្តនូវកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដោយរួមមានទាំងការរៀបចំរបាយការណ៍ ការពិនិត្យ និងការផ្តល់លិខិតឯកភាពលើរបាយការណ៍ជាដើម។ ម្ចាស់គម្រោងគួរពិនិត្យនូវដំណាក់កាលទាំងនេះដោយម៉ត់ចត់ជាមួយក្រុមហ៊ុនទីប្រឹក្សាឯករាជ្យក្នុងការធានាបាននូវកិច្ចដំណើរការមួយដែលសមស្រប និងអាចគ្រប់គ្រងបាន។ ដំណើរការជាបទពិសោធន៍ត្រូវចាប់ផ្តើមពីពេលដែល ❶ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាឯករាជ្យត្រូវរៀបចំសំណើសុំអនុញ្ញាត្តរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោងអភិវឌ្ឍន៍របស់ខ្លួនមកក្រសួងបរិស្ថាន។ ❷ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងធ្វើចំណាត់ថ្នាក់ថាតើគម្រោងដែលបានស្នើឡើងចាំបាច់ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬពេញលេញ ឬគ្រាន់តែរៀបចំកិច្ចសន្យាការពារបរិស្ថាន។ ប្រសិនបើគម្រោងតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង ឬពេញលេញ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវរៀបចំលក្ខខណ្ឌការងារសម្រាប់ការសិក្សាវាយតម្លៃហេតុប៉ះពាល់របស់ខ្លួន ហើយត្រូវធ្វើបទបង្ហាញជូននាយកដ្ឋាននៅពេលណាមួយ និងត្រូវរង់ចាំរហូតដល់ក្រសួងបរិស្ថានចេញលិខិតអនុញ្ញាត្តសម្រាប់ការសិក្សាវាយតម្លៃ។ ប្រសិនបើនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានតម្រូវឱ្យមានតែកិច្ចសន្យា នោះនាយកដ្ឋាននឹងរៀបចំកិច្ចសន្យាការពារបរិស្ថានដើម្បីឱ្យម្ចាស់គម្រោងឯកភាព និងចាប់ផ្តើមអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថានតែម្តង។

ដ្យាក្រាមទី១៖ កិច្ចដំណើរការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម




ដំណាក់កាលបន្តគឺ ③ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវរៀបចំផែនការសកម្មភាព និងវិធីសាស្ត្រក្នុងការសិក្សា ប្រមូលព័ត៌មាន និងពិគ្រោះយោបល់ដើម្បីរៀបចំរបាយការណ៍មុនពេលដាក់ជូនក្រសួងបរិស្ថានសម្រាប់ការពិនិត្យ និងផ្តល់មតិយោបល់បច្ចេកទេសកែលម្អ។ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវដាក់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬពេញលេញក្តីជូនក្រសួងបរិស្ថាន (នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន) សម្រាប់ការពិនិត្យ និងកែលម្អបន្ត។ ④ នៅពេលទទួលបានរបាយការណ៍ជាផ្លូវការ ក្រសួងបរិស្ថានចាត់តាំងក្រុមការងារក្នុងការដឹកនាំនិងចុះពិនិត្យលើទីតាំងគម្រោងជាក់ស្តែង។ ក្រុមការងារនេះចុះត្រួតពិនិត្យដោយផ្ទាល់នៅក្នុងទីតាំងគម្រោង ដើម្បីសិក្សាបញ្ជាក់ទៅលើរបាយការណ៍ដែលម្ចាស់គម្រោងនិងក្រុមហ៊ុនទីប្រឹក្សាបានដាក់ជូន។ ⑤ បន្ទាប់មក ក្រសួងបរិស្ថានដែលមាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានរៀបចំកិច្ចប្រជុំមន្ត្រីបច្ចេកទេសនៃនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានដើម្បីពិនិត្យ និងផ្តល់មតិយោបល់សម្រាប់ការកែលម្អរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ របាយការណ៍ត្រូវកែសម្រួលទៅតាមមតិយោបល់ ហើយដាក់ជូនក្រសួងបរិស្ថានជាថ្មីម្តងទៀត។ ក្នុងករណីដែលរបាយការណ៍មានភាពគ្រប់ជ្រុងជ្រោយ និងលក្ខណៈសម្បត្តិគ្រប់

គ្រាន់ហើយ ៦ ក្រសួងបរិស្ថានរៀបចំកិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យផ្តល់យោបល់ និងអនុសាសន៍លើរបាយការណ៍។ របាយការណ៍ត្រូវកែសម្រួលទៅតាមមតិយោបល់ ហើយដាក់ជូនក្រសួងបរិស្ថានជាថ្មីម្តងទៀតមុនពេលដែលកិច្ចសន្យាការពារបរិស្ថានត្រូវបានរៀបចំ និងចុះហត្ថលេខា។ កិច្ចប្រជុំអន្តរក្រសួងអាចត្រូវរៀបចំឡើងម្តងហើយម្តងទៀតចំពោះគម្រោងទាំងឡាយណាដែលអាចបង្កជាហេតុប៉ះពាល់បរិស្ថាន និងសង្គមស្មុគស្មាញ ឬស្ថិតនៅក្នុងតំបន់ការពារ ឬតំបន់ដែលមានគម្រោងអភិវឌ្ឍជាតិនិងអន្តរជាតិ ឬតំបន់ទីប្រជុំជនដែលទាមទារឱ្យមានការពិភាក្សា និងពិនិត្យល្អិតល្អន់មុននឹងសម្រេចថាតើគួរផ្តល់លិខិតឯកភាពលើរបាយការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឬតម្រូវឱ្យកែសម្រួលរបាយការណ៍ឡើងវិញ។ លទ្ធផលពីកិច្ចប្រជុំអន្តរក្រសួងអាចឯកភាពលើរបាយការណ៍តែម្តង ឬតម្រូវឱ្យមានការកែសម្រួលលើរបាយការណ៍ដែលម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវធ្វើការកែសម្រួលរបាយការណ៍ឱ្យស្របទៅតាមមតិយោបល់របស់កិច្ចប្រជុំអន្តរក្រសួងនេះ ហើយត្រូវបញ្ជូនរបាយការណ៍មកក្រសួងបរិស្ថានជាថ្មីទៀតដើម្បីឱ្យក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានធ្វើការពិនិត្យរបាយការណ៍ចុងក្រោយ។

នៅពេលដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងកិច្ចសន្យាការពារបរិស្ថាន[4] ត្រូវបានកែសម្រួល និងឯកភាពជាចុងក្រោយរួចហើយ ក្រសួងបរិស្ថានចេញលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីឱ្យម្ចាស់គម្រោងយកទៅប្រើប្រាស់ជាផ្លូវការដែលពាក់ព័ន្ធជាមួយអាជីវកម្មរបស់គម្រោង។ បន្ទាប់ពីម្ចាស់គម្រោងទទួលបានលិខិតឯកភាពរួច ម្ចាស់គម្រោងត្រូវចាប់ផ្តើមអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន ហើយត្រូវបញ្ជូននូវរបាយការណ៍អង្កេតតាមដានបរិស្ថាននៅរៀងរាល់ ៣ ឬ ៦ខែម្តងទៅកាន់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន។ ក្រសួងបរិស្ថានត្រូវធ្វើការអង្កេតតាមដានលើការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោងរហូតដល់គម្រោងត្រូវបានបញ្ចប់ជាផ្លូវការនៅពេលណាមួយ។ តារាងទី១ ខាងក្រោមសង្ខេបនូវដំណើរការនេះដោយភ្ជាប់ជាមួយខ្លឹមសារសំខាន់ៗបន្ថែមដែលផ្អែកទៅលើបទពិសោធន៍ជាក់ស្តែង។

តារាងទី ១៖ សង្ខេបនូវដំណើរការពិនិត្យ និងឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

| **សកម្មភាព ឬយន្តការការងារ** | **លទ្ធផលពីការអនុវត្ត** |
|---|---|
| ▪ ម្ចាស់គម្រោងនិងក្រុមហ៊ុនទីប្រឹក្សារៀបចំដាក់ពាក្យសុំពិនិត្យលក្ខខណ្ឌការងារសម្រាប់ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម | ▪ លិខិតអនុញ្ញាតសម្រាប់ការសិក្សាវាយតម្លៃវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម |
| ▪ ម្ចាស់គម្រោងនិងក្រុមហ៊ុនទីប្រឹក្សារៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម *(រួមបញ្ចូលទាំងកិច្ចពិគ្រោះយោបល់ជាសាធារណៈថ្នាក់ខេត្ត)* | ▪ សេចក្តីព្រាងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម |
| ▪ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាដាក់របាយការណ៍ជូនក្រសួងបរិស្ថានសម្រាប់ការពិនិត្យ និងផ្តល់យោបល់ | ▪ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានចាត់តាំងក្រុមការងារពិនិត្យ |
| ▪ ក្រុមការងាររបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានចុះត្រួតពិនិត្យទីតាំងគម្រោងជាក់ស្តែង | ▪ នាយកដ្ឋានរៀបចំរបាយការណ៍អំពីលទ្ធផលនៃការចុះត្រួតពិនិត្យ និងដាក់បង្ហាញជូននៅពេលប្រជុំបច្ចេកទេសរបស់នាយកដ្ឋាន |
| ▪ កិច្ចប្រជុំថ្នាក់នាយកដ្ឋានដើម្បីពិនិត្យបច្ចេកទេសទៅលើ | ▪ មតិយោបល់បច្ចេកទេសកែលម្អលើរបាយ- |

[4] ប្រសិនបើគម្រោងអាចត្រូវបានឯកភាពនៅពេលខាងមុខ ក្រសួងបរិស្ថាន និងក្រុមហ៊ុនម្ចាស់គម្រោងនឹងរៀបចំនូវកិច្ចសន្យាការពារបរិស្ថានស្របពេលដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមកំពុងត្រូវបានកែសម្រួលដោយក្រុមហ៊ុនទីប្រឹក្សា។

| | |
|---|---|
| របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម *(រួមបញ្ចូលទាំងការកែសម្រួលមតិយោបល់ទៅមករបស់នាយកដ្ឋាន)* | ការណ៍ *(ម្ចាស់គម្រោងនិងក្រុមហ៊ុនទីប្រឹក្សាកែសម្រួល និងដាក់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រឡប់មកក្រសួងបរិស្ថានសម្រាប់ការពិនិត្យម្តងទៀត)* |
| • កិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យបច្ចេកទេសទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម *(រួមបញ្ចូលទាំងការកែសម្រួលមតិយោបល់ទៅមករបស់អន្តរក្រសួង)* | • មតិយោបល់បច្ចេកទេសកែលម្អលើរបាយការណ៍ *(ម្ចាស់គម្រោងនិងក្រុមហ៊ុនទីប្រឹក្សាកែសម្រួល និងដាក់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រឡប់មកក្រសួងបរិស្ថានសម្រាប់ការត្រួតពិនិត្យម្តងទៀត)* |
| • ក្រសួងបរិស្ថាន និងនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងម្ចាស់គម្រោងរៀបចំកិច្ចសន្យាការពារបរិស្ថាន *(ម្ចាស់គម្រោងជាអ្នកស្នើសុំ និងរៀបចំកិច្ចសន្យានេះ)* | • នាយកដ្ឋាន និងម្ចាស់គម្រោងត្រូវត្រួតពិនិត្យ និងឯកភាពលើកិច្ចសន្យាការពារបរិស្ថាន |
| • ក្រសួងបរិស្ថានចេញលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់ម្ចាស់គម្រោង | • លិខិតឯកភាពជាផ្លូវការលើរបាយការណ៍ |
| • ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន | • ម្ចាស់គម្រោងដាក់របាយការណ៍អង្កេតតាមដានបរិស្ថានរៀងរាល់ ៣ ឬ ៦ខែម្តងជូននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់នៃក្រសួងបរិស្ថាន |

រូបភាពទី ១៖ សកម្មភាពចុះប្រមូលព័ត៌មាន ទិន្នន័យនិងពិភាក្សាជាមួយភាគីពាក់ព័ន្ធនៅក្នុងតំបន់មូលដ្ឋាន



រូបភាពទី២៖ សកម្មភាពចុះពិនិត្យទីតាំង និងកិច្ចប្រជុំផ្តល់មតិយោបល់លើរបាយការណ៍



ក្រុមការងាររបស់ក្រសួងបរិស្ថានចុះសិក្សានិងត្រួតពិនិត្យគម្រោង



កិច្ចប្រជុំថ្នាក់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន



កិច្ចប្រជុំអន្តរក្រសួងពិនិត្យលើរបាយការណ៍

## ១.៤ ការចូលរួមពីសាធារណជននៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

ការចូលរួមពីសាធារណជន គឺជាការចូលរួមពិគ្រោះយោបល់របស់អ្នកពាក់ព័ន្ធទៅនឹងគម្រោងអភិវឌ្ឍន៍ដែលអ្នកពាក់ព័ន្ធទាំងនោះរួមមាន៖ ក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធ ម្ចាស់គម្រោង ក្រុមហ៊ុនទីប្រឹក្សា តំណាងប្រជាពលរដ្ឋដែលរងនូវផលប៉ះពាល់ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលមានការពាក់ព័ន្ធទៅនឹងតំបន់គម្រោង (យោងតាមប្រកាសរបស់ក្រសួងបរិស្ថានលេខ ៣៧៦ ប្រក.បស្ថ ឆ្នាំ២០០៩)។ គោលបំណងនៃការចូលរួមពីសាធារណជន និងស្ថាប័នពាក់ព័ន្ធនេះ គឺដើម្បីធ្វើការបង្ហាញពីព័ត៌មានលម្អិតរបស់គម្រោង ក៏ដូចជាការទទួលបាននូវការព្រួយបារម្ភ មតិរិះគន់កែលម្អ យោបល់គាំទ្រ ព័ត៌មានលម្អិតពាក់ព័ន្ធនឹងបរិស្ថានដែលមានស្រាប់ក្នុងតំបន់គម្រោង និងមតិយោបល់នានាសម្រាប់ធ្វើការវាយតម្លៃបន្តដែលរួមចំណែកដល់ការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមនៅពេលបច្ចុប្បន្ន និងអនាគត។

ការលើកទឹកចិត្ត និងជំរុញឱ្យមានការចូលរួមជាសាធារណៈពីបណ្តាភាគីពាក់ព័ន្ធនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានយកចិត្តទុកដាក់ជាខ្លាំងពីសំណាក់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន។ នាយកដ្ឋានបានណែនាំក្រុមហ៊ុនម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាក្នុងការរៀបចំឱ្យមាននូវយន្តការ និងឱកាសនានាក្នុងការបង្កលក្ខណៈងាយស្រួលដល់ភាគីពាក់ព័ន្ធសំខាន់ៗដែលអាចទទួលរងនូវផលប៉ះពាល់អវិជ្ជមានពីសកម្មភាពរបស់គម្រោងដែលបានស្នើឡើង។ ដំណាក់កាល និងជំហានសំខាន់ៗដែលបានណែនាំ និងអនុវត្តកន្លងមកមានសង្ខេបក្នុងដ្យាក្រាម និងការរៀបរាប់ដូចខាងក្រោម៖

ដ្យាក្រាមទី ២៖ ដំណាក់កាលនៃការចូលរួមពីសាធារណជននៅក្នុងកិច្ចការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

១

**ដំណាក់កាលទី១** គឺជាដំណាក់កាលរៀបចំពិគ្រោះយោបល់ និងឯកភាពទៅលើលក្ខខណ្ឌការងារសម្រាប់ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

២

**ដំណាក់កាលទី២** គឺជាដំណាក់កាលប្រមូលព័ត៌មានពីសាធារណជនដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃ និងចងក្រងជារបាយការណ៍។

*ភាគីពាក់ព័ន្ធចូលរួមមាន ក) ប្រជាពលរដ្ឋមូលដ្ឋានពាក់ព័ន្ធតំបន់គម្រោង ខ) មេភូមិ គ) មេឃុំ ឃ) ស្រុក ង) អង្គការមិនមែនរដ្ឋាភិបាល និង ច) មន្ទីរជុំវិញខេត្ត ។*

៣

**ដំណាក់កាលទី៣** គឺជាកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្ត ក្នុងគោលបំណងទទួលបាននូវមតិយោបល់កែសម្រួលបន្ថែមទៅលើរបាយការណ៍។

៤

**ដំណាក់កាលទី៤** គឺនៅពេលដំណើរចុះត្រួតពិនិត្យទីតាំងផ្ទាល់របស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថានមុនពេលនាយកដ្ឋាននេះធ្វើការត្រួតពិនិត្យជាផ្លូវការលើរបាយការណ៍។

៥

**ដំណាក់កាលទី៥** គឺនៅពេលដែលរបាយការណ៍វាយតម្លៃនេះត្រូវបានត្រួតពិនិត្យ និងផ្តល់មតិយោបល់បច្ចេកទេសដោយនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន។

៦

**ដំណាក់កាលទី៦** គឺកិច្ចប្រជុំអន្តរក្រសួងស្តីពីការពិនិត្យនិងផ្តល់មតិយោបល់ លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមរបស់គម្រោង។

*តំណាងក្រសួងនិងអាជ្ញាធរពាក់ព័ន្ធដូចជា ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតំណាងមន្ទីរបរិស្ថានខេត្ត អាជ្ញាធរមូលដ្ឋាន និងតំណាងអាជ្ញាធរខេត្ត និងតំណាងអង្គការមិនមែនរដ្ឋាភិបាល។*

៧

**ដំណាក់កាលទី៧** គឺការចុះអង្កេតតាមដានលើការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោង។

*តំណាងមន្ទីរបរិស្ថានខេត្ត ម្ចាស់គម្រោង អាជ្ញាធរមូលដ្ឋាន និងតំណាងឬប្រជាពលរដ្ឋដែលពាក់ព័ន្ធជាមួយគម្រោង ឬតំបន់គម្រោង។*

**ដំណាក់កាលទី១** គឺជាពេលដែលក្រុមហ៊ុនម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវរៀបចំលក្ខខណ្ឌការងារសម្រាប់ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោងដែលបានស្នើឡើង។ លក្ខខណ្ឌការងារនេះត្រូវឆ្លងកាត់ការត្រួតពិនិត្យរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ហើយត្រូវទទួលការឯកភាពជាមុន មុនការសិក្សាវាយតម្លៃអាចត្រូវបានអនុញ្ញាតជាផ្លូវការ។ នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យនេះមិនមានការអញ្ជើញចូលរួមពីសាធារណជនទេ។

**ដំណាក់កាលទី២** គឺដំណាក់កាលប្រមូលព័ត៌មាន និងសិក្សាអំពីស្ថានភាពធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គម។ នៅក្នុងដំណាក់កាលនេះក្រុមហ៊ុនទីប្រឹក្សានិងក្រុមហ៊ុនម្ចាស់គម្រោងសហការគ្នាក្នុងការរៀបចំការសិក្សាប្រមូល និងចងក្រងនូវព័ត៌មាន និងទិន្នន័យនានាដែលមាននៅក្នុង និងជុំវិញតំបន់គម្រោង។ ភាគីពាក់ព័ន្ធ

សំខាន់ៗដែលមានប្រជាពលរដ្ឋដែលអាចរងផលប៉ះពាល់ អាជ្ញាធរមូលដ្ឋាន (មេភូមិ មេឃុំ និងអភិបាលស្រុក) អង្គការមិនមែនរដ្ឋាភិបាលដែលមានវត្តមាននៅក្នុងតំបន់ និងមន្ទីរពាក់ព័ន្ធក្នុងខេត្តត្រូវបានជួបសម្ភាសន៍ និងពិភាក្សាដាច់ដោយឡែកៗដើម្បីផ្សព្វផ្សាយអំពីព័ត៌មានគម្រោង ស្រង់យកនូវមតិយោបល់ និងអនុសាសន៍នានាដែលអាចជួយបំពេញតម្រូវការ និងសម្រាលការលំបាកនានាដែលគម្រោងអាចនឹងបង្កឡើង។ ព័ត៌មាន និងទិន្នន័យទាំងឡាយនឹងជួយដល់ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោង។

**ដំណាក់កាលទី៣** គឺដំណាក់កាលពិគ្រោះយោបល់ថ្នាក់ខេត្ត។ នៅពេលដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវបានរៀបចំសេចក្តីព្រាងរួចរាល់ហើយ ក្រុមហ៊ុនទីប្រឹក្សា និងក្រុមហ៊ុនម្ចាស់គម្រោងរៀបចំនូវកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្តទៅតាមតំបន់ដែលគម្រោងមានវត្តមាន។ កិច្ចប្រជុំនេះមានការអញ្ជើញភាគីពាក់ព័ន្ធសំខាន់ៗរួមមាន តំណាងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ អាជ្ញាធរភូមិ-ឃុំ-ស្រុក អាជ្ញាធរខេត្ត មន្ទីរពាក់ព័ន្ធជុំវិញខេត្ត និងតំណាងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ កិច្ចប្រជុំពិគ្រោះយោបល់នេះមានគោលបំណងបង្ហាញជូននូវលទ្ធផលបឋមនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោង និងប្រមូលមកវិញនូវធាតុចូល និងមតិយោបល់ និងអនុសាសន៍នានាដែលអាចជួយបញ្ចៀស និងកាត់បន្ថយនូវហេតុប៉ះពាល់អវិជ្ជមានពីសកម្មភាពរបស់គម្រោង។

**ដំណាក់កាលទី៤** គឺដំណាក់កាលចុះសិក្សាឈ្វេងយល់អំពីគម្រោងរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន។ នៅពេលដែលរបាយការណ៍ត្រូវបានរៀបចំ និងដាក់បញ្ចូលនូវមតិយោបល់ និងអនុសាសន៍នានារបស់ភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងដំណាក់កាលទី១ និងទី២រួចមក របាយការណ៍នេះត្រូវបញ្ជូនទៅកាន់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានដើម្បីធ្វើការពិនិត្យទីតាំងជាក់ស្តែង។ នាយកដ្ឋានចាត់តាំងក្រុមការងារដែលមានប្រធាន និងសមាជិកក្នុងការពិនិត្យរបាយការណ៍។ ដើម្បីឱ្យការពិនិត្យមានប្រសិទ្ធភាពខ្ពស់ ក្រុមការងារធ្វើដំណើរទៅកាន់តំបន់គម្រោង និងជួបពិភាក្សាដោយផ្ទាល់ជាមួយម្ចាស់គម្រោង ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ និងអាជ្ញាធរមូលដ្ឋានក្នុងការប្រមែប្រមូលព័ត៌មានបន្ថែម និងដើម្បីពិនិត្យជាក់ស្តែងទៅលើធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គមដែលមាននៅក្នុងតំបន់គម្រោង។ ភាគីពាក់ព័ន្ធដែលបានចូលរួមអាចលើកឡើងនូវមតិយោបល់ការព្រួយបារម្ភនានា និងសំណូមពរនានាអំពីគម្រោង។

**ដំណាក់កាលទី៥** គឺដំណាក់កាលប្រជុំបច្ចេកទេសពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោង។ បន្ទាប់ពីដំណើរទស្សនកិច្ចឈ្វេងយល់អំពីគម្រោង នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានរៀបចំកិច្ចប្រជុំបច្ចេកទេសក្នុងការពិនិត្យ និងផ្តល់យោបល់ទៅលើរបាយការណ៍។ មតិយោបល់អាចត្រូវបានដាក់បញ្ចូលបន្ថែមផងដែរពីភាគីពាក់ព័ន្ធ។

**ដំណាក់កាលទី៦** គឺដំណាក់កាលប្រជុំអន្តរក្រសួងពិនិត្យ និងឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោង។ នៅក្នុងកិច្ចប្រជុំនេះមានការចូលរួមពីតំណាងក្រសួងសំខាន់ៗជាច្រើនដូចមានរៀបរាប់នៅក្នុងក្រាហ្វិកខាងលើ ក្នុងនោះក៏មានតំណាងអាជ្ញាធរខេត្ត និងតំណាងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ កិច្ចប្រជុំនេះមានសារៈសំខាន់ណាស់ដោយសារនេះជាកិច្ចប្រជុំធំចុងក្រោយ និងជាដំណាក់កាលដែលត្រូវអនុម័តលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ តំណាងក្រសួង និងសមាជិកអង្គប្រជុំនីមួយៗដែលមានវត្តមានលើកឡើងនូវមតិយោបល់ សំណួរនិងការបញ្ជាក់នានា ការព្រួយបារម្ភ និងការផ្តល់អនុសាសន៍ ផ្សេងៗក្នុងគោលបំណងកាត់បន្ថយឱ្យបាននូវហេតុប៉ះពាល់អវិជ្ជមានពីគម្រោងដែលបានស្នើឡើង។

**ដំណាក់កាលទី៧** គឺដំណាក់កាលដែលក្រសួងបរិស្ថានចុះអង្កេតតាមដាន និងត្រួតពិនិត្យលើការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុនម្ចាស់គម្រោង បន្ទាប់ពីលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវបានផ្តល់ជូន។ ក្រសួងបរិស្ថាននឹងចុះត្រួតពិនិត្យដោយផ្ទាល់នៅតាមទីតាំងរបស់គម្រោង និងត្រូវជួបពិភាក្សាជាមួយមន្ទីរបរិស្ថាន អាជ្ញាធរមូលដ្ឋាន ម្ចាស់គម្រោង និងប្រជាពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋ

ដែលពាក់ព័ន្ធនៅក្នុងតំបន់គម្រោងដើម្បីស្វែងយល់អំពីស្ថានភាពអនុវត្តគម្រោងជាក់ស្តែង និងការព្រួយបារម្ភ ឬសំណូមពរនានាក្នុងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពបរិស្ថាន និងសង្គមក្នុងតំបន់គម្រោង និងតំបន់ជុំវិញ។

រូបភាពទី ៣៖ សកម្មភាពពិគ្រោះយោបល់ជាសាធារណៈក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម



*ការជួបពិគ្រោះយោបល់ជាសាធារណៈជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ដែលស្ថិតនៅក្នុងតំបន់គម្រោង*



*ការជួបពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងតំបន់*



*ការជួបពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាស្រុក/ខណ្ឌ*

# ជំពូកទី២



## ស្ថានភាពនៃការអភិវឌ្ឍនិងហេតុប៉ះពាល់សំខាន់ៗ

# ផ្នែកទី២៖ ស្ថានភាពនៃការអភិវឌ្ឍ និងហេតុប៉ះពាល់សំខាន់ៗ

## ២.១ ស្ថានភាពនៃការអភិវឌ្ឍ

ប្រទេសកម្ពុជាទទួលបាននូវសុខសន្តិភាពពេញលេញ ដែលជាកាតាលីករសំខាន់ក្នុងការជំរុញឱ្យមានការអភិវឌ្ឍន៍ និងការវិនិយោគលើវិស័យជាច្រើនក្នុងទិសដៅជំរុញការរីកចម្រើនផ្នែកសេដ្ឋកិច្ច។ ការអភិវឌ្ឍនានាមានដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍ (មានផ្លូវថ្នល់ សំណង់អគារ) ការវិនិយោគលើដំណាំកសិ-ឧស្សាហកម្ម ការអភិវឌ្ឍវិស័យរ៉ែ និងថាមពល (ការសាងសង់ទំនប់វារីអគ្គិសនី ការតបណ្តាញខ្សែអគ្គិសនីតង់ស្យុងខ្ពស់ ការផ្តល់អាជ្ញាបណ្ណសិក្សាស្វែងរ៉ករក និងធ្វើអាជីវកម្មធនធានរ៉ែ) និងការអភិវឌ្ឍវិស័យឧស្សាហកម្ម (មានរោងចក្រ តំបន់សេដ្ឋកិច្ចពិសេសជាដើម)។ ក្រៅអំពីការរួមចំណែកនូវកំណើនសេដ្ឋកិច្ចជាតិ និងមូលដ្ឋាន ស្ថានភាពនៃការអភិវឌ្ឍទាំងនេះអាចបង្កជាហេតុប៉ះពាល់ដល់ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គម ជាពិសេសការប៉ះពាល់ទៅលើការតាំងទីលំនៅ និងការប្រកបមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ នៅក្នុងផ្នែកនេះ យើងលើកឡើងនូវសក្តានុពលនៃវិស័យអភិវឌ្ឍន៍មួយចំនួន ដែលអាចបង្កហេតុប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា។

### ២.១.១ ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធ

ការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលក្រោមថវិកាជាតិ និងថវិកាជាជំនួយ ឬកម្ចីក្តី និងការវិនិយោគដោយផ្ទាល់ពីបរទេសទៅលើការកសាងផ្លូវថ្នល់ និងស្ពាន សំណង់អគារស្នាក់នៅនិងការិយាល័យ ការស្តារនិងសាងសង់នូវប្រព័ន្ធធារាសាស្ត្រ និងការសាងសង់និងពង្រីកអាកាសយានដ្ឋានជាដើម មានសន្ទុះកំណើនយ៉ាងច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ គេក៏សម្គាល់ឃើញដែរថាស្ថានភាពនៃការអភិវឌ្ឍនេះបានបង្កជាហេតុប៉ះពាល់ទៅលើការតាំងទីលំនៅ និងជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន ដោយសារគម្រោងទាំងនេះអាចមានតម្រូវការផ្ទៃដីដែលអាចត្រួត ឬជាន់លើគ្នាជាមួយដីលំនៅដ្ឋាន ឬការកាន់កាប់ដីធ្លី ឬទ្រព្យសម្បត្តិដោយឯកជនដែលបម្រើដល់ការចិញ្ចឹមជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

ប្រទេសកម្ពុជា ជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ កម្រិតកំណើននេះតម្រូវឱ្យមានការអភិវឌ្ឍបន្ថែមទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធនានាដូចផ្លូវថ្នល់ និងស្ពានជាដើម ដើម្បីជួយបំពេញតម្រូវការសម្រាប់អ្នកវិនិយោគ។ ការវិនិយោគលើវិស័យទាំងនេះបាននាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ចទាំងជាតិ និងនៅតាមមូលដ្ឋាន។ យោងតាមរបាយការណ៍របស់ក្រសួងសាធារណការ និងដឹកជញ្ជូនស្តីអំពីស្ថានភាពវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនក្នុងឆ្នាំ២០១៥ របាយការណ៍នេះបានលើកឡើងថា ប្រទេសកម្ពុជាមានប្រព័ន្ធផ្លូវគោកយ៉ាងច្រើនសម្បូរបែបដែលពេលបច្ចុប្បន្ននេះមានប្រវែងសរុប ៤៧.២០៧គីឡូម៉ែត្រ ដែលក្នុងនោះ ក). ផ្លូវជាតិកម្រិត១ មានប្រវែងសរុប ២.២៥៨គីឡូម៉ែត្រ ខ). ផ្លូវជាតិកម្រិត២មានប្រវែងសរុប ៣.៣៤២គីឡូម៉ែត្រ គ). ផ្លូវក្នុងខេត្តមានប្រវែងសរុប ៦.៦០៧គីឡូម៉ែត្រ និង ឃ). ផ្លូវជនបទមានប្រវែងសរុប ៣៥.០០០គីឡូម៉ែត្រដែលផ្លូវជនបទស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ ដោយឡែក ស្ពានចំនួន ៤.០៦០ ត្រូវបានសាងសង់ឡើងនៅទូទាំងប្រទេសកម្ពុជាដែលមានប្រវែងសរុប ៧៦.២២១ម៉ែត្រ។ ស្ពានធំៗរួមមានស្ពានគីហ្សូណា ស្ពានជ្រោយចង្វារ ស្ពាននាក់លឿង (ឬស្ពានត្សឹបាសា) ស្ពានព្រែកតាមាក់ ស្ពានព្រែកក្តាម ស្ពានកំពង់បាយ ស្ពានសេកុង ស្ពានកោះកុង ស្ពានជ្រោយចង្វារទី២ និងស្ពានព្រែកព្នៅជាដើម។ ផ្លូវនិងស្ពានទាំងនេះបានរួមចំណែកយ៉ាងច្រើនក្នុងការជំរុញសក្តានុពលអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចមូលដ្ឋានរបស់ប្រជាពលរដ្ឋដោយផ្ទាល់ និងដោយប្រយោល។

### ២.១.២ ការវិនិយោគលើដំណាំកសិឧស្សាហកម្ម

ប្រទេសកម្ពុជាបានជំរុញការអភិវឌ្ឍកសិកម្មយ៉ាងខ្លាំង។ ការបើកទូលាយឱ្យមានការវិនិយោគខ្នាតធំជាពិសេសក្នុងវិស័យកសិឧស្សាហកម្មក្នុងទម្រង់រូបភាពជាដីសម្បទានសេដ្ឋកិច្ចទៅឱ្យក្រុមហ៊ុនឯកជនទាំងស្រុក និងបរទេស។ តាមច្បាប់ស្តីពីសម្បទានសេដ្ឋកិច្ចឆ្នាំ២០០៥ (លេខ ១៤៦ អនក្រ.បក) រាជរដ្ឋាភិបាលកម្ពុជាអាចផ្តល់ដីសម្បទានសេដ្ឋកិច្ចត្រឹមតែ ១០.០០០ហិកតាប៉ុណ្ណោះសម្រាប់សម្បទានិកម្នាក់។ ការផ្តល់សម្បទានក្នុងទំហំធំៗជាទូទៅច្រើនតែមានការប៉ះទង្គិចជាមួយនឹងការកាន់កាប់ដោយស្របច្បាប់ និងមិនស្របច្បាប់ទៅលើដីលំនៅដ្ឋានកសិកម្ម និងដីព្រៃអារក្ស ឬព្រៃកប់សព ឬព្រៃជំនឿនានារបស់ប្រជាពលរដ្ឋនៅក្នុងតំបន់មូលដ្ឋាន។ ការកាន់កាប់និងប្រើប្រាស់នូវដីធ្លី និងធនធានសំខាន់ៗទាំងនេះជាផ្នែកយ៉ាងរឹងមាំក្នុងការកសាង និងទ្រទ្រង់នូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាពិសេសជនក្រីក្រ និងងាយរងគ្រោះ។ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំង៥ក្នុងផ្តល់ជាដីសម្បទានសេដ្ឋកិច្ច មានគោលការណ៍ ២សំខាន់គឺ ជា *(១). ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងការអភិវឌ្ឍដីសម្រាប់គម្រោងសម្បទាន និងជាដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មីស្របតាមល័ក្ខខណ្ឌគតិយុត្ត និងនីតិវិធីជាធរមាន។ (២). អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធានាថា មិនមានការបង្ខំឱ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិមានច្រកចេញចូលទៅកាន់ដីឯកជន (មាត្រា ៤)*។

### ២.១.៣ ការអភិវឌ្ឍវិស័យរ៉ែ និងថាមពល

ប្រទេសកម្ពុជារក្សាបាននូវស្ថេរភាពសេដ្ឋកិច្ច និងនយោបាយក្នុងរយៈប៉ុន្មានឆ្នាំចុងក្រោយនេះដែលបានជំរុញនិងទាក់ទាញនូវអ្នកវិនិយោគទុនទាំងក្នុង និងក្រៅប្រទេសឱ្យចូលមកធ្វើការបណ្តាក់ទុនវិនិយោគលើវិស័យរ៉ែ និងថាមពល។ វិស័យឧស្សាហកម្មរ៉ែ កាន់តែមានតួនាទីសំខាន់នៅក្នុងវិស័យនិយោគទាំងនេះ ហើយក៏កំពុងតែមានសន្ទុះកើនឡើងជាលំដាប់។ ជាងនេះទៅទៀត ឧស្សាហកម្ម រ៉ែក៏មានសក្តានុពលចូលរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ចជាតិ តាមរយៈការបង់ពន្ធ និងសួយសារអាករនានា ការផ្តល់ការងារធ្វើ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់មូលដ្ឋាន។ គិតមកដល់ត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៣ ក្រសួងរ៉ែ និងថាមពលបានផ្តល់អាជ្ញាបណ្ណស្វែងរុករករ៉ែជូនក្រុមហ៊ុនក្នុងស្រុក និងបរទេស (អូស្ត្រាលី ចិន វៀតណាម រុស្ស៊ី កូរ៉េ កាណាដា) បានចំនួន ១០៦ ក្រុមហ៊ុនដែលក្នុងនោះមានអាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈចំនួន ១៣២អាជ្ញាបណ្ណ រ៉ែបុកស៊ីតចំនួន ២អាជ្ញាបណ្ណ រ៉ែខ្សាច់ចំនួន ២ អាជ្ញាបណ្ណ និងរ៉ែធ្យូងថ្មចំនួន ១១អាជ្ញាបណ្ណ (ដកស្រង់ចេញពីគេហទំព័ររបស់ក្រសួងរ៉ែ និងថាមពលនៅឆ្នាំ ២០១៧)។ ក្រៅអំពីនេះក្រសួងបានផ្តល់អាជ្ញាបណ្ណអាជីវកម្មរ៉ែជូនដល់ក្រុមហ៊ុនមួយចំនួនដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធការដ្ឋាន អណ្តូងរ៉ែ រោងចក្រ និងឈានទៅធ្វើអាជីវកម្មធនធានរ៉ែ។ អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មរ៉ែមាសចំនួន ៤ អាជ្ញាបណ្ណ រ៉ែដែកចំនួន ១ អាជ្ញាបណ្ណ អាជីកម្មរ៉ែត្បូងថ្មមានតម្លៃចំនួន ១ អាជ្ញាប័ណ្ណ អាជីវកម្មថ្មកំបោរសម្រាប់រោងចក្រស៊ីម៉ងត៍ចំនួន ៧ អាជ្ញាបណ្ណ និងអាជីវកម្មថ្មហ្វូសស្វាតចំនួន ១ អាជ្ញាបណ្ណ។

របាយការណ៍ប្រចាំឆ្នាំ២០១៧[5] របស់អាជ្ញាធរអគ្គិសនីកម្ពុជា បានកត់សម្គាល់ថាតម្រូវការថាពលអគ្គិសនីនឹងមានកំណើនគួរឱ្យកត់សម្គាល់មួយក្នុងរយៈពេល ១៥ឆ្នាំខាងមុខនេះ។ តម្រូវការសម្រាប់ការផលិតថាមពលអគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជានឹងមានកំណើនពី ២.២៤២GWh និង ៤០៩MW នៅឆ្នាំ២០១០ ទៅ ១៤.៩៥១GWh និង ២.៦៧៨MW នៅឆ្នាំ២០២៥។ នៅក្នុងឆ្នាំ២០១៧ អានុភាពដំឡើងសរុបប្រមាណ ២.៥២០MW ដែលក្នុងនោះរួមមានវារីអគ្គិសនីប្រមាណ ១.៣៣០MW ធ្យូងថ្មប្រមាណ ៥៣៥MW ប្រេងឥន្ទនៈប្រមាណ ២៤៨MW ជីវម៉ាសប្រមាណ ៦MW ពន្លឺព្រះអាទិត្យ ១០MW និងនាំចូលពីប្រទេសជិតខាងដូចជាប្រទេសថៃឡង់ដ៏ ប្រទេសវៀតណាម និងប្រទេសឡាវ សរុបប្រមាណ ៣៨៨MW។

---

[5] អគ្គិសនីកម្ពុជា (២០១៧) របាយការណ៍ប្រចាំឆ្នាំ២០១៧។ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ថាមពលផលិតសរុបប្រមាណ ៧.៦៦៥GWh ក្នុងនោះប្រភពពីវារីអគ្គិសនីមាន ៣៥% ប្រភពធ្យូងថ្ម ៤៦,៥% ប្រភពប្រេងឥន្ធនៈ ៣% ប្រភពជីវម៉ាស ០,៥% ថាមពលពន្លឺព្រះអាទិត្យ ០,១% និងការនាំចូលពីប្រទេសជិតខាង ១៥%។ ជាលទ្ធផលនៃការអភិវឌ្ឍប្រភពអគ្គិសនីក្នុងស្រុកបានធ្វើឱ្យការនាំចូលថាមពលពីប្រទេសជិតខាងថយចុះគួរឱ្យកត់សម្គាល់ពី ៦២%នៅឆ្នាំ២០១០ មកត្រឹម ១៥% នៅឆ្នាំ២០១៧ និងការប្រើប្រាស់ប្រេងឥន្ធនៈថយចុះយ៉ាងគំហុកពី ៣៤% មកត្រឹម ៣% និងមានកំណើនផលិតកម្មសរុបប្រចាំឆ្នាំប្រមាណ ១៦% បើប្រៀបធៀបនឹងឆ្នាំ២០១៦។

ក្រាហ្វិកទី១៖ អានុភាពដំឡើងតាមប្រភេទពីឆ្នាំ២០១២-២០១៧




ប្រភព៖ អគ្គិសនីកម្ពុជា (២០១៧)

ក្រាហ្វិកទី ២៖ ការផលិតថាមពលតាមប្រភេទ នៅឆ្នាំ២០១៧




ប្រភព៖ អគ្គិសនីកម្ពុជា (២០១៧)

### ២.១.៤ ការអភិវឌ្ឍវិស័យឧស្សាហកម្ម

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥ បានព្យាករណ៍ និងជំរុញថាត្រឹមឆ្នាំ២០២០ វិស័យឧស្សាហកម្មនឹងរួមចំណែកប្រមាណ ២៨ភាគរយនៃផលិតផលក្នុងស្រុកសរុប និងអាចឈានហួសទៅដល់ ៣០ភាគរយក្នុងឆ្នាំ២០២៥។ ការងារសំខាន់មួយក្នុងចំណោមអត្ថិភាពជាច្រើនទៀតគឺការជំរុញការបង្កើត និងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស។ តំបន់ប្រភេទនេះតម្រូវឱ្យមានផ្ទៃដីយ៉ាងតិចណាស់ ៥០ហិកតា និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន (ប្រព័ន្ធទឹក ភ្លើង លូទឹកស្អុយ ការគ្រប់គ្រងបរិស្ថានជាដើម) សម្រាប់បម្រើដល់ការវិនិយោគនៅក្នុងតំបន់។ គិតត្រឹមឆ្នាំ២០១៣ តំបន់សេដ្ឋកិច្ចពិសេសក្នុងព្រះរាជាណាចក្រកម្ពុជាមានចំនួន ២២ទីតាំងនៅក្នុងខេត្ត-ក្រុងចំនួន ១០ មានដូចជា រាជធានីភ្នំពេញ កណ្តាល ស្វាយរៀង បន្ទាយមានជ័យ តាកែវ ព្រះសីហនុ កំពត កោះកុង កំពង់ចាម និងពោធិសាត់។

តាមបទពិសោធន៍ជាក់ស្តែងក្នុងប្រទេសកម្ពុជា គម្រោងអភិវឌ្ឍន៍ឯកជននៅតាមវិស័យអភិវឌ្ឍន៍ដូចបានរៀបរាប់ខាងលើនេះច្រើនបង្កជាហេតុប៉ះពាល់ទៅលើធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គមរបស់ប្រជាជននៅតាមតំបន់មូលដ្ឋាន។ ហេតុប៉ះពាល់ដែលបង្កជាការព្រួយបារម្ភខ្លាំងនោះ គឺការតម្រូវឱ្យមាននូវការរុះរើលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តរបស់ប្រជាជនដែលទទួលរងផលប៉ះពាល់។ គំនូសបំព្រួញអំពីហេតុប៉ះពាល់ទៅលើការរុះរើលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តពីវិស័យអភិវឌ្ឍន៍នានា ត្រូវបានបង្ហាញយ៉ាងខ្លីដូចគំនូសខាងក្រោម។ គំនូសនេះបង្ហាញថា វិស័យអភិវឌ្ឍន៍ដែលមាននាពេលបច្ចុប្បន្ន ក្រៅតែអំពីការជំរុញកំណើនសេដ្ឋកិច្ចជាតិ និងមូលដ្ឋាន គម្រោងវិនិយោគទាំងឡាយដែលស្ថិតនៅក្នុងវិស័យអភិវឌ្ឍន៍ទាំងនេះ ក៏បានរួមចំណែកក្នុងការបង្កជាហានិភ័យទៅលើការការតាំងទីលំនៅដ្ឋាន និងការប៉ះទង្គិចដល់ជីវភាពរបស់ប្រជាពលរដ្ឋផងដែរ។

ដ្យាក្រាមទី ៣៖ រូបគំនូសបង្ហាញពីហេតុប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តពីវិស័យអភិវឌ្ឍន៍នានា



## ២.២ ស្ថានភាពហេតុប៉ះពាល់បរិស្ថាន-សង្គម

ហេតុប៉ះពាល់មួយចំនួនសំខាន់ៗ ដែលវិស័យអភិវឌ្ឍន៍អាចបង្កជាហានិភ័យទៅលើការតាំងទីលំនៅដ្ឋាន ដោយមិនស្ម័គ្រចិត្ត និងជីវភាពរស់នៅមានដូចជា៖

### ២.២.១ ការប៉ះពាល់ទៅលើការប្រើប្រាស់ដីធ្លី និងការកាន់កាប់ទ្រព្យសម្បត្តិឯកជន

គម្រោងវិនិយោគឯកជនភាគច្រើនវិនិយោគនៅលើផ្ទៃដីធំ (ច្រើនបំផុត ១០.០០០ហិកតា) ក្នុងរូបភាពជាដីសម្បទានសេដ្ឋកិច្ច ដែលទំហំនេះច្រើនតែមានផ្ទៃដីជាន់គ្នាជាមួយការប្រើប្រាស់ដីធ្លី និងការកាន់កាប់ទ្រព្យសម្បត្តិឯកជននានារបស់ប្រជាពលរដ្ឋនៅក្នុងតំបន់មូលដ្ឋាន។ ប្រជាពលរដ្ឋតាមទីជនបទប្រកបរបរចិញ្ចឹមជីវិតពីការធ្វើកសិកម្មលើដី ដូចជាការធ្វើស្រូវវស្សា ស្រូវប្រាំង ដំណាំបន្លែ និងចម្ការផ្សេងៗ។ ក្រៅអំពីការប្រើប្រាស់ដីសម្រាប់ការងារកសិកម្ម ដីមួយផ្នែកធំក៏ត្រូវបានប្រើប្រាស់សម្រាប់សាងសង់លំនៅដ្ឋានស្នាក់នៅ និងការធ្វើអាជីវកម្មនៅផ្ទះផងដែរ។

### ២.២.២ ការបាត់បង់មុខរបរ និងប្រាក់ចំណូល

ការវិនិយោគអាចបង្កជាការរំខាន ឬខូចខាតដល់មុខរបរ និងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ ការធ្វើសកម្មភាពរបស់គម្រោងអាចរំខានដល់ការធ្វើចរាចរណ៍ ការប្រកបមុខរបរផ្សេងៗ និងអាចធ្វើឱ្យមានការបាត់បង់ធនធានព្រៃឈើ និងអនុផលព្រៃឈើ ការបាត់បង់នៅដែននេសាទ និងធនធានជីវៈចម្រុះ និងការបាត់បង់នៅធនធានមូលដ្ឋានមួយចំនួនទៀតដែលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតមុខរបរ និងការធានាបាននូវប្រាក់ចំណូលប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

### ២.២.៣ ការបាត់បង់ធនធានព្រៃឈើ និងអនុផលព្រៃឈើ

ការវិនិយោគឯកជនជាពិសេស វិស័យកសិ-ឧស្សាហកម្ម វិស័យឧស្សាហកម្មរ៉ែ និងថាមពល ភាគច្រើនស្ថិតនៅក្នុងតំបន់ធម្មជាតិដែលមានធនធានព្រៃឈើដែលជាធនធានយ៉ាងសំខាន់ សម្រាប់ប្រជាពលរដ្ឋតាមទីជនបទ។ ប្រជាពលរដ្ឋក្រីក្រច្រើនតែចេញ-ចូលក្នុងតំបន់ព្រៃឈើដើម្បីប្រមូលផល និងអនុផលព្រៃឈើសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ និងសម្រាប់ការលក់ដូរជាលក្ខណៈគ្រួសារក្នុងការទ្រទ្រង់ជីវភាព។ ការផ្តល់អាជ្ញាបណ្ណសម្រាប់ការវិនិយោគនៅក្នុងតំបន់ដែលមានធនធានព្រៃឈើបែបនេះ ចៀសមិនផុតពីការប៉ះទង្គិច និងខូចខាតទៅដល់ធនធានព្រៃឈើដែលជាធនធានចាំបាច់ក្នុងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ។

### ២.២.៤ ការបាត់បង់ធនធានជលផល និងជីវៈចម្រុះក្នុងទឹក

គម្រោងវិនិយោគជាច្រើនទៀតដូចជាគម្រោងអាជីវកម្មរ៉ែលោហៈ គម្រោងបូមខ្សាច់ គម្រោងបូម និងចាក់ដីបំពេញលំហសមុទ្រនិងតំបន់ដីសើមសម្រាប់សាងសង់ទីក្រុង គម្រោងសាងសង់ទំនប់វារីអគ្គិសនី គម្រោងសាងសង់កំពង់ផែ គម្រោងសាងសង់រោងចក្រនៅក្បែរប្រភពទឹក និងគម្រោងសាងសង់ស្ពានជាដើមសុទ្ធតែអាចបង្កជាហេតុប៉ះពាល់ដល់ជីវៈចម្រុះក្នុងទឹក និងធនធានជលផលតាមរយៈការបំពុលគុណភាពទឹក ការខូចខាតជម្រក និងចំណីអាហារសម្រាប់សារពាង្គកាយ និងភាវៈរស់នានា។

### ២.២.៥ ការប៉ះពាល់ទៅលើជំនឿ ប្រពៃណី និងទំនៀមទម្លាប់

សកម្មភាពរបស់គម្រោងវិនិយោគក៏អាចបង្កជាការព្រួយបារម្ភ ការរំខានដល់ទីតាំងសក្ការៈ និងការប្រតិបត្តិនានាទៅលើជំនឿ ប្រពៃណី សាសនា និងទំនៀមទម្លាប់របស់ប្រជាពលរដ្ឋក្នុងតំបន់មូលដ្ឋាន។ បទពិសោធន៍ជាច្រើនបានបង្ហាញថាព្រៃអារក្ស ព្រៃកប់សព ព្រៃជំនឿ និងរោងអ្នកតាជាពិសេសរបស់ក្រុមជនជាតិដើមភាគតិចត្រូវបានរុះរើចេញ ឬទន្ទ្រានសម្រាប់ការអនុវត្តរបស់គម្រោង។

### ២.២.៦ សុខភាពនិងសុវត្ថិភាព

គម្រោងវិនិយោគអាចបង្កជាហេតុប៉ះពាល់ទៅលើបញ្ហាសុខភាព និងសុវត្ថិភាពរបស់បុគ្គលិក-កម្មករ និងសាធារណជនដែលរស់នៅតាមបណ្តោយផ្លូវ និងជុំវិញតំបន់គម្រោង។ ការរងរបួស និងគ្រោះថ្នាក់ផ្សេងៗដូចជាការដួល ការចក់ឬឆ្លងចរន្តអគ្គិសនី ការធ្លាក់ពីទីខ្ពស់ ឬការប្រឈមទៅនឹងសំឡេង ឬរំញ័រខ្លាំង ការហុយធូលី ការលេចជ្រាបសារធាតុគ្រោះថ្នាក់នានាដែលទាំងអស់នេះអាចប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពរបស់បុគ្គលិក-កម្មករ និងសាធារណជន។

### ២.២.៧ ជម្លោះក្នុងការប្រើប្រាស់ទឹក និងថាមពល

វត្តមានរបស់គម្រោងវិនិយោគអាចបង្កជាជម្លោះក្នុងការប្រើប្រាស់ធនធាន ក៏ដូចជាសេវាកម្មមូលដ្ឋានមួយចំនួនដូចជាទឹកស្អាត និងថាមពលជាដើមដែលប្រជាពលរដ្ឋមូលដ្ឋានកំពុងប្រើប្រាស់សម្រាប់ការងារចិញ្ចឹមជីវិត និងការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។

ដ្យាក្រាមទី៤៖ រូបគំនូសបង្ហាញផលប៉ះពាល់អវិជ្ជមានពីវិស័យអភិវឌ្ឍន៍ជាតិសំខាន់ៗ




## ២.៣ តំបន់ដែលងាយរងគ្រោះ

នៅក្នុងបរិបទនៃផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តនេះ តំបន់ដែលងាយរងគ្រោះគឺជាតំបន់ ឬទីតាំងដែល (១) មានដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់ (២) តំបន់ដែលសម្បូរណ៍ធនធានព្រៃឈើ និង (៣) ជាតំបន់ទាំងឡាយណា ដែលត្រូវបានចាត់ទុកថាជាតំបន់ដែលងាយប្រឈមទៅនឹងហានិភ័យនៃគ្រោះមហន្តរាយ

ធម្មជាតិ។ ផលប៉ះពាល់ពីគម្រោងវិនិយោគ ឬអភិវឌ្ឍន៍នឹងជួបប្រទះបញ្ហាច្រើន ប្រសិនបើគម្រោងទាំងនោះមិនបានធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឱ្យបានដិតដល់ និងគ្រប់ជ្រុងជ្រោយនោះទេ ជាពិសេសនៅតាមតំបន់ដែលមានដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់ ដែលងាយនឹងធ្វើឱ្យមានផលប៉ះពាល់ទៅលើការតាំងទីលំនៅរបស់ប្រជាពលរដ្ឋជាច្រើន។

### ២.៣.១ តំបន់ដែលមានដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់

ស្ថិតិរបស់របាយការណ៍ជំរឿនឆ្នាំ២០១៩ បានកំណត់ថាប្រជាពលរដ្ឋសរុបក្នុងប្រទេសកម្ពុជាមាន ១៥.២៨៨.៤៨៩នាក់ (ស្ត្រីមានចំនួន ៧.៨៦៩.៩១២នាក់) ដែលចំនួននេះមិនទាន់រាប់បញ្ចូលនូវពលករដែលធ្វើការនៅក្រៅប្រទេសទេ។ ដង់ស៊ីតេមាន ៨៦នាក់ក្នុង១គីឡូម៉ែត្រក្រឡា។ បើគិតជាចំនួនគ្រួសារវិញ ប្រទេសកម្ពុជាក្នុងឆ្នាំ២០១៩ មានចំនួនគ្រួសារសរុប ៣.៣៤១.៧៧០ ដែលក្នុងនោះជាមធ្យម គ្រួសារនីមួយៗមានសមាជិកចំនួន ៤,៦នាក់។ ក្នុងចំណោមខេត្តក្រុងទាំងឡាយ តំបន់ដែលមានប្រជាពលរដ្ឋច្រើនជាងគេគិតត្រឹមឆ្នាំ២០១៩មានៈ រាជធានីភ្នំពេញ (២.១២៩.៣៧១នាក់ ឬ១៣,៩ភាគរយ) ខេត្តកណ្ដាល (១.១៩៥.៥៤៧នាក់ ឬ៧,៨ភាគរយ) ខេត្តព្រៃវែង (១.០៥៧.៤២៨នាក់ ឬ៦,៩ភាគរយ) ខេត្តសៀមរាប (១.០០៦.៥១២នាក់ ឬ៦,៦ភាគរយ) ខេត្តបាត់ដំបង (៩៨៧.៤០០ ឬ៦,៥ភាគរយ) ខេត្តតាកែវ (៨៩៩.៤៨៥នាក់ ឬ៥,៩ភាគរយ) និងខេត្តកំពង់ចាម (៨៩៥.៧៦៣នាក់ ឬ៥,៩ភាគរយ)។ ចំណែកខេត្តកែបមានប្រជាជនទាបជាងគេប្រមាណ ៤១.៧៩៨នាក់ ឬស្មើនិង ០,៣ភាគនៃប្រជាជនសរុបទូទាំងប្រទេសកម្ពុជា។

តារាងទី២៖ តារាងស្ថិតិប្រជាពលរដ្ឋសរុបក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៩

| ល.រ | ប្រជាសាស្ត្រ | | បរិមាណ |
|---|---|---|---|
| ១ | ចំនួនប្រជាពលរដ្ឋសរុប | | ១៥.២៨៨.៤៨៩ *នាក់ |
| | ស្ត្រី | | ៧.៨៦៩.៩១២នាក់ |
| | បុរស | | ៧.៤១៨.៥៧៧នាក់ |
| ២ | អត្រាកំណើនជាមធ្យមប្រចាំឆ្នាំ | | ១,២ ភាគរយ |
| ៣ | ដង់ស៊ីតេ (១គីឡូម៉ែត្រក្រឡា) | | ៨៦នាក់ |
| ៤ | ចំនួនគ្រួសារសរុប | | ៣.៣៤១.៧៧០ គ្រួសារ |
| ៥ | សមាជិកគ្រួសារជាមធ្យម | | ៤,៦ នាក់ |
| ៦ | ចំនួនប្រជាពលរដ្ឋតាមតំបន់ | | ដង់ស៊ីតេ/ម៉ែត្រក្រឡា |
| | *តំបន់ទំនាបកណ្ដាល* | ៧.៤៧៧.៤៤៤ នាក់ (៤៨,៩%) | ២៩៨នាក់ |
| | *តំបន់ទន្លេសាប* | ៤.៨០១.២៦០ នាក់ (៣១,៤%) | ៧១នាក់ |
| | *តំបន់ឆ្នេរនិងសមុទ្រ* | ១.០៦១.១៤៨ នាក់ (១២,៧%) | ៦២នាក់ |
| | *តំបន់ខ្ពង់រាប និងភ្នំ* | ១.៩៤៨.៦៣៧ នាក់ (៦,៩%) | ២៩នាក់ |

*សំគាល់៖ * តួលេខនេះមិនរាប់បញ្ចូលពលករធ្វើការនៅក្រៅប្រទេសឡើយ។ យោងតាមរបាយការណ៍លទ្ធផលសន្និបាតបូកសរុបការងារឆ្នាំ២០១៨ ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មានពលករធ្វើការនៅក្រៅប្រទេសចំនួន១.២៣៥.៩៩៣នាក់ ក្នុងប្រទេសថៃ ១.១៤៦.៦៨៥នាក់ សាធារណរដ្ឋកូរ៉េ ៤៩.០៩៩នាក់ ជប៉ុន ៩.១៩៥នាក់ ម៉ាឡេស៊ី ៣០.១១៣នាក់ សិង្ហបុរី ៨៣១នាក់ ហុងកុង ៥៤នាក់ និងអារ៉ាប់ប៊ីសាអូឌីត ១៦នាក់។*

*១) តំបន់ទំនាប៖ ខេត្តកំពង់ចាម ត្បូងឃ្មុំ កណ្ដាល ភ្នំពេញ ព្រៃវែង ស្វាយរៀង និងតាកែវ។*

*២) តំបន់ទំនាបបឹងទន្លេសាប៖ បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ សៀមរាប ឧត្ដរមានជ័យ និងប៉ៃលិន។*

*៣) តំបន់ឆ្នេរ៖ កំពត កោះកុង ព្រះសីហនុ និងកែប។*

*៤) តំបន់ខ្ពង់រាប និងតំបន់ភ្នំ៖ កំពង់ស្ពឺ ក្រចេះ មណ្ឌលគិរី ព្រះវិហារ រតនគិរី និងស្ទឹងត្រែង*

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (របាយការណ៍ជំរឿនប្រជាជនទូទៅនៅប្រទេសកម្ពុជា) ឆ្នាំ២០១៩

**ផែនទីទី១៖ ចំនួនប្រជាជនសរុបតាមរាជធានីខេត្ត ឆ្នាំ២០១៩**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១៩)[6]

[6]វិទ្យាស្ថានជាតិស្ថិតិ (២០១៩). *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩។* ក្រសួងផែនការ។ រាជធានីភ្នំពេញ

ផែនទីទី២៖ ការបែងចែករបាយភាគរយប្រជាជន ឆ្នាំ២០១៩




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១៩)

### ២.៣.២ តំបន់ដែលសម្បូរធនធានព្រៃឈើ

របាយការណ៍របស់ក្រសួងបរិស្ថានឆ្នាំ២០១៦ស្តីពីធនធានគម្របព្រៃឈើកម្ពុជាឆ្នាំ២០១៦[7] បានបង្ហាញថាផ្ទៃដីព្រៃឈើមានប្រមាណ ៨.៧៤២.៤០១ហិកតា[8] ស្មើនឹង ៤៨,១៤ភាគរយធៀបនឹងផ្ទៃដីសរុបទូទាំងប្រទេស។ តារាងខាងក្រោមបង្ហាញនូវទិន្នន័យគម្របព្រៃឈើតាមប្រភេទចំណាត់ថ្នាក់ព្រៃឈើនីមួយៗ៖

តារាងទី៣៖ ស្ថិតិទិន្នន័យធនធានគម្របព្រៃឈើឆ្នាំ២០១៦ (ព្រៃឈើជាតិ)

| ល.រ | ប្រភេទ | ហិកតា | ភាគរយ | ល.រ | ប្រភេទ | ហិកតា | ភាគរយ |
|---|---|---|---|---|---|---|---|
| ១ | ព្រៃស្រោង | ២.៨៦១.២៣៣ | ១៥,៧៦ | ១៤ | វាលស្មៅ | ៣៤១.១៣២ | ១,៨៨ |
| ២ | ព្រៃពាក់កណ្តាលស្រោង | ១.០៧១.៩៤៧ | ៥,៩០ | ១៥ | ចម្ការ | ៣.០១៧.៤៣៥ | ១៦,៦២ |

[7] ក្រសួងបរិស្ថាន (២០១៨). ធនធានគម្របព្រៃឈើកម្ពុជាឆ្នាំ២០១៦។ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
[8] ចំនួននេះរាប់បញ្ចូលទាំងផ្ទៃដីចម្ការកៅស៊ូ ចម្ការដូងប្រេង និងដំណាំហូបផ្លែដទៃទៀត។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | ព្រៃល្បោះ | ៣.៣៣៦.៣៤៩ | ១៨,៣៧ | ១៦ | ដីស្រែ | ៤.២២១.៤០៧ | ២៣,២៤ |
| ៤ | ព្រៃលិចទឹក | ៤៧៧.៨១៣ | ២,៦៣ | ១៧ | ថ្ម | ១.១០០ | ០,០១ |
| ៥ | ព្រៃដុះឡើងវិញ | ១៩៦.៨៤២ | ១,០៨ | ១៨ | ខ្សាច់ | ៤១.២៤៥ | ០,២៣ |
| ៦ | ព្រៃឫស្សី | ១២៥.៣៩៨ | ០,៦៩ | ១៩ | ភូមិ | ៣៥២.៩៨៧ | ១,៩៤ |
| ៧ | ព្រៃកោងកាង | ៣១.២២៦ | ០,១៧ | ២០ | ទីប្រជុំជន | ៤២.៩៣០ | ០,២៤ |
| ៨ | ព្រៃស្នាច់ | ២៥.៩០៦ | ០,១៤ | ២១ | ផ្ទៃទឹក | ៧៨៣.៨៦០ | ៤,៣២ |
| ៩ | ព្រៃស្រល់ | ៨.១៩៥ | ០,០៥ | ២២ | ព្រៃគុម្ពោត | ៦១៦.១៧៧ | ៣,៣៩ |
| ១០ | ចម្ការស្រល់ | ៣.៨៧០ | ០,០២ | | សរុប | ៩.៤១៨.២៧៣ | ៥១,៨៦ |
| ១១ | ចម្ការឈើដាំ | ៤៣.១២២ | ០,២៤ | | | | |
| ១២ | ចម្ការដូងប្រេង | ៥១.២៧៦ | ០,២៨ | | | | |
| ១៣ | ចម្ការកៅស៊ូ | ៥០៩.២២៤ | ២,៨០ | | | | |
| | សរុប | ៨.៧៤២.៤០១ | ៤៨,១៤ | | | | |

ប្រភព៖ ក្រសួងបរិស្ថាន (២០១៨)

ដោយឡែក ស្ថានភាពព្រៃឈើនៅតាមខេត្តក្រុងនីមួយៗមានស្ថានភាពធនធានខុសគ្នា។ ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ព្រៃឈើច្រើនតែប្រើប្រាស់ធនធានទាំងនោះជាប្រចាំក្នុងការទ្រទ្រង់ជីវភាពមូលដ្ឋាន។ ការសិក្សាជាច្រើនបានបញ្ជាក់ថាប្រជាពលរដ្ឋមូលដ្ឋានបានប្រើប្រាស់ផល និងអនុផលព្រៃឈើយ៉ាងសំខាន់ក្នុងការជំរុញសកម្មភាពសេដ្ឋកិច្ចជាលក្ខណៈគ្រួសារ និងសហគមន៍។ ក្រៅតែអំពីការប្រមូលផល និងអនុផល ប្រជាពលរដ្ឋចូលចិត្តតាំងទីលំនៅដ្ឋាននៅតាមតំបន់ព្រៃឈើនិងប្រើប្រាស់ដីព្រៃឈើសម្រាប់ការងារកសិកម្មផងដែរ។ គម្រោងវិនិយោគ ឬអភិវឌ្ឍនានាដែលកើតមាននៅក្នុងតំបន់ដែលមានសម្បូរណ៍ព្រៃឈើអាចបង្កជាហានិភ័យដល់ការរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិតដោយចៀសមិនរួច។ ម្ចាស់គម្រោងត្រូវធ្វើការសិក្សាអំពីស្ថានភាពធនធានព្រៃឈើតាមតំបន់ទាំងនេះដោយប្រុងប្រយ័ត្នមុននឹងធ្វើការសម្រេចចិត្តវិនិយោគនៅក្នុងតំបន់ណាមួយ។ តារាងទី៤ខាងក្រោមនេះបង្ហាញនូវតួលេខស្ថិតិធនធានព្រៃឈើតាមខេត្តនីមួយៗនៅក្នុងប្រទេសកម្ពុជា៖

តារាងទី៤៖ ទិន្នន័យធនធានគម្របព្រៃឈើជាតិតាមបណ្តាខេត្តឆ្នាំ២០១៦

| ខេត្ត | ផ្ទៃដីគម្របព្រៃឈើ (ហ.ត) | | | | | សរុបផ្ទៃដីពុំមានគម្របព្រៃឈើ (ហ.ត) | សរុបរួម (ហ.ត) |
|---|---|---|---|---|---|---|---|
| | ព្រៃស្រោង | ព្រៃពាក់កណ្តាលស្រោង | ព្រៃល្បោះ | ព្រៃផ្សេងៗ | សរុបផ្ទៃដីព្រៃឈើ (ហ.ត) | | |
| បន្ទាយមានជ័យ | ១.៤៦០ | ២.៨៦០ | ៩.៤៣៧ | ៨.០៥១ | ២១.៨០៨ | ៥៩៣.០១១ | ៦១៤.៨១៩ |
| បាត់ដំបង | ៥៩.៤៨៣ | ១៦.៣៨២ | ២០.០៧៥ | ១៧១.៥៧៣ | ២៦៧.៥១៣ | ៩១៩.៦៩៧ | ១.១៨៧.២១០ |
| កំពង់ចាម | ៦៥៨ | ៥៩ | ៦៤១ | ៥០.៩២៣ | ៥២.២៨១ | ៤០២.៨៩៣ | ៤៥៥.១៧៤ |
| កំពង់ឆ្នាំង | ១៧.៣១៩ | ៥.៤១៤ | ៧១.៩១៣ | ៤៧.១០៨ | ១៤១.៦៦៤ | ៣៨៧.៧៩៧ | ៥២៩.៤៦១ |
| កំពង់ស្ពឺ | ៦៤.៥៨៧ | ២១.៦៧៧ | ១៣០.០៦៥ | ១៩.១៧៨ | ២៣៥.៥០៧ | ៤៦០.៩៦៤ | ៦៩៦.៤៧១ |
| កំពង់ធំ | ១៩៤ ២៥១ | ១៤.៨៥០ | ៤៥.៩៤៨ | ២២៤.៦៤០ | ៤៧៩.៦៨៩ | ៧៦៥.០៧៤ | ១ ២៤៤.៧៦៣ |
| កំពត | ១២៥.៧៦៤ | ៣.៩២៤ | ២៧.៧៥៨ | ៤.៩៧០ | ១៦២.៤១៦ | ៣០៩.៣៩៩ | ៤៧១.៨១៥ |
| កណ្តាល | ០ | ០ | ៩៩ | ១៤.៦៤៤ | ១៤.៧៤៣ | ៣៤១.៦៣០ | ៣៥៦.៣៧៣ |
| កែប | ១.៨០៦ | ៩ | ០ | ១.២០១ | ៣.០១៦ | ១២.១៥៧ | ១៥.១៧៣ |
| កោះកុង | ៨៣៩.៩៣៨ | ១១.៦៣២ | ២៤.៤០៤ | ៩៥.២៤៧ | ៩៧១.២២១ | ២៤០.៣៧៤ | ១ ២១១.៥៩៥ |
| ក្រចេះ | ១០០.២៣៩ | ៩៥.៣៦៤ | ៤០៣.០៥៥ | ១៣៦.៤១០ | ៧៣៥.០៦៨ | ៤៦២.២៣៧ | ១.១៩៧.៣០៥ |
| មណ្ឌលគិរី | ១៣១.៤៣៩ | ២១២.៣៤១ | ៨០៣.៦៦៥ | ៦៧.៩៧៥ | ១.២១៥.៤២០ | ១៥១ ៤៧២ | ១.៣៦៦.៨៩២ |
| ឧត្តរមានជ័យ | ៥០.០៥១ | ១៨.៦៣៩ | ១០៤.៩១២ | ១៦.៣៦១ | ១៨៩.៩៦៣ | ៤៧៣.២០២ | ៦៦៣.១៦៥ |
| ប៉ៃលិន | ២៩ ៨៧៧ | ១.៤៥៤ | ៥០៣ | ៥១០ | ៣២.៣៤៤ | ៧៥.៣៦៧ | ១០៧.៧១១ |
| ភ្នំពេញ | ០ | ០ | ០ | ០ | ០ | ៣៧.៣៧៤ | ៣៧.៣៧៤ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ព្រះសីហនុ | ៤៨.៩០១ | ២.៥៧៩ | ២ | ២៩.៤៣២ | ៨០.៩១៤ | ៦៨.២៥១ | ១៤៩.២០៥ |
| ព្រះវិហារ | ២១១.៧៣៧ | ១៤១.៨៣៦ | ៦៩៨.៨៨០ | ៤២.០១៩ | ១.០៩៤.៤៧២ | ៣០៨.៦១៥ | ១.៤០៣.០៨៧ |
| ព្រៃវែង | ១៩ | ០ | ៩២ | ១.៦១៣ | ១.៧២៤ | ៤៧៤.៤៣៦ | ៤៧៦.១៦០ |
| ពោធិ៍សាត់ | ៤៤០.៥២៨ | ៧៣.១៥៧ | ១៣៨.៣០៩ | ៧៥.៦២៥ | ៧២៧.៦១៩ | ៤៣០.៩៧២ | ១.១៥៨.៥៩១ |
| រតនគិរី | ២៣៤.៧៧៦ | ១៧៣.៨២៤ | ៣៣៤.៥៥៥ | ១៥០.៧៦៣ | ៨៩៣.៩១៨ | ២៨៤.៥៤២ | ១.១៧៨.៤៦០ |
| សៀមរាប | ៤៤.៦៦២ | ២៣.០១៨ | ១១៧.៦៧៩ | ១៣៤.៣៥៨ | ៣១៩.៧១៧ | ២៣០.៣៤៤ | ១.០៥៤.៤៤៩ |
| ស្ទឹងត្រែង | ២៦១.២៤០ | ២៥២.៧៧៩ | ៣៩៥.១១៧ | ៦២.១៨១ | ៩៧១.៣១៧ | ២៣០.៣៤៤ | ១.២០១.៦៦១ |
| ស្វាយរៀង | ២៨ | ០ | ០ | ៥.១៨៩ | ៥.២១៧ | ២៨១.៦០៨ | ២៨៦.៨២៥ |
| តាកែវ | ១.៩១៦ | ០ | ៩.១១៥ | ២.៥៨៤ | ១៣.៦១៥ | ៣៣៩.៤២៨ | ៣៤៩.០៤៣ |
| ត្បូងឃ្មុំ | ៥៥៤ | ១៤៩ | ១២៥ | ១០៨.៥៤៤ | ១០៩.៦៧២ | ៣៨៣.៤៥០ | ៤៩៣.១២២ |
| ទន្លេសាប | ០ | ០ | ០ | ១.៥៦៣ | ១.៥៦៣ | ២៥៣.២០៧ | ២៥៤.៧៧០ |
| ផ្ទៃដីសរុប (ហ.ត) | ២.៨៦១.២៣៣ | ១.០៧១.៩៤៧ | ៣.៣៣៦.៣៤៩ | ១.៤៧២.៨៧២ | ៨.៧៤២.៤០១ | ៩.៤១៨.២៧៣ | ១៨.១៦០.៦៧៤ |
| ភាគរយ (%) | ១៥,៧៦ | ៥,៩០ | ១៨,៣៧ | ៨,១១ | ៤៨,១៤ | ៥១,៨៦ | ១០០ |

ប្រភព៖ ក្រសួងបរិស្ថាន (២០១៨)

### ២.៣.៣ តំបន់ដែលប្រឈមមុខនឹងហានិភ័យគ្រោះមហន្តរាយធម្មជាតិ

ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាស្ថិតនៅក្នុងទីតាំងដែលទទួលរងនូវគ្រោះមហន្តរាយធម្មជាតិមួយចំនួនដូចជា ទឹកជំនន់ (ដោយសារទឹកទន្លេ និងទឹកភ្លៀង) រាំងស្ងួត និងខ្យល់កន្ត្រាក់ជាដើម។ មកដល់ពេលបច្ចុប្បន្ននេះ បម្រែបម្រួលអាកាសធាតុបាននឹងគំរាមកំហែងបន្ថែមទៅលើការរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋានផងដែរ។ ទីតាំង និងតំបន់មួយចំនួនត្រូវបានកំណត់ថាជាតំបន់ដែលងាយរងគ្រោះ ដោយសារគ្រោះមហន្តរាយធម្មជាតិដែលការវិនិយោគ និងគម្រោងអភិវឌ្ឍន៍ទាំងឡាយចាំបាច់ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ដោយចៀសវាងការបង្កជាហានិភ័យបន្ថែមទៀតទៅលើប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ឧទាហរណ៍ខ្យល់ព្យុះកេតសាណាឆ្នាំ២០០៩ និងទឹកជំនន់ធំក្នុងឆ្នាំ២០១១ និង២០១៣ បានធ្វើឱ្យប្រជាពលរដ្ឋមួយភាគធំទទួលរងនូវទុក្ខវេទនាដោយសារការបាត់បង់ទ្រព្យសម្បត្តិ អាយុជីវិត និងមុខរបរចិញ្ចឹមជីវិត។ របាយការណ៍របស់មជ្ឈមណ្ឌល CEDM&HA ឆ្នាំ២០១៧[9] បានលើកឡើងថា ១៤ក្នុងចំណោម ២៥ខេត្តក្រុងទទួលរងនូវការបំផ្លិចបំផ្លាញពីខ្យល់ព្យុះកេតសាណានៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ដែលបានប៉ះទង្គិចចំនួន ១៨០.០០០គ្រួសារ ហើយបានបណ្តាលឱ្យមនុស្សចំនួន ៤៣ស្លាប់ និង ៦៧នាក់ទៀតរងរបួស។ ដោយឡែកចំពោះទឹកជំនន់ របាយការណ៍នេះក៏បានកត់សម្គាល់ថាទឹកជំនន់ឆ្នាំ២០១១ បានធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៣៥០.០០០គ្រួសារ (ប្រហែល ១,៥លាននាក់) និង ៥២.០០០គ្រួសារត្រូវជម្លៀសចាកចេញពីផ្ទះសម្បែង។ ក្នុងនោះខេត្តក្រុងចំនួន ១៨ត្រូវជន់លិច និងរងការខូចខាត និងមានការបាត់បង់ជីវិតមនុស្សចំនួន ២៥០នាក់។ ផ្ទៃដីស្រែជិត ៤៣១.០០០ហិកតាត្រូវទទួលរងការជន់លិចដែលក្នុងនោះ ២៦៧.០០០ហិកតាត្រូវខូចខាតទាំងស្រុង។ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗជាច្រើនទៀតត្រូវបានបំផ្លិចបំផ្លាញ ហើយតម្លៃសរុបនៃផលប៉ះពាល់នេះមានរហូតដល់ទៅ ៦៣០លានដុល្លារអាមេរិក។ របាយការណ៍ដដែលក៏បានលើកឡើងផងដែរអំពីទឹកជំនន់ឆ្នាំ២០១៣ដែលពេលនោះទឹកបានជន់លិច ២០ខេត្តក្រុងក្នុងចំណោមខេត្តក្រុងទាំង ២៤ ហើយប៉ះពាល់ដល់គ្រួសារចំនួន ៣៧៧.៣៥៤នាក់ និងបាត់បង់ជីវិតចំនួន ១៦៨នាក់ និងត្រូវជម្លៀសឱ្យចាកចេញពីលំនៅដ្ឋានទៅរកទីទួលសុវត្ថិភាពចំនួន ៣១.៣១៤គ្រួសារ។ ខេត្តក្រុងដែលងាយរងគ្រោះដោយសារទឹកជំនន់មាន៖

[9] Center for Excellence in Disaster Management and Human Assistance (CEDM&HA) (2017). *Cambodia Disaster Management Reference Handbook*. Hawaii, USA

តារាងទី៥៖ ខេត្ត និងក្រុងដែលប្រឈមមុខនឹងទឹកជំនន់

| ល.រ | ទឹកជំនន់ | ខេត្ត/ក្រុង |
|---|---|---|
| ១ | ជំនន់ទឹកភ្លៀង | បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្ដាល ពោធិ៍សាត់ និងរតនគិរី |
| ២ | ជំនន់ទឹកទន្លេមេគង្គ | កំពង់ចាម ក្រចេះ កណ្ដាល ព្រៃវែង ស្ទឹងត្រែង ស្វាយរៀង និងតាកែវ |

ប្រភព៖ CEDM&HA (ឆ្នាំ២០១៧)

ក្រាហ្វិកខាងក្រោមបង្ហាញថាទឹកជំនន់ គឺជាហានិភ័យដែលកើតឡើងញឹកញាប់ជាងគេនៅក្នុងប្រទេសកម្ពុជា (មានរហូតដល់ ៧២ភាគរយ) ហើយក៏ជាគ្រោះមហន្តរាយធម្មជាតិក៏បានសម្លាប់ជីវិតមនុស្សច្រើនជាងគេផងដែរ រហូតដល់ ៩៧,៤ភាគរយ។ ទឹកជំនន់ក៏ជាគ្រោះមហន្តរាយដែលបង្កឱ្យមានការខាតបង់សេដ្ឋកិច្ចយ៉ាងច្រើនរហូតដល់ ៩១,១ភាគរយ។ លទ្ធផលនៃការវាយតម្លៃភាពងាយរងគ្រោះឆ្នាំ២០១៧តាមរយៈសន្ទស្សន៍ INFORM[10] បានកំណត់សម្រាប់ប្រទេសកម្ពុជាដូចខាងក្រោម។ លទ្ធផលនេះបង្ហាញថាបើទោះបីជាប្រទេសកម្ពុជាមានភាពងាយរងគ្រោះទាប ប៉ុន្តែអាចនឹងជួបបញ្ហាច្រើនក្នុងការប្រឈមមុខនឹងគ្រោះហានិភ័យនានាដោយសារសមត្ថភាពឆ្លើយតបនៅកម្រិតតិចតួចនៅឡើយ។

តារាងទី៦៖ សន្ទស្សន៍សម្រាប់ការវាយតម្លៃភាពងាយរងគ្រោះ

| ល.រ | សន្ទស្សន៍ | ពិន្ទុ (១០/១០) |
|---|---|---|
| ១ | គ្រោះថ្នាក់ និងភាពប្រឈម (Hazards and Exposure) | ៤,៨ |
| ២ | ភាពងាយរងគ្រោះ (Vulnerabiility) | ៣,០ |
| ៣ | កង្វះខាតសមត្ថភាពឆ្លើយតប (Lack of Coping Capacity) | ៦,៥ |

ប្រភព៖ CEDM&HA (ឆ្នាំ២០១៧)

ក្រាហ្វិកទី៣៖ ព័ត៌មានអំពីហានិភ័យនិងគ្រោះមហន្តរាយធម្មជាតិសម្រាប់ប្រទេសកម្ពុជា




ប្រភព៖ CEDM&HA (ឆ្នាំ២០១៧ ទំព័រទី២០)

[10] ការសិក្សាដោយប្រើប្រាស់នូវសន្ទស្សន៍ INFORM។ INFORM ជាសន្ទស្សន៍សម្រាប់ការគ្រប់គ្រងហានិភ័យដែលជាឧបករណ៍សិក្សាជាសកលដែលមានតម្លាភាព និងផ្អែកលើគោលបំណងជាក់លាក់ក្នុងសិក្សាស្វែងយល់នូវហានិភ័យនៃវិបត្តិមនុស្សធម៌។ INFORM នេះវាយតម្លៃលើសន្ទស្សន៍ចំនួន ៥០ដោយបែងចែកតាមផ្នែកសំខាន់ៗដូចជា ១) គ្រោះថ្នាក់ (ហេតុការណ៍ដែលអាចនឹងកើតមានឡើង) និងភាពប្រឈមទៅនឹងហេតុការណ៍ទាំងនោះ ២) ភាពងាយរងគ្រោះ (ភាពងាយទទួលរងរបស់សហគមន៍ទៅនឹងគ្រោះថ្នាក់ទាំងនោះ) និង ៣) កង្វះខាតសមត្ថភាពក្នុងការឆ្លើយតប (ការខ្វះធនធានដែលអាចជួយដល់ការទប់ទល់នឹងផលប៉ះពាល់)។ សន្ទស្សន៍នេះកំណត់ពិន្ទុពី ១-១០ ដែលមានន័យថាពិន្ទុកាន់តែខ្ពស់ ប្រទេសនោះកាន់តែងាយរងគ្រោះពីហានិភ័យនានា។ INFORM នេះផ្ដល់នូវវិធីសាស្ត្រដែលមានតម្លាភាព និងផ្អែកលើការធ្វើជំរឿនត្រឹមត្រូវសម្រាប់ធ្វើការវិភាគនូវហានិភ័យនៃវិបត្តិនានានៅក្នុងកម្រិតពិភពលោក ថ្នាក់តំបន់ និងតាមប្រទេសនីមួយៗ។

## ២.៤ ក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះពីគម្រោងវិនិយោគ

ប្រជាពលរដ្ឋដែលងាយរងគ្រោះ គឺសំដៅទៅលើក្រុមប្រជាពលរដ្ឋដែលមិនមានសមត្ថភាព ឬលទ្ធភាពក្នុងការទ្រទ្រង់ជីវភាពដោយខ្លួនឯង មិនមានឱកាសក្នុងចូលរួមជីវភាពសង្គម និងមិនមានធនធានក្នុងការទប់ទល់ ឬស្តារឡើងវិញជាមួយហេតុការណ៍អាក្រក់ៗដែលអាចនឹងកើតមានឡើង។ យុទ្ធសាស្ត្រជាតិស្តីពីកិច្ចគាំពារសង្គមសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងក្រុមងាយរងគ្រោះ (២០១១-២០១៥) និងស្តង់ដារនីតិវិធីប្រតិបត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា[11] បានកំណត់ប្រភេទប្រជាពលរដ្ឋដែលងាយរងគ្រោះប្រហាក់ប្រហែលគ្នាដូចខាងក្រោម៖

### ២.៤.១ ប្រជាពលរដ្ឋក្រីក្រ (ស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ)

ការធ្វើអត្តសញ្ញាណកម្មប្រជាពលរដ្ឋក្រីក្រនៅក្នុងប្រទេសកម្ពុជាដោយក្រសួងផែនការក្នុងឆ្នាំ២០១២[12] បានកំណត់បែងចែកប្រជាពលរដ្ឋក្រីក្រជាពីរប្រភេទគឺក្រកម្រិតទី១ (ទ័លក្រ) និងក្រកម្រិតទី២ (ក្រ)។ គិតត្រឹមឆ្នាំ២០១២ ប្រទេសកម្ពុជាមានប្រជាពលរដ្ឋក្រកម្រិតទី១ចំនួន ៤៥ភាគរយ និងប្រជាពលរដ្ឋក្រីក្រកម្រិតទី២ ចំនួន ៥៥ភាគរយ[13]។ ចំនួនគ្រួសារក្រីក្រសរុបមាន ៥៧១.៦៦៧គ្រួសារដែលស្មើនឹង ២៧,២ភាគរយនៃចំនួនប្រជាពលរដ្ឋសរុប។ ក្នុងចំណោមខេត្តក្រុងទាំងអស់ដែលបានសិក្សា ខេត្តបាត់ដំបងមានចំនួនគ្រួសារក្រីក្រច្រើនជាងគេរហូតដល់ទៅ ៧៦.៤៦៦គ្រួសារ ខេត្តព្រៃវែងមានចំនួន ៦៦.៦៨៩គ្រួសារ ខេត្តតាកែវមានចំនួន ៥៥.៩៨៩គ្រួសារ ខេត្តកណ្តាលមានចំនួន ៥៥.៩៦៩គ្រួសារ និងខេត្តសៀមរាបមានចំនួន ៥២.៨៨៩គ្រួសារ។

### ២.៤.២ ប្រជាពលរដ្ឋចាស់ជរា

ក្រសួងផែនការនៃប្រទេសកម្ពុជាបានព្យាករណ៍ក្នុងឆ្នាំ២០១៦ថា ប្រជាពលរដ្ឋកម្ពុជាដែលមានវ័យចាប់ពី៦០ឆ្នាំឡើងទៅនឹងមានចំនួនប្រមាណ ៨,២ភាគរយត្រឹមឆ្នាំ២០២០ និងអាចកើនឡើងដល់ ១១ភាគរយក្នុងឆ្នាំ២០៣០[14]។ ស្ថានភាពកំណើនមនុស្សចាស់នេះនឹងពញាក់ស្មារតីដល់អ្នកធ្វើគោលនយោបាយ និងម្ចាស់គម្រោងអភិវឌ្ឍន៍ និងវិនិយោគទាំងឡាយឱ្យងាកមកគិតគូរអំពីក្រុមជនងាយរងគ្រោះដែលអាចទទួលរងនូវឥទ្ធិពលអាក្រក់ពីសកម្មភាពនានារបស់គម្រោង។ ការឆ្លើយតបរបស់គម្រោងទៅនឹងការស្តារឡើងវិញ និងការចូលរួមអភិវឌ្ឍន៍មូលដ្ឋានក៏ត្រូវគិតគូរ និងផ្តល់អត្ថិភាពចម្បងដល់ក្រុមជនចាស់ជរាផងដែរ។

### ២.៤.៣ ជនពិការជាមេគ្រួសារ

របាយការណ៍ជំរឿនពាក់កណ្តាលអាណត្តិក្នុងឆ្នាំ២០១៣ បានរកឃើញថាប្រជាពលរដ្ឋដែលមានពិការភាពមានរហូតដល់ទៅ ២,០៦ភាគរយនៃប្រជាពលរដ្ឋសរុប (សរុបក្នុងឆ្នាំ២០១៣ មាន ១៤.៦៧៦.៥៩១នាក់) ដែលក្នុងនោះមាន ០,៩៩ភាគរយជាស្ត្រី និងមាន ១,០៧ភាគរយជាបុរស[15]។ ចំនួនជនពិការសរុបត្រឹមឆ្នាំ២០១៣ មាន ៣០១.៦២៩នាក់ដែលមាន ១៥៧.០០៧នាក់ (ស្មើនឹង ៥២,០៥ភាគរយ) ជាបុរស និងមាន ១៤៤.៦២២នាក់ (៤៧,៩៥ភាគរយ) ជាស្ត្រី។ សមាមាត្រនៃជនពិការនៅក្នុងតំបន់ជនបទមានកម្រិត ២,២៥ភាគរយដែលខ្ពស់ជាតំបន់ទីក្រុងដែលមានត្រឹមតែ ១,៣២ភាគរយ) ប៉ុណ្ណោះ។ បើប្រៀបធៀបទៅនឹងចំនួនប្រជាពលរដ្ឋសរុបទូទាំង

---

11 រាជរដ្ឋាភិបាលកម្ពុជា (២០១៨) អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់ស្តង់ដារនីតិវិធីប្រតិបត្តិសម្រាប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ក្នុងព្រះរាជាណាចក្រកម្ពុជា។ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

12 ក្រសួងផែនការ (២០១២) អត្តសញ្ញាណកម្មគ្រួសារក្រីក្រប្រទេសកម្ពុជា។ លទ្ធផលនៃការប្រមូលទិន្នន័យជុំទី៤ (២០១០) និងជុំទី៥ (២០១១)។ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

13 តួលេខនេះលើកលែងខេត្តក្រុងចំនួន ៤ គឺរាជធានីភ្នំពេញ កំពង់ចាម កំពង់ធំ និងស្ទឹងត្រែង។

14 MoP (2016): Population Ageing in Cambodia – Current Situation and Needs. General Secretariat for Population and Development, Ministry of Planning. Phnom Penh, Cambodia

15 វិទ្យាស្ថានជាតិស្ថិតិ (២០១៣). របាយការណ៍ជំរឿនពាក់កណ្តាលអាណត្តិ។ ក្រសួងផែនការ។ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ប្រទេស ក្នុងចំណោមបណ្ដាខេត្តទាំងអស់ ខេត្តបាត់ដំបងមានជនពិការខ្ពស់ជាងគេដែលមាន ១០,៦៥ភាគរយ និងខេត្តកែបមានជនពិការតិចជាងគេត្រឹមតែ ០,២៣ភាគរយ។

### ២.៤.៤ ទារក និងកុមារ

អត្រាកំណើនកុមារមានការថយចុះចាប់ពីឆ្នាំ២០០៥ ដែលមាន ៣៧ភាគរយ មកនៅត្រឹម ៣១ភាគរយក្នុងឆ្នាំ២០១៦[16]។ បើទោះបីជាអត្រាកុមារមានការធ្លាក់ចុះ កុមារនៅតែជាក្រុមគោលដៅដែលងាយរងគ្រោះពីសកម្មភាពគម្រោងដែលចាំបាច់ត្រូវយកចិត្តទុកដាក់ឱ្យបានខ្ពស់។ រាល់ការដោះស្រាយនូវផលប៉ះពាល់នានាទៅលើការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តចាំបាច់ត្រូវមានការប្រុងប្រយ័ត្ន និងត្រូវកាត់បន្ថយហានិភ័យឱ្យបានទាបតាមដែលអាចធ្វើបានទៅលើកុមារ។

### ២.៤.៥ ស្ត្រីជាមេគ្រួសារដែលមានបន្ទុក

មិនមានតួលេខជាក់លាក់អំពីចំនួនស្ត្រីជាមេគ្រួសារ និងមេម៉ាយនៅតាមបណ្ដាខេត្ត និងប្រទេសកម្ពុជាទេ។ ស្ត្រីជាមេគ្រួសារ ឬមេម៉ាយត្រូវបានគេចាត់ទុកថាជាក្រុមជនដែលងាយរងគ្រោះក្នុងសង្គមដោយសារតែក្រុមនេះភាគច្រើនមានជីវភាពក្រីក្រ មានធនធានតិចតួចក្នុងការទប់ទល់នឹងវិបត្តិសង្គមនិងគ្រួសារ និងខ្វះការជួយជ្រោមជ្រែងពីគ្រួសារ និងសង្គម។ នៅពេលដែលធនធានរបស់ក្រុមនេះកំពុងតែខ្វះខាត ហើយស្របពេលដែលត្រូវទទួលរងនៅផលប៉ះពាល់ពីគម្រោងវិនិយោគនានា នោះកម្រិតជីវភាព និងស្ថានភាពរស់នៅនឹងត្រូវប្រឈមមុខយ៉ាងខ្លាំង។

### ២.៤.៦ ជនជាតិដើមភាគតិច

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ជនជាតិភាគតិចក្នុងប្រទេសកម្ពុជាជា ៣ក្រុមធំៗ គឺ ១) ក្រុមជនជាតិដើមភាគតិច (ដែលគេហៅថាខ្មែរលើ) ២) ក្រុមជនជាតិចាម ឬខ្មែរ-អ៊ីស្លាម និង ៣) ក្រុមអន្តោប្រវេសន៍ ឬក្រុមជនបរទេសស្នាក់នៅក្នុងប្រទេស (Parth & Narong, 2006)[17]។ របាយការណ៍ស្ដីពីជនជាតិដើមភាគតិចពិភពលោកឆ្នាំ២០១៩[18] ដែលបោះពុម្ពដោយក្រុមការងារអន្តរជាតិស្ដីពីកិច្ចការជនជាតិដើមភាគតិច (IWGIA) ដែលមានមូលដ្ឋាននៅក្នុងប្រទេសដាណឺម៉ាកបានលើកឡើងថាប្រទេសកម្ពុជាមានក្រុមជនជាតិដើមភាគតិចចំនួន ២៤ក្រុមផ្សេងៗគ្នា និងមានចំនួន ៤០០.០០០នាក់ (ប្រមាណពី២-៣ភាគរយនៃចំនួនប្រជាពលរដ្ឋសរុប)។ ដែនដីរបស់ជនជាតិដើមភាគតិចច្រើនតែនៅតាមតំបន់ដែលសម្បូរព្រៃឈើ និងតាមតំបន់ខ្ពង់រាប ហើយដែនដីរបស់ជនជាតិដើមភាគតិចទាំងនេះមានប្រមាណជា ២៥ភាគរយនៃផ្ទៃប្រទេសកម្ពុជាទាំងមូល។

ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជាមានចំនួន ២៤ក្រុមដែលក្នុងនោះរួមមាន ចារ៉ាយ ទំពួន ប្រៅ គ្រឹង លន់ ពូនង (ឬព្នង) ស្មៀង គួយនិងក្រុមផ្សេងៗទៀត ហើយមានភាសាជនជាតិដើមភាគតិចចំនួន ២៣ភាសាត្រូវបានប្រើប្រាស់ (Ian Bird, 2013)[19]។ ក្រុមជនជាតិដើមភាគតិចទាំងនេះមានវត្តមាននៅក្នុងខេត្តចំនួន ១២ ហើយភាគច្រើនពួកគេរស់នៅក្នុងខេត្តភាគឦសាន ពោលគឺក្នុងខេត្តក្រចេះ ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី (Laura M. Kirchner, 2015)[20]។

---

[16] Source: Statista (2019). Share of children in total population in Cambodia from 2005-2016, accessed through https://www.statista.com/statistics/678028/cambodia-children-as-a-percentage-of-the-population/, retrieved on 30 January 2019

[17] Parth & Narong (2006). *Draft of Assessment of the International Decade of the World's Indigenous Peoples (1995-2004) for Southeast Asia*, Phnom Penh, Cambodia.

[18] International Work Group for Indigenous Affairs (IWGIA) (2019). *The Indigenous World 2019*. Copenhagen, Denmark.

[19] Ian Bird (2013). Indigenous Peoples' and Land: Comparing communal land titling and its implications in Cambodia and Laos. *Asia Pacific Viewpoint*, Vol. 54, No. 3

[20] Laura M. Kirchner (2015). *Living on the margins: On the status and standing of minorities and indigenous peoples in Cambodia*. Heinrich Boll Stiftung Cambodia. http://bit.ly/1XFN911

ប្រជាពលរដ្ឋជនជាតិដើមភាគតិចច្រើនរស់នៅក្នុងតំបន់មួយចំនួនក្នុងប្រទេសកម្ពុជាដូចខាងក្រោម៖

តារាងទី៧៖ ប្រភេទ និងតំបន់នៃជនជាតិភាគតិចរស់នៅ

| ខេត្ត-ក្រុង | ក្រុមជនជាតិដើម | ខេត្ត-ក្រុង | ក្រុមជនជាតិដើម |
|---|---|---|---|
| រតនគិរី | ព្នង គ្រឹង ចារ៉ាយ ទំពួន ប្រៅ កាវែត កាចក់ លន់ | ឧត្តរមានជ័យ | កួយ ព្នង ទំពួន ចារ៉ាយ គ្រឹង ស្ទៀង កាវែត ក្រោល កាចក់ កេក |
| ក្រចេះ | ព្នង ក្រោល ស្ទៀង ធ្មូន កួយ មិល ខុង | កំពង់ចាម | ស្ទៀង |
| មណ្ឌលគិរី | ព្នង គ្រឹង ចារ៉ាយ ក្រោល ស្ទៀង ធ្មូន កួយ ទំពួន | ពោធិសាត់ | ព័រ ចុង |
| ព្រះវិហារ | កួយ ព័រ | កំពង់ស្ពឺ | សួយ |
| កំពង់ធំ | កួយ | បន្ទាយមានជ័យ | កួយ |
| ស្ទឹងត្រែង | ព្នង គ្រឹង ចារ៉ាយ កួយ ទំពួន | កោះកុង | ចុង |

ប្រភព៖ Laura M. Kirchner (2015)

ក្រុមប្រជាពលរដ្ឋទាំងនេះត្រូវបានគេចាត់ទុកថាជាក្រុមជនដែលងាយរងគ្រោះជាងគេពីសកម្មភាពនៃគម្រោងអភិវឌ្ឍន៍នានាដែលមាននៅក្នុងតំបន់មូលដ្ឋានរបស់ពួកគេ។ ដ្យាក្រាមខាងក្រោមសង្ខេបនូវរូបភាពខ្លីអំពីឥទ្ធិពលនៃគម្រោងទៅលើតំបន់ និងក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះ។ គម្រោងអភិវឌ្ឍន៍ភាគច្រើនត្រូវការប្រើប្រាស់នូវធនធានធម្មជាតិដូចជាដី ទឹក និងព្រៃឈើជាដើមដែលការប្រើប្រាស់ទាំងនេះអាចបង្កជាការខាត ហេតុប៉ះពាល់ទៅលើការតាំងទីលំនៅ និងការអាស្រ័យផលរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ ជាញឹកញាប់គេសង្កេតឃើញមានការបណ្តេញចេញ និងការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តពីទីតាំងអភិវឌ្ឍន៍ណាមួយ។ ស្ថានភាពទាំងនេះត្រូវតែធ្វើការចៀសវាងជាដាច់ខាតដោយមិនឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទៀតឡើយ។

ដ្យាក្រាមទី៥៖ ឥទ្ធិពលនៃគម្រោងអភិវឌ្ឍន៍ឯកជនទៅលើតំបន់ និងក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះ[21][22][23][24]




[21] រូបភាពព្រៃឈើមានប្រភពមកពី https://clipartion.com/free-clipart-24523/ ចូលទស្សនានិងថតចម្លងមកប្រើប្រាស់នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០

[22] រូបភាពប្រជាជនមានប្រភពមកពី https://www.freepik.com/free-photos-vectors/population ចូលទស្សនានិងថតចម្លងមកប្រើប្រាស់នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០

[23] រូបភាពជនពិការមានប្រភពមកពី https://www.freepik.com/free-icon/disabled_858830.htm ចូលទស្សនានិងថតចម្លងមកប្រើប្រាស់នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០

[24] រូបភាពជនជាតិដើមភាគតិចមានប្រភពមកពី https://eu.clipdealer.com/vector/media/A:15387277? ចូលទស្សនានិងថតចម្លងមកប្រើប្រាស់នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០

# ជំពូកទី៣



## បញ្ហាប្រឈម និងនីតិវិធីក្នុងការដោះស្រាយលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត

## ផ្នែកទី៣៖ បញ្ហាប្រឈម និងនីតិវិធីក្នុងការដោះស្រាយលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត

### ៣.១ សេចក្តីផ្តើម

*ផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត* គឺសំដៅទៅលើឥទ្ធិពលអាក្រក់ ឬផលប៉ះពាល់អវិជ្ជមានពីគម្រោងអភិវឌ្ឍន៍ ឬគម្រោងវិនិយោគនានាទៅលើការតាំងទីលំនៅដោយតម្រូវឱ្យមានការផ្លាស់ប្តូរទីលំនៅ-ដ្ឋានជារូបវន្តរបស់ប្រជាជនដោយមិនស្ម័គ្រចិត្តដែលត្រូវចាកចេញពីផ្ទះសម្បែង អាជីវកម្មរបស់ខ្លួន និងឬការកាន់កាប់ទ្រព្យសម្បត្តិទាំងឡាយមុនពេលគម្រោងត្រូវបានអនុវត្តន៍។ ផលប៉ះពាល់នេះផ្តោតទៅលើការខាតបង់ដោយផ្ទាល់ និងប្រយោលផ្នែកសេដ្ឋកិច្ច-សង្គម និងវប្បធម៌ ដែលប្រជាជនធ្លាប់ទទួលផល និងប្រតិបត្តិដោយស្របច្បាប់។

*អ្នកទទួលរងផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត៖* ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ គឺសំដៅលើអ្នកទាំងឡាយណាដែលត្រូវបានជម្លៀសដូចជា ការផ្លាស់ប្តូរទីលំនៅ ការបាត់បង់ដីលំនៅដ្ឋាន ឬការបាត់បង់ទីជម្រក និងឬការប៉ះពាល់ផ្នែកសេដ្ឋកិច្ចដូចជា ការបាត់បង់ដីធ្លី ទ្រព្យសម្បត្តិ ប្រភពចំណូល ឬក៏ជីវភាពរស់នៅដែលជាលទ្ធផលបណ្តាលមកពី (ក). ការទន្ទ្រានយកដីធ្លីដោយមិនស្ម័គ្រចិត្ត ឬ (ខ). ការហាមឃាត់លើការប្រើប្រាស់ដីដោយមិនស្ម័គ្រចិត្ត ឬទៅលើការចូលទៅកាន់តំបន់ឧទ្យានដែលបានកំណត់ ឬតំបន់ការពារស្របច្បាប់។ ក្នុងករណីនេះលំនៅដ្ឋានដែលទទួលរងផលប៉ះពាល់ត្រូវរួមបញ្ចូលសមាជិកទាំងអស់ដែលរស់នៅក្រោមដំបូលផ្ទះតែមួយ ហើយប្រកបរបរចិញ្ចឹមជីវិតតែមួយមុខដែលទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមានដោយគម្រោង ឬផ្នែកណាមួយរបស់គម្រោង។

*ផែនការដោះស្រាយផលប៉ះពាល់* (Resettlement Action Plan – RAP) គឺជារបាយការណ៍ដែលមានផែនការសកម្មភាពតាមពេលវេលាជាក់លាក់មួយជាមួយនឹងការរៀបចំថវិកា ការកំណត់នូវគោលបំណង និងយុទ្ធសាស្រ្តនៃការរុះរើលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត ការកំណត់សិទ្ធិទទួលបានសំណង សកម្មភាព និងការទទួលខុសត្រូវការត្រួតពិនិត្យការតាំងទីលំនៅឡើងវិញ និងការវាយតម្លៃនៃការតាំងទីលំនៅឡើងវិញជាដើម។ គោលបំណងនៃផែនការនេះសំខាន់គឺសំដៅធានាឱ្យប្រភពចិញ្ចឹមជីវិត និងកម្រិតជីវភាពរស់នៅរបស់ជនរងផលប៉ះពាល់ដោយសារគម្រោងយ៉ាងហោចណាស់មានស្ថានភាពប្រហាក់ប្រហែល ឬប្រសើរជាងស្ថានភាពមុនពេលមានគម្រោង។

និយមន័យខាងក្រោមនេះត្រូវបានដកស្រង់ចេញពីឯកសាររបស់ធនាគារពិភពលោក ឆ្នាំ២០១២[25]៖

- *ការផ្លាស់ទីលំនៅផ្នែកសេដ្ឋកិច្ច៖* គឺជាការបាត់បង់នូវដីធ្លី ទ្រព្យសម្បត្តិ សិទ្ធិក្នុងការទទួលបានការកាន់កាប់ទ្រព្យសម្បត្តិ ប្រភពប្រាក់ចំណូល ឬមធ្យោបាយនានាក្នុងការទ្រទ្រង់ជីវភាពដែលផលប៉ះពាល់ទាំងអស់នេះកើតឡើងពី (១). ការទិញដូរដីដោយមិនស្ម័គ្រចិត្ត (២). ការរឹតបន្តឹងដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដីធ្លី ឬលើការទទួលសិទ្ធិក្នុងការប្រើប្រាស់ដីឧទ្យាន និងតំបន់ការពារនានាដែលបានកំណត់។
- *ជនដែលត្រូវផ្លាស់ទីលំនៅ៖* នៅក្នុងបរិបទនៃការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ជនទាំងឡាយដែលត្រូវផ្លាស់ទីលំនៅ គឺជាជនដែលត្រូវផ្លាស់ទីជារូបវន្ត (ការផ្លាស់ប្តូរទីកន្លែង ការបាត់បង់ដីលំនៅដ្ឋាន ឬបាត់បង់ទីជម្រក) និងឬដែលត្រូវផ្លាស់ទីផ្នែកសេដ្ឋកិច្ច (ការបាត់បង់ដីធ្លី ទ្រព្យសម្បត្តិ សិទ្ធិក្នុងការកាន់កាប់ទ្រព្យសម្បត្តិ ប្រភពប្រាក់ចំណូល ឬមធ្យោបាយនានាក្នុងការទ្រទ្រង់ជីវភាព) ដែលផលប៉ះពាល់ទាំងអស់នេះកើតឡើងពី (១). ការទិញដូរដីដោយមិនស្ម័គ្រចិត្ត (២). ការរឹតបន្តឹងដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដីធ្លី ឬលើការទទួលសិទ្ធិក្នុងការប្រើប្រាស់ដីឧទ្យាន និងតំបន់ការពារនានាដែលបានកំណត់។

---

[25] ADB (2012). *Involuntary Resettlement Safeguards – A Planning and Implementation Good Practice Sourcebook*. Manila, the Philippines.

## ៣.២ ក្របខ័ណ្ឌគតិយុត្តដែលពាក់ព័ន្ធការងារគ្រប់គ្រង និងដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត

មានក្របខ័ណ្ឌគតិយុត្តជាច្រើន ដែលបម្រើដល់ការងារដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត។ ម្ចាស់គម្រោងត្រូវអនុវត្តតាមតម្រូវការ និងលក្ខខណ្ឌនានាដែលបានកំណត់រួច។ ក្របខ័ណ្ឌគតិយុត្តមួយចំនួនដូចខាងក្រោម៖

**៣.២.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ១៩៩៣** បានចែងថា " *សិទ្ធិរឹបអូសទ្រព្យសម្បត្តិពីជនណាម្នាក់នឹងត្រូវធ្វើឡើងសម្រាប់អត្ថប្រយោជន៍សាធារណៈ ដូចដែលបានចែងតាមផ្លូវច្បាប់ និងទាមទារឱ្យមានសំណងស្មើភាព និងយុត្តិធម៌ជាមុនសិន ( មាត្រា ៤៤)"*។ មាត្រា ២០ បានចែងថា *គ្មានជនណាម្នាក់នឹងត្រូវគេបង្ខំឱ្យផ្ទេរកម្មសិទ្ធរបស់ខ្លួន ប្រសិនបើការបង្ខំនោះ គឺពុំមានសារៈសំខាន់សម្រាប់សាធារណៈ និងប្រសិនបើគ្មានសំណងណាមួយសមរម្យសម្រាប់ម្ចាស់កម្មសិទ្ធិនោះទេ។*

**៣.២.២ ច្បាប់ភូមិបាលឆ្នាំ ២០០១** (នស/រកម/០៨០១/១៤ ចុះខែសីហា ឆ្នាំ២០០១) គឺគ្រប់គ្រងសិទ្ធិកាន់កាប់ដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងប្រទេសកម្ពុជា។ ដោយផ្អែកលើបទប្បញ្ញត្តិរបស់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ច្បាប់នេះបានកំណត់អំពីភាពជាម្ចាស់នៃអចលនទ្រព្យដែលត្រូវបានគេកំណត់ថាជា ដីធ្លី ដើមឈើ និងសំណង់ដែលនៅមួយ កន្លែង។ ដូចគ្នានេះដែរ មាត្រា៣០ បានចែងថា " *ជនណាដែលរស់នៅលើដីនោះដោយសន្តិភាព និងគ្មានការប្រឆាំងតវ៉ាក្នុងរយៈពេល ៥ឆ្នាំ ឬរស់នៅលើដីនោះមុនពេលដែលច្បាប់នេះត្រូវបានគេអនុម័តក្នុងឆ្នាំ២០០១ អាចចាត់ទុកថាជាម្ចាស់ស្របច្បាប់[26]"* ។ លើសពីនេះទៅទៀត សិទ្ធិ និងទំនួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយគោរពតាមសិទ្ធិនៃការកាន់កាប់ ត្រូវបានកំណត់នៅក្នុងច្បាប់ភូមិបាល។ រាជរដ្ឋាភិបាលកម្ពុជាអាចរឹបអូសយកដីឯកជនសម្រាប់ជាប្រយោជន៍សាធារណៈនៅក្នុងលក្ខខណ្ឌ (១). សំណងស្មើភាព និងយុត្តិធម៌ (២). ប្រាក់សំណងត្រូវប្រគល់ជូនជាមុន។ ច្បាប់ភូមិបាលមាត្រា ៥ បានកំណត់ថា៖

> " *គ្មានជនណាម្នាក់អាចត្រូវគេដកហូតសិទ្ធិជាម្ចាស់របស់ខ្លួនបានទេ ប្រសិនបើករណីនេះមិនមែនជាប្រយោជន៍សាធារណៈ។ ការដកហូតសិទ្ធជាម្ចាស់នឹងត្រូវគេធ្វើឡើង ដោយយោងទៅតាមទម្រង់ និងនីតិវិធីដែលបានផ្តល់ឱ្យដោយច្បាប់ និងបទប្បញ្ញត្តិ ហើយបន្ទាប់ពីផ្តល់ប្រាក់សំណងឱ្យបានស្មើភាព និងយុត្តិធម៌ជាមុនសិន។"*

**៣.២.៣ អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច** ត្រូវបានពង្រឹងចាប់តាំងពីឆ្នាំ២០០៥ ដើម្បីបង្កើតនីតិវិធី ការរៀបចំស្ថាប័នសម្រាប់ផ្តួចផ្តើម និងផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មីៗ និងសម្រាប់ត្រួតពិនិត្យកិច្ចការងារនោះ។ រាជរដ្ឋាភិបាលមានសិទ្ធិផ្តល់ដីរដ្ឋ និងឯកជនឱ្យទៅជាដីសម្បទានសេដ្ឋកិច្ចសម្រាប់អ្នកស្នើសុំដីសម្បទានប្រើប្រាស់ក្នុងគោលបំណងកសិកម្ម ឬកសិ-ឧស្សាហកម្ម។ អនុក្រឹត្យនេះធានាថានឹងគ្មានការតាំងទីលំនៅឡើងវិញដោយពុំស្ម័គ្រចិត្តណាមួយដែលធ្វើឡើងដោយអ្នកទទួលបានដីស្របច្បាប់នោះទេ (មាត្រា ៤)។ អនុក្រឹត្យនេះក៏ទាមទារឱ្យមានកិច្ចប្រឹក្សាយោបល់ជាសាធារណៈជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋក្នុងតំបន់ មុនពេលផ្តល់អាជ្ញាប័ណ្ណដីសម្បទានសេដ្ឋកិច្ច។

---

[26] ដើម្បីអាចអះអាងជាម្ចាស់កម្មសិទ្ធស្របច្បាប់លើដី អ្នកកាន់កាប់ត្រូវមាន ១) ភស្តុតាងនៃការកាន់កាប់ (ឧ. លិខិតទិញ/ដូរ) ២) ភស្តុតាងទទួលមរតកពីឪពុកម្តាយ ៣) សៀវភៅគ្រួសារ ៤) សាក្សីជាមនុស្សឬអ្នកជិតខាងដែលអះអាង និងធានាអំពីការកាន់កាប់ និង៥) ភស្តុតាងនៃការប្រើប្រាស់ដីសម្រាប់លំនៅដ្ឋាន ឬធ្វើដំណាំ (ឧ. មានដើមដូង ខ្នុរ និងស្វាយជាដើម...)។

**៣.២.៤ អនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ** (លេខ៩៨ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥) មានបំណងគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍអាងទន្លេឱ្យមានប្រសិទ្ធភាព និងនិរន្តភាពដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនីតិវិធីនៃការរៀបចំ និងការអនុវត្តផែនការនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ អាងទន្លេរង ទឹកលើទីជម្រាល ទឹកក្រោមដី និងល្អាងទឹកក្រោមដី។ មាត្រា៨ បានចែងថាចម្ងាយពីមាត់ទន្លេ និងឆ្នេរនៅតាមដងទន្លេធម្មជាតិ និងសំណង់ទឹក នៅតំបន់ជនបទនឹងទទួលបានការការពារ ហើយមិនអនុញ្ញាតឱ្យមានការកាន់កាប់ស្របច្បាប់ណាមួយនោះទេ។

**៣.២.៥ អនុក្រឹត្យលេខ១៩៧ អនក្រ.បក ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិ និងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា** (ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩) មានគោលដៅកំណត់ការគ្រប់គ្រង និងការប្រើប្រាស់ដីចំណីតាមបណ្តាញផ្លូវជាតិ និងផ្លូវរថភ្លើងឱ្យសមស្របតាមការអភិវឌ្ឍ និងការរីកចម្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់ទៅលើផ្លូវជាតិមានលេខ១ (មួយ) ខ្ទង់ ផ្លូវជាតិមានលេខ ២ (ពីរ) ខ្ទង់ ព្រមទាំងផ្លូវរថភ្លើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ អនុក្រឹត្យនោះមានគោលបំណង (១) លុបបំបាត់បាតុភាពទន្ទ្រានយកដីចំណីទៅធ្វើការសាងសង់សំណង់ ឬដាំដំណាំផ្សេងៗ, (២) ទប់ស្កាត់ឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ និងរក្សាសណ្តាប់ធ្នាប់សង្គមដែលតែងកើតមាននៅតាមបណ្តាញផ្លូវ, (៣) កាត់បន្ថយឧបសគ្គនានាដែលរាំងស្ទះដល់ការអភិវឌ្ឍផ្លូវ, (៤) កាត់បន្ថយរាល់ការចំណាយរបស់រដ្ឋលើការដោះស្រាយផលប៉ះពាល់ផ្ទះសម្បែងប្រជាពលរដ្ឋដែលតាំងនៅតាមបណ្តាញផ្លូវ, (៥) បង្កលក្ខណៈងាយស្រួលដល់សមត្ថកិច្ចពាក់ព័ន្ធក្នុងការផ្តល់ភាពស្របច្បាប់ដល់ប្រជាពលរដ្ឋដែលមានកម្មសិទ្ធិនៅតាមបណ្តាញផ្លូវ, (៦) ធានាការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តប្រកបដោយនិរន្តភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**៣.២.៦ អនុក្រឹត្យលេខ២២ អនក្រ.បក ស្តីពីការដាក់ឱ្យប្រើប្រាស់ស្តង់ដានីតិវិធីប្រតិបត្តិសម្រាប់ការដោះស្រាយផលប៉ះពាល់ ដោយសារគម្រោងអភិវឌ្ឍន៍ដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ក្នុងព្រះរាជាណាចក្រកម្ពុជា** ត្រូវប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨។ ស្តង់ដារនីតិវិធីប្រតិបត្តិនេះត្រូវអនុវត្តចំពោះគម្រោងអភិវឌ្ឍន៍ដែលទទួលបានហិរញ្ញ-ប្បទានពីដៃគូអភិវឌ្ឍន៍ក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃស្តង់ដារនីតិវិធីប្រតិបត្តិនេះគឺបង្កើននូវការយល់ដឹង និងកំណត់ជាឯកសារ ឬគោលការណ៍គោលសម្រាប់ការធ្វើផែនការ និងអនុវត្តន៍ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ដែលកាតព្វកិច្ចនេះមានសារៈសំខាន់ណាស់នៅពេលដែលគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានធ្វើផែនការ និងអនុវត្តន៍ក្រោមការគាំទ្រហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។ ស្តង់ដារនីតិវិធីប្រតិបត្តិនេះនឹងជួយធានាថារាល់បញ្ហានានានៃគោលការណ៍សុវត្ថិភាពដែលពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មដីធ្លី និងការតាំងទីលំនៅត្រូវបានដោះស្រាយដោយតម្លាភាព សមស្រប និងមានលក្ខណៈយុត្តិធម៌ដែលស្របតាមបទដ្ឋានគតិយុត្តនៃច្បាប់ជាតិ និងគោលនយោបាយសុវត្ថិភាពនិងនីតិវិធីរបស់ដៃគូអភិវឌ្ឍន៍សម្រាប់ជាប្រយោជន៍ផ្នែកសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជា។

**៣.២.៧ សារាចរណ៍ណែនាំលេខ ០១ សរណន ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ បានបញ្ជាក់ថាដីចំណីឆ្នេរសមុទ្រជាដីសាធារណៈរបស់រដ្ឋ (លើកលែងតែមានការកាន់កាប់ស្របច្បាប់)។ ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រត្រូវកំណត់យ៉ាងតិច ៥០ (ហាសិប) ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក ប៉ុន្តែក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។ មិនអាចអនុញ្ញាតឱ្យមាន

សំណង់រឹងមាំនៅលើដីចំណីឆ្នេរសមុទ្រ លើកលែងតែសំណង់នោះត្រូវសាងសង់ឡើងក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ និងទេសចរណ៍។ សារាចរក៏បានតម្រូវឱ្យមាននូវការសិក្សា និងវាយតម្លៃហេតុប៉ះពាល់បរិស្ថានឱ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេសនូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានាដូចជាសំណង់រោងចក្រឧស្សាហកម្ម រោងជាង និងស្ថានីយផ្សេងៗជាដើមដែលអាចមានកម្រិតបញ្ចេញផ្សែងពុលខ្ពស់ទៅក្នុងបរិយាកាស និងបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង។

**៣.២.៨ សារាចរលេខ ០២ ស្តីពីការកាន់កាប់ដីរបស់រដ្ឋខុសច្បាប់** ដែលចេញដោយរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ បានចែងថានៅពេលដែលការកាន់កាប់ដីជាទម្រង់កម្មសិទ្ធិត្រូវបានគេចាត់ទុកថាខុសច្បាប់ បន្ទាប់ពីថ្ងៃ៣០ ខែសីហា ឆ្នាំ២០០១ នោះរដ្ឋចាំបាច់ផ្តល់ដីសម្បទានសង្គមសម្រាប់ប្រជាជនក្រីក្រ និងប្រជាជនខ្វះខាត ដើម្បីបំពេញតម្រូវការរបស់ខ្លួន នៅខណៈពេលដែលមានកំណើនប្រជាជនខ្ពស់ ការរំសាយកងទ័ព និងការបាត់បង់ដីធ្លីដោយសារគ្រោះថ្នាក់ធម្មជាតិ។ ដើម្បីដោះស្រាយស្ថានភាពនេះសារាចរលេខ ០២ បានកំណត់ថា៖

*ក. ជាទូទៅ អ្នកកាន់កាប់ដីរបស់រដ្ឋខុសច្បាប់ ជាពិសេសឈ្មួញរកស៊ីទិញដី ពុំមានសិទ្ធិទទួលបាននូវប្រាក់សំណងនោះទេ (កថាខណ្ឌទី៦.១ ក្នុងប្រកាសលេខ ០២)។*
*ខ. អ្នកកាន់កាប់ដីរបស់រដ្ឋខុសច្បាប់ ដែលជាគ្រួសារក្រីក្រ និងគ្មានដីធ្លី ឬខ្វះដី នឹងពុំមានសិទ្ធិទទួលបាននូវប្រាក់សំណង ប៉ុន្តែអាចទទួលបាននូវទំហំដីសមស្របសម្រាប់ការចិញ្ចឹមជីវភាពរបស់ពួកគេ (កថាខណ្ឌទី៦.២ ក្នុងប្រកាសលេខ ០២)។*
*គ. សម្រាប់ដីឯកជនរបស់រដ្ឋ គេអាចប្រើប្រាស់សម្រាប់ការលក់ដូរ ជួល អំណោយ សិទ្ធិអាស្រ័យផល ដីសម្បទានសង្គម ដីសម្បទានសេដ្ឋកិច្ច ឬអនុញ្ញាតឱ្យប្រើប្រាស់។ ការសម្រេចចិត្តអំពីជម្រើសជាក់លាក់ត្រូវតែផ្អែកលើការសម្របសម្រួលរវាងអាជ្ញាធរដែនដី អាជ្ញាធរទទួលការទុកចិត្តដីរដ្ឋ និងបុគ្គលដែលប្រើប្រាស់ដី និងដោយផ្អែកលើផែនការប្រើប្រាស់ដី (កថាខណ្ឌទី៧.១ ក្នុងប្រកាសលេខ ០២)។*

**៣.២.៩ សារាចរលេខ ០៣ ស្តីពីដំណោះស្រាយលំនៅដ្ឋានបណ្តោះអាសន្ននៅលើដីរបស់រដ្ឋដែលកាន់កាប់នៅរាជធានី និងតំបន់ទីក្រុង** ដែលបានសម្រេចឱ្យប្រើប្រាស់នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ មានគោលបំណងផ្តល់នូវនីតិវិធីផ្លូវការសម្រាប់ដោះស្រាយដីលំនៅដ្ឋានបណ្តោះអាសន្នដែលមានស្រាប់នៅលើដីរបស់រដ្ឋដែលកាន់កាប់ដោយខុសច្បាប់។ ដើម្បីដោះស្រាយបញ្ហាតាំងទីលំនៅខុសច្បាប់ សារាចរនេះបានណែនាំអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធឱ្យចាត់វិធានការដូចខាងក្រោម៖

ក. ប្រមូលទិន្នន័យអំពីចំនួនទីកន្លែងតាំងទីលំនៅបណ្តោះអាសន្ន
ខ. កំណត់ ធ្វើផែនទី និងចាត់ចំណាត់ថ្នាក់ប្រភេទដីសម្រាប់ការតាំងទីលំនៅបណ្តោះអាសន្ន
គ. ធ្វើជំរឿនអំពីចំនួនសមាជិកគ្រួសារនៅក្នុងតំបន់តាំងទីលំនៅបណ្តោះអាសន្ន
ឃ. ជម្រើសនៃការដោះស្រាយ
ង. ពិភាក្សាអំពីការសម្របសម្រួលក្នុងការបង្កើតគោលនយោបាយ
ច. ផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធសាមញ្ញ និងការគាំទ្រសេវាកម្មសាធារណៈ
ឆ. ការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍ

**៣.២.១០ សារាចរលេខ ០០៦ ស្តីពីនីតិវិធីអនុវត្តការទារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នានា** ត្រូវប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤។

សារាចរនេះមានគោលបំណងធានាឱ្យបាននូវការអនុវត្តការងារដោះស្រាយផលប៉ះពាល់ ដោយសារគម្រោងអភិវឌ្ឍន៍នីមួយៗប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ចៀសវាងបាននូវផលប៉ះពាល់ផ្នែកសតិអារម្មណ៍បន្ថែមលើផលប៉ះពាល់ផ្នែកទ្រព្យសម្បត្តិដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ ចៀសវាងបាននូវការរាំងស្ទះដល់ការងារវិស្វកម្មសម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ និងដើម្បីទទួលបានការគាំទ្រពេញលេញពីប្រជាពលរដ្ឋទូទៅ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំនូវនីតិវិធីអនុវត្តការងារតាមដំណាក់កាលគម្រោងដូចជា ១). ដំណាក់កាលសិក្សាពីសមិទ្ធិលទ្ធភាពនៃគម្រោងអភិវឌ្ឍន៍ ២). ដំណាក់កាលអនុវត្តផែនការដោះស្រាយផលប៉ះពាល់ និង ៣). ដំណាក់កាលក្រោយការអនុវត្តផែនការដោះស្រាយផលប៉ះពាល់

**៣.២.១១ ប្រកាសលេខ ០៦ ស្តីពី "វិធានការបង្ក្រាបការរំលោភ និងការទន្ទ្រានយកដីដោយអនាធិបតេយ្យ" ឆ្នាំ២០១០** បានកំណត់បញ្ហាដីចំណីផ្លូវ។ នៅក្នុងការគាំទ្រសេចក្តីប្រកាសនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០០០ បានចេញអនុក្រឹត្យលេខ ៩៦១ ដែលរាំងការផ្តល់ប្រាក់សំណងសម្រាប់សំណង់ និងទ្រព្យសម្បត្តិដទៃទៀតដែលស្ថិតនៅលើដីចំណីផ្លូវ។ អនុក្រឹត្យមួយទៀតលេខ ១៩៧ ស្តីអំពីដីចំណីផ្លូវ និងដីចំណីផ្លូវរថភ្លើងដែលរៀបចំដោយក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៩។

## ៣.៣ គោលការណ៍អន្តរជាតិស្តីអំពីការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត

### ៣.៣.១ ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank)

ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ហិរញ្ញប្បទាន ឬជំនួយសម្រាប់គម្រោងផ្សេងៗគ្នាជាច្រើនដែលអាចជួយនាំទៅរកការកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃជីវិតរស់នៅ។ ក្រៅពីនេះ ធនាគារអភិវឌ្ឍន៍អាស៊ីក៏ផ្តល់នូវជំនួយបច្ចេកទេស និងការផ្តល់អនុសាសន៍នានាសម្រាប់រដ្ឋាភិបាលផងដែរ។ សកម្មភាពជំនួយបែបនេះមានដូចជាការជួយរដ្ឋាភិបាលក្នុងការរៀបចំនិងអនុវត្តគម្រោង ការបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាល ការធ្វើការសិក្សាស្រាវជ្រាវ និងការប្រមូលព័ត៌មាន ឬការជួយដល់ការតាក់តែងគោលនយោបាយ និងច្បាប់នានា។ ឧទាហរណ៍ជាក់ស្តែង រដ្ឋាភិបាលកម្ពុជាបានទទួលជំនួយបច្ចេកទេសក្នុងការរៀបចំ និងព្រាងច្បាប់ភូមិបាលឆ្នាំ២០០១ជាដើម[27] ។

គោលនយោបាយប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានគោលនយោបាយការពារចំនួនបី៖ ១). គោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (ឆ្នាំ១៩៩៥) ២). គោលនយោបាយស្តីពីបរិស្ថាន (ឆ្នាំ២០០២) និង ៣). គោលនយោបាយស្តីពីក្រុមជនជាតិដើមភាគតិច (ឆ្នាំ១៩៩៨)។ កម្មវត្ថុនៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីរួមមាន៖

- ចៀសវាងផលប៉ះពាល់អវិជ្ជមានរបស់គម្រោងចំពោះបរិស្ថាន និងក្រុមមនុស្សរងផលប៉ះពាល់ប្រសិនបើអាច
- បន្ធូរបន្ថយ កាត់បន្ថយ ឬប៉ះប៉ូវសងនូវផលប៉ះពាល់អវិជ្ជមានរបស់គម្រោងចំពោះបរិស្ថាន និងក្រុមមនុស្សរងផលប៉ះពាល់ ប្រសិនបើការបញ្ចៀសមិនអាចធ្វើទៅបាន
- ជួយអ្នកខ្ចី ឬអតិថិជនពង្រឹងប្រព័ន្ធការពាររបស់ពួកគេ និងអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងហានិភ័យសង្គម និងបរិស្ថាន

ធនាគារអភិវឌ្ឍន៍អាស៊ីគោរពតាមកម្មវត្ថុនៃគោលនយោបាយការពារ និងការអនុវត្តគោលនយោបាយទាំងនេះ ហើយទទួលខុសត្រូវក្នុងការៀបចំអង្កេតលម្អិត និងវាយតម្លៃ អង្កេតតាមដាន និងត្រួតពិនិត្យគម្រោងនៅគ្រប់

[27] សៀវភៅគោលការណ៍ណែនាំសម្រាប់សហគមន៍ស្តីអំពីគោលការណ៍ការពារលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ បោះពុម្ពដោយអង្គការ Bridges Across Borders Cambodia ឆ្នាំ២០១១។

ដំណាក់កាលនៃវដ្តគម្រោងស្របតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដូចដែលមានចែងក្នុងសេចក្តីថ្លែងគោលការណ៍ការពារ (SPS)។

គោលការណ៍ការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវបានរៀបចំលើកដំបូងនៅក្នុងឆ្នាំ១៩៩៥ និងបានកែសម្រួលជាចុងក្រោយ និងផ្លូវការនៅឆ្នាំ២០០៩ដែលក្នុងនោះក៏រួមមាននូវគោលការណ៍ការពារស្តីអំពីការតាំងលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (Involuntary Resettlement Safeguard)។ គោលបំណងចម្បងរបស់គោលការណ៍នេះមាន ១). ព្យាយាមបញ្ចៀសនូវការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តប្រសិនបើអាចធ្វើទៅបាន ២). កាត់បន្ថយការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តតាមរយៈការសិក្សារកមើលជម្រើសគម្រោង និងការរៀបចំប្លង់ផ្សេងៗទៀត និង ៣). លើកស្ទួយ (ឬយ៉ាងហោចណាស់) ការចិញ្ចឹមជីវិតរបស់មនុស្សដែលត្រូវផ្លាស់ទីលំនៅឱ្យបានក្នុងកម្រិតមួយប្រហាក់ប្រហែលនឹងកម្រិតនៅមុនពេលមានគម្រោងអភិវឌ្ឍន៍ និងលើកកម្ពស់នូវកម្រិតជីវភាពរស់នៅរបស់ជនក្រីក្ររងផលប៉ះពាល់ និងក្រុមងាយគ្រោះផ្សេងៗទៀត។

គោលការណ៍នេះតម្រូវឱ្យអ្នកខ្ចី ឬអតិថិជនត្រូវបំពេញ ដើម្បីផ្តល់នូវការការពារក្នុងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តចំពោះគម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ លក្ខខណ្ឌតម្រូវនេះពិភាក្សាពីកម្មវត្ថុទំហំនៃការអនុវត្ត និងគូសបញ្ជាក់ពីលក្ខខណ្ឌតម្រូវក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់សង្គម និងការរៀបចំផែនការតាំងទីលំនៅជាថ្មី ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់សង្គម និងឯកសាររៀបចំផែនការតាំងទីលំនៅជាថ្មី សិក្សាអំពីការចរចាធ្វើលទ្ធកម្មដី ការផ្សព្វផ្សាយព័ត៌មាន និងការពិគ្រោះយោបល់ ការបង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ា និងការតាមដាននិងការរាយការណ៍ពីការតាំងទីលំនៅជាថ្មី។ គោលការណ៍នេះតម្រូវឱ្យអ្នកខ្ចី ឬអតិថិជនត្រូវបំពេញនូវលក្ខខណ្ឌតម្រូវមួយចំនួនអំពី៖

- ការទូទាត់សង ជំនួយ និងអត្ថប្រយោជន៍សម្រាប់អ្នកបាត់បង់លំនៅដ្ឋាន
- ការវាយតម្លៃផលប៉ះពាល់សង្គម
- ការរៀបចំផែនការតាំងទីលំនៅជាថ្មី
- ការទទួលបានដីធ្លីតាមរយៈការចរចា
- ការផ្តល់ព័ត៌មាន
- ការពិគ្រោះយោបល់ និងការចូលរួម
- យន្តការដោះស្រាយបណ្តឹងតវ៉ា
- ការអង្កេតតាមដាន និងការរាយការណ៍
- ផលប៉ះពាល់ដែលមិនមានគិតទុកមុន
- ការគិតគូរជាពិសេសចំពោះក្រុមជនជាតិដើមភាគតិច

**ការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត៖** គោលនយោបាយការពារស្តីពីការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត មានគោលបំណងចៀសវាងការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តតាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តតាមរយៈការសិក្សា និងការរចនាជម្រើសសម្រាប់គម្រោង ឬយ៉ាងហោចណាស់ដើម្បីបង្កើន ឬស្តារជីវភាពរបស់អ្នកដែលត្រូវផ្លាស់ទីលំនៅឱ្យដូចទៅនឹងការកម្រិត និងស្ថានភាពមុនពេលមានវត្តមានគម្រោង និងដើម្បីកែលម្អជីវភាពរស់នៅរបស់ជនក្រីក្រ និងក្រុមងាយរងគ្រោះដែលត្រូវផ្លាស់ទីលំនៅ។ គោលនយោបាយនេះគ្របដណ្តប់លើការផ្លាស់ប្តូរជាលក្ខណៈរូបវន្ត (ផ្លាស់ប្តូរទីលំនៅ ការបាត់បង់ដីធ្លីលំនៅ-ដ្ឋាន ឬការបាត់បង់ទីជម្រក) និងការផ្លាស់សេដ្ឋកិច្ច (ការបាត់បង់នៃដី ទ្រព្យសម្បត្តិ លទ្ធភាពប្រើប្រាស់ទ្រព្យសម្បត្តិ ប្រភពចំណូល ឬមធ្យោបាយចិញ្ចឹមជីវិត) ដែលជាលទ្ធផលនៃ (ក). លទ្ធកម្មដីធ្លីដោយមិនស្ម័គ្រចិត្ត ឬ (ខ). ការរឹតបន្តឹងលើការប្រើប្រាស់ដីធ្លីដោយមិនស្ម័គ្រចិត្ត ឬការរឹតបន្តឹងលើការចូលទៅកាន់កាប់តំបន់ឧទ្យានជាតិ

និងតំបន់ការពារនានាដែលត្រូវបានកំណត់ដោយច្បាប់។ គោលនយោបាយនេះក៏គិតគូរផងដែរ ថាតើការខាតបង់បែបនេះ និងការរឹតបណ្តឹងដោយមិនស្ម័គ្រចិត្តទាំងនោះ គឺមានលក្ខណៈពេញលេញទាំងមូល ឬដោយផ្នែកៗ ឬជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន។ ក្នុងនាមជាអ្នកផ្តល់ហិរញ្ញប្បទាន ធនាគារអភិវឌ្ឍន៍អាស៊ីនឹងសម្រិតសម្រាំងគម្រោងទាំងអស់ដើម្បីកំណត់ថា តើវាមានពាក់ព័ន្ធនឹងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តដែរឬទេ។ សម្រាប់គម្រោងដែលពាក់ព័ន្ធនឹងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅឡើងវិញមួយនឹងត្រូវបានរៀបចំសមស្របដោយផ្អែកទៅលើវិសាលភាព និងកម្រិតនៃផលប៉ះពាល់នេះ។ កម្រិតនៃផលប៉ះពាល់ត្រូវកំណត់ដោយ (ក). វិសាលភាពនៃការផ្លាស់ប្តូរលក្ខណៈរូបវ័ន្ត និងផ្នែកសេដ្ឋកិច្ច និង (ខ). ភាពងាយរងគ្រោះរបស់អ្នកដែលរងផលប៉ះពាល់ (ADB, 2009)[28]។

**ក្រុមងាយរងគ្រោះ៖** ជាញឹកញាប់ ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តបានផ្តល់នូវឱកាសដើម្បីណែនាំវិធានការក្នុងពង្រឹងស្ថានភាពសេដ្ឋកិច្ច និងសង្គមនៃក្រុមងាយរងគ្រោះ ជាជាងគ្រាន់តែការស្តារឡើងវិញនូវភាពងាយរងគ្រោះនៅកម្រិតមុនពេលមានវត្តមានគម្រោង។ គោលនយោបាយរបស់ធនាគារបានទទួលស្គាល់យ៉ាងជាក់លាក់ និងបានបញ្ជាក់ថាការយកចិត្តទុកដាក់ជាពិសេសផ្តោតលើតម្រូវការរបស់ជនដែលក្រីក្របំផុត គ្រួសារមានស្ត្រីជាមេគ្រួសារ ជនជាតិដើមភាគតិច និងក្រុមមនុស្សផ្សេងៗទៀតក្នុងសង្គម (ADB ,1998)។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងសម្រិតសម្រាំងគម្រោងទាំងអស់ដើម្បីកំណត់ថា តើមានផលប៉ះពាល់ខ្លាំងកម្រិតណាទៅលើជនជាតិដើមភាគតិច។ សម្រាប់គម្រោងដែលមានផលប៉ះពាល់មកលើជនជាតិដើមភាគតិច ផែនការជនជាតិដើមភាគតិចនឹងត្រូវបានរៀបចំឡើង។ កម្រិតលម្អិតនៃផែនការ និងភាពទូលំទូលាយត្រូវផ្អែកទៅលើកម្រិតនៃផលប៉ះពាល់ផងដែរ។ កម្រិតនៃផលប៉ះពាល់នេះត្រូវបានកំណត់ដោយការវាយតម្លៃ (ក). ទំហំនៃផលប៉ះពាល់លើសិទ្ធជាប្រពៃណីរបស់ជនជាតិដើមទៅលើការប្រើប្រាស់និងការទទួលបានដី និងធនធានធម្មជាតិប៉ះពាល់ទៅលើស្ថានភាពសេដ្ឋកិច្ចសង្គម វប្បធម៌ និងបូរណភាពរបស់សហគមន៍ សុខភាព ការអប់រំ ប្រព័ន្ធចិញ្ចឹមជីវិត និងស្ថានភាពសន្តិសុខសង្គម ឬចំណេះដឹងនៅតាមតំបន់មូលដ្ឋាន និង (ខ). ភាពងាយរងគ្រោះរបស់ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ (ADB, 2009)[29]។

**ការផ្តល់សំណង៖** ជាតុសំខាន់ៗនៃសេចក្តីថ្លែងគោលការណ៍សុវត្ថិភាព (SPS) ឆ្នាំ២០០៩ របស់ធនាគារអភិវឌ្ឍន៍អាស៊ីលើការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តគឺ (ក). ការសងសំណងជំនួសទ្រព្យសម្បត្តិដែលបាត់បង់ សម្រាប់ការចិញ្ចឹមជីវិត និងសម្រាប់ប្រាក់ចំណូលដែលបាត់បង់ (ខ). ការផ្តល់ជំនួយសម្រាប់ការផ្លាស់ទីលំនៅឡើងវិញ រួមបញ្ចូលទាំងការផ្តល់ទីតាំងថ្មីជាមួយសម្ភារៈបរិក្ខារ និងសេវាកម្មសមរម្យ និង (គ). ការផ្តល់ជំនួយសម្រាប់ការស្តារឡើងវិញដើម្បីសម្រេចបានយ៉ាងហោចណាស់នូវស្ថានភាព ឬកម្រិតដូចគ្នានៃសុខុមាលភាពដូចពេលដែលគ្មានគម្រោង។ ជាតុមួយចំនួន ឬទាំងអស់នៃសេចក្តីថ្លែងនេះ អាចមានវត្តមានប្រើប្រាស់នៅក្នុងគម្រោងដែលពាក់ព័ន្ធនឹងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត (Vo & Brereton, 2014)។ មិនមានការពិភាក្សាអំពីការទូទាត់សំណងជាសាច់ប្រាក់នៅក្នុងគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ទោះជាយ៉ាងណា ការអនុវត្តរបស់ធនាគារមិនបានលើកទឹកចិត្តជាសំណងសាច់ប្រាក់សម្រាប់ដីធ្លី លើកលែងតែក្នុងករណីដែលផលប៉ះពាល់មានកម្រិតតែប៉ុណ្ណោះ ដូចជាដីដែលទាមទារសម្រាប់ធ្វើជាចំណីផ្លូវដែលមិនគំរាមកំហែងដល់ជីវភាពរស់នៅ។ ដីជំនួស " ការបន្ថែមទឹកប្រាក់ " ឬសាច់ប្រាក់បន្ថែមដើម្បីទិញដី ការបង្កើតការងារ ហើយជាញឹកញាប់មានសមាសភាពបញ្ចូលគ្នានៃជម្រើសនានាត្រូវបានអនុវត្តនៅក្នុងគម្រោងជាច្រើន។ ប្រជាជនរងផលប៉ះពាល់គួរត្រូវបានផ្តល់ជូនជម្រើសច្រើនក្នុងការជ្រើសរើសដើម្បីស្តារជីវភាពរស់នៅរបស់ពួកគេ។

---

[28] ADB. (2009). *Safeguard Policy Statement*. The Asian Development Bank. The Philippines.
[29] (ibid, 2009)

**យន្តការដោះស្រាយបណ្តឹងតវ៉ា៖** ធនាគារអភិវឌ្ឍន៍អាស៊ីបានតម្រូវថាអ្នកខ្ចីប្រាក់ ឬអតិថិជនបង្កើត និងរក្សានូវយន្តការដោះស្រាយបណ្តឹងមួយដើម្បីទទួល និងសម្របសម្រួលដំណោះស្រាយសម្រាប់ការព្រួយបារម្ភ និងការតវ៉ារបស់ប្រជាជនរងផលប៉ះពាល់អំពីការអនុវត្តទៅលើបរិស្ថាន និងសង្គមនៅកម្រិតគម្រោងរបស់អ្នកខ្ចីប្រាក់ ឬអតិថិជន។ យន្តការដោះស្រាយបណ្តឹងគួរតែត្រូវបានធ្វើមាត្រដ្ឋានទៅតាមទំហំហានិភ័យ និងផលប៉ះពាល់របស់គម្រោង។ យន្តការនេះគួរតែដោះស្រាយការព្រួយបារម្ភ និងបណ្តឹងរបស់ប្រជាជនរងផលប៉ះពាល់បានភ្លាមៗ ដោយប្រើប្រាស់ដំណើរការដែលងាយយល់ និងមានតម្លាភាព ហើយដែលអាចឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ បញ្ហាវប្បធម៌ និងដែលអាចចូលរួមបានពីគ្រប់ស្រទាប់ទាំងអស់នៃប្រជាជនរងផលប៉ះពាល់។ អ្នកខ្ចីប្រាក់ នឹងប្រើប្រាស់វិធានការ ឬនីតិវិធី ដោះស្រាយបណ្តឹងដែលមានស្រាប់។ នៅពេលដែលពុំមាននីតិវិធី ឬមានគម្លាតរវាងគោលនយោបាយរបស់ប្រទេសម្ចាស់ផ្ទះ និងធនាគារអភិវឌ្ឍន៍អាស៊ី ពួកគេនឹងបង្កើតឱ្យមានវិធានការដាក់លាក់ដែលអនុលោមតាមគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB, 2009)។

ប្រជាជនដែលរងផលប៉ះពាល់ពីគម្រោង អាចដាក់ពាក្យបណ្តឹងទៅកាន់យន្តការគណនេយ្យភាព (Accountability Mechanism) របស់ធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។ យន្តការគណនេយ្យភាពនេះបានផ្តល់នូវវេទិកាឯករាជ្យ និងដំណើរការមួយដែលប្រជាជនរងផលប៉ះពាល់ដោយគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ ADB អាចបញ្ចេញ និងស្វែងរកដំណោះស្រាយលើបញ្ហារបស់ពួកគាត់ ព្រមទាំងរាយការណ៍អំពីការរំលោភបំពានទៅលើគោលនយោបាយនិងនីតិវិធីប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ យន្តការគណនេយ្យភាពនេះមានដំណាក់កាលពីរដាច់ដោយឡែកតែទាក់ទងគ្នាគឺ៖ (១). ដំណាក់កាលពិគ្រោះយោបល់៖ ដឹកនាំដោយអ្នកសម្របសម្រួលគម្រោងពិសេសរបស់ ADB ដែលបានរាយការណ៍ដោយផ្ទាល់ទៅប្រធានធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីជួយដល់ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោងក្នុងការស្វែងរកដំណោះស្រាយសម្រាប់បញ្ហារបស់ពួកគាត់ និង (២). ដំណាក់កាលពិនិត្យលើការអនុវត្តតាម ដែលដឹកនាំដោយគណៈកម្មការដែលមានសមាជិកបីនាក់ដែលរាយការណ៍ទៅក្រុមប្រឹក្សាភិបាលរបស់ធនាគារ។ គណៈកម្មការពិនិត្យលើការអនុវត្តស៊ើបអង្កេតការរំលោភបំពានលើគោលនយោបាយ និងនីតិវិធីប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលត្រូវបានចោទប្រកាន់ដូចដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល រួមបញ្ចូលទាំងគោលនយោបាយសុវត្ថិភាពដែលបានបណ្តាល ឬទំនងជាបង្កឱ្យមានគ្រោះថ្នាក់អវិជ្ជមានដោយផ្ទាល់ទៅលើប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងផ្តល់អនុសាសន៍អំពីវិធីសាស្រ្តក្នុងអនុវត្តតាមគោលនយោបាយ និងនីតិវិធីរបស់ ADB (ADB, 2009)។

### ៣.៣.២ ធនាគារពិភពលោក (World Bank)

ធនាគារពិភពលោក គឺជាទីភ្នាក់ងារមួយក្នុងចំណោមទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដំបូងបង្អស់ក្នុងការបង្កើតគោលនយោបាយតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។ សៀវភៅគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិលេខ ២.៣៣ ត្រូវបានពង្រាងឡើងដំបូងក្នុងឆ្នាំ១៩៨០ ហើយចាប់តាំងពីពេលនោះមក គោលនយោបាយនេះត្រូវបានកែលម្អជាច្រើនលើកច្រើនសារនៅឆ្នាំ១៩៨៦, ១៩៨៨, ១៩៩០ និងចុងក្រោយបំផុតនៅក្នុងឆ្នាំ២០០១ នៅពេលដែលវាត្រូវបានគេស្គាល់ថាជាគោលនយោបាយប្រតិបត្តិលេខ ៤.១២ (Vo & Brereton, 2014)[30]។ គោលនយោបាយប្រតិបត្តិលេខ ៤.១២ នេះបានផ្តល់ឱ្យអ្នកអនុវត្តន៍ដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅឡើងវិញ រួមបញ្ចូលទាំងធនាគារខ្លួនឯងផ្ទាល់ ភ្នាក់ងារម្ចាស់ជំនួយផ្សេងទៀត អ្នកខ្ចីប្រាក់ (រដ្ឋាភិបាល) អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកទីប្រឹក្សា និងអ្នកដទៃទៀតនូវការណែនាំស្តីពីការអនុវត្តគោលការណ៍គោលនយោបាយ តម្រូវការនីតិវិធីសម្រាប់គម្រោង

[30] Vo, M. & Brereton, D. (2014). *Involuntary Resettlement in the Extractive Industries: Some lessons from a Vietnamese Mining Project.* The University of Queensland.

ទិដ្ឋភាពបច្ចេកទេសនៃការធ្វើផែនការតាំងទីលំនៅ និងការអនុវត្តជាក់ស្តែងក្នុងការដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅឡើងវិញ (World Bank, 2004)[31]។

គោលនយោបាយប្រតិបត្តិលេខ ៤.១២ នេះមានគោលបំណងដើម្បីចៀសវាងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តទៅតាមវិសាលភាពអាចធ្វើបាន ឬដើម្បីកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ច និងសង្គមអវិជ្ជមានរបស់វា។ គោលនយោបាយនេះជំរុញឱ្យមានការចូលរួមរបស់ជនដែលរងផលប៉ះពាល់ ឬដែលត្រូវផ្លាស់ទីលំនៅក្នុងការកសាងផែនការ និងអនុវត្តន៍ការដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅឡើងវិញ។ គោលបំណងផ្នែកសេដ្ឋកិច្ចសំខាន់របស់គោលនយោបាយនេះ គឺដើម្បីជួយអ្នកដែលត្រូវផ្លាស់ទីលំនៅក្នុងកិច្ចប្រឹងប្រែងរបស់ពួកគេដើម្បីធ្វើឱ្យប្រាក់ចំណូល និងស្តង់ដារសនៅកាន់តែប្រសើរឡើងបន្ទាប់ពីការផ្លាស់ទីលំនៅ។ គោលនយោបាយណែនាំនេះបានរៀបរាប់អំពីវិធានការសងសំណង និងវិធានការដោះស្រាយផលប៉ះពាល់ពីការតាំងទីលំនៅឡើងវិញ ដើម្បីសម្រេចឱ្យបាននូវតាមគោលបំណង និងតម្រូវថាអ្នកខ្ចីប្រាក់រៀបចំជាមុននូវឧបករណ៍គ្រប់គ្រាន់ក្នុងការធ្វើផែនការដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅឡើងវិញ មុនពេលការវាយតម្លៃរបស់ធនាគារទៅលើគម្រោងដែលបានស្នើឡើង (World Bank, 2001)។

**ការតាំងទីលំនៅដ្ឋានឡើងវិញ៖** គោលការណ៍នេះត្រូវបានអនុវត្តទៅលើសមាសភាគទាំងអស់នៃគម្រោង ដែលអាចបណ្តាលឱ្យកើតមានផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានឡើងវិញដោយមិនស្ម័គ្រចិត្ត ដោយមិនគិតពីប្រភពនៃការផ្តល់ហិរញ្ញប្បទាននោះទេ។ គោលការណ៍ត្រូវបានអនុវត្តទៅលើសកម្មភាពផ្សេងៗទៀតដែលបណ្តាលឱ្យកើតមានផលប៉ះពាល់លើការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ដែលស្ថិតនៅក្នុងក្រោមការវិនិច្ឆ័យរបស់ធនាគារ។ នៅក្នុងគម្រោងដែលពាក់ព័ន្ធនឹងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត អ្នកខ្ចីប្រាក់ ឬអតិថិជនត្រូវបានទាមទារឱ្យរៀបចំនីតិវិធី ឬក្របខ័ណ្ឌក្នុងការដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅឡើងវិញដោយមានការចូលរួមពីអ្នកដែលផ្លាស់ប្តូរលំនៅ ក្នុងអំឡុងពេលការរចនា និងការអនុវត្តគម្រោង។ ភាគីអ្នកខ្ចី គឺជាអ្នកទទួលខុសត្រូវសម្រាប់ការអនុវត្ត និងត្រួតពិនិត្យផែនការដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅឡើងវិញ (World Bank, 2004)[32]។

**ក្រុមងាយរងគ្រោះ៖** សម្រាប់លទ្ធកម្មដីធ្លី និងលទ្ធភាពទទួលបាននូវធនធានមានកម្រិត គោលនយោបាយតម្រូវឱ្យមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធ ជាមួយប្រជាជនរងផលប៉ះពាល់ទៅលើវិធានការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដោយផ្តល់ការយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហារបស់ជនជាតិភាគតិច បញ្ហាយេនឌ័រ និងបញ្ហារបស់ក្រុមងាយរងគ្រោះ។ គោលនយោបាយនេះបានលើកឡើងជាពិសេសអំពីបញ្ហាសំខាន់ៗមួយចំនួនរបស់ជនជាតិដើមភាគតិចដែលអាចនឹងកើតមានឡើង។ បទពិសោធរបស់ធនាគារ បានបង្ហាញឱ្យឃើញថាការដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅឡើងវិញរបស់ជនជាតិដើមភាគតិច ដែលមានរបៀបរបបចិញ្ចឹមជីវិតតាមបែបប្រពៃណីដោយពឹងផ្អែកលើដីសម្រាប់ការផលិត នោះគឺជាការស្មុគស្មាញជាពិសេស និងអាចមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងលើអត្តសញ្ញាណ និងវប្បធម៌របស់ពួកគេ។ ចំពោះហេតុផលនេះ ធនាគារបំពេញតម្រូវការរបស់ខ្លួន ដែលថាអ្នកខ្ចីប្រាក់ចាំបាច់ត្រូវតែសិក្សាជម្រើសនានារបស់គម្រោងដែលមានទាំងអស់ ដើម្បីចៀសវាងការផ្លាស់ប្តូរទីលំនៅដែលមានលក្ខណៈរូបវន្តរបស់ក្រុមទាំងនេះ។ នៅពេលដែលការផ្លាស់ទីលំនៅបែបនេះមិនអាចចៀសវាងធ្វើទៅបាន អាទិភាពត្រូវតែធ្វើឡើងជាយុទ្ធសាស្ត្រសម្រាប់ការតាំងទីលំនៅដ្ឋានឡើងវិញដែលផ្អែកលើការបែង

[31] World Bank (2004). Involuntary Resettlement Sourcebook. Planning and Implementation in Development Projects. The International Bank for Reconstruction and Development/The World Bank, Washington DC.

[32] World Bank (2004). *Involuntary Resettlement Sourcebook. Planning and Implementation in Development Projects*. The International Bank for Reconstruction and Development/The World Bank, Washington DC.

ចែកដី និងទីតាំងដែលត្រូវគ្នាជាមួយចំណង់ចំណូលចិត្ត និងរបៀបរបបរស់នៅរបស់ពួកគាត់ដោយមានការរៀបចំពិគ្រោះយោបល់ដោយពេញលេញ (World Bank, 2001)។

**ការផ្ដល់សំណង៖** បើយោងតាមគោលនយោបាយប្រតិបត្តិលេខ ៤.១២ ផែនការតាំងទីលំនៅឡើងវិញផ្ដល់នូវ "សំណងឆាប់រហ័ស និងមានប្រសិទ្ធភាពដោយផ្អែកលើថ្លៃជំនួសពេញលេញសម្រាប់ការខាតបង់ទ្រព្យសម្បត្តិដែលបណ្ដាលមកពីគម្រោងដោយផ្ទាល់"។ សម្រាប់គ្រួសារដែលចិញ្ចឹមជីវិតដោយសារការប្រកបការងារកសិកម្មលើដីហើយបាត់បង់មួយផ្នែកនៃការកាន់កាប់របស់ពួកគាត់ គោលនយោបាយរបស់ធនាគារផ្ដល់អាទិភាពទៅលើយុទ្ធសាស្ត្រដោះដូរដីជាមូលដ្ឋាន។ " យុទ្ធសាស្ត្រទាំងនេះអាចរួមបញ្ចូលទាំងការតាំងទីលំនៅឡើងវិញនៅលើដីសាធារណៈ ឬលើដីឯកជនដែលត្រូវបានដកហូត ឬទិញដូរសម្រាប់ការតាំងទីលំនៅឡើងវិញ " (World Bank, 2001)។

ការទូទាត់សំណងជាសាច់ប្រាក់ប្រហែលជាការសមរម្យ "នៅពេលដែល (ក). ជីវភាពរស់នៅដោយពឹងផ្អែកទៅលើការបង្កបង្កើនផលលើដី ប៉ុន្តែដីនេះត្រូវបានយកសម្រាប់គម្រោងនេះគឺជាមួយផ្នែកតូចនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ ហើយផ្នែកដែលនៅសល់ គឺមានសារៈសំខាន់ផ្នែកសេដ្ឋកិច្ច (ខ). ដី លំនៅដ្ឋាន ឬកម្លាំងពលកម្មមានទីផ្សារច្រើន ដូច្នេះជនដែលផ្លាស់ប្ដូរទីលំនៅបានប្រើប្រាស់ទីផ្សារបែបនេះ ហើយមានការផ្គត់ផ្គង់គ្រប់គ្រាន់នៃដីធ្លី និងលំនៅដ្ឋាន ឬ (គ). ការចិញ្ចឹមជីវិតមិនពឹងផ្អែកលើដី។ កម្រិតនៃការសងសំណងជាសាច់ប្រាក់ត្រូវតែមានបរិមាណគ្រប់គ្រាន់ដើម្បីជំនួសដី និងទ្រព្យសម្បត្តិផ្សេងទៀតដែលបានបាត់បង់នៅថ្លៃជំនួសពេញលេញនៅក្នុងទីផ្សារក្នុងស្រុក"។ បន្ថែមពីលើការទូទាត់សាច់ប្រាក់សម្រាប់ដី និងទ្រព្យសម្បត្តិផ្សេងទៀតដែលបាត់បង់ ជម្រើសក្នុងការដោះស្រាយជាមួយនិងការចិញ្ចឹមជីវិតដែលពឹងលើដី គួរតែរួមបញ្ចូលនូវឱកាសសម្រាប់ការងារ និងការប្រកបអាជីវកម្មដោយខ្លួនឯង នៅពេលដែលបទប្បញ្ញត្តិក្នុងប្រទេសមិនបានបំពេញតាមស្តង់ដារនៃការសងសំណងនៅថ្លៃជំនួសពេញលេញ។ ការសងសំណងតាមបទប្បញ្ញត្តិក្នុងប្រទេសត្រូវតែបំពេញបន្ថែមដោយចាត់វិធានការចាំបាច់ដើម្បីបំពេញតាមស្តង់ដារថ្លៃជំនួស" (World Bank, 2004)[33]។

**យន្តការដោះស្រាយបណ្ដឹងតវ៉ា៖** នៅក្រោមគោលនយោបាយប្រតិបត្តិលេខ ៤.១២ អ្នកខ្ចីប្រាក់ទទួលខុសត្រូវចំពោះបណ្ដឹងសារទុក្ខ ដែលទាក់ទងនឹងគម្រោង។ យន្តការបណ្ដឹងត្រូវតែមានការបញ្ជាក់ឱ្យបានជាក់លាក់នូវនីតិវិធីសម្រាប់ការដោះស្រាយការតាំងទីលំនៅឡើងវិញ និងសំណងដែលតម្រូវឱ្យមានការពិគ្រោះយោបល់ពេញលេញជាមួយនិងប្រជាពលរដ្ឋ និងសហគមន៍រងផលប៉ះពាល់ អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល (World Bank, 2001)។

### ៣.៣.៣ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Financial Corporation)

នៅឆ្នាំ២០០៦ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិដែលជាសមាជិករបស់ក្រុមធនាគារពិភពលោក បានអនុម័តនូវបទដ្ឋានស្តង់ដារអនុវត្តន៍ (Performance Standard - PS) ស្ដីពីនិរន្តភាពបរិស្ថាន និងសង្គម សម្រាប់វិស័យឯកជនដែលបានទទួលថវិកាពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC, 2009)[34]។ នៅក្នុងការចាប់ផ្ដើម បទដ្ឋាននេះត្រូវបានគេចាត់ទុកថាជាគោលការណ៍ណែនាំដែលមានការជម្រុញលើកទឹកចិត្តខ្លាំង និងត្រូវបានគេចាត់ទុកជាគោលដៅអន្តរជាតិសម្រាប់គម្រោងវិស័យឯកជន (Nazari, 2010)[35]។ ទោះយ៉ាងណាក៏ដោយ នៅក្នុងបរិបទដែលសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិបានក្លាយទៅជាអ្នកផ្ដល់ប្រាក់កម្ចីមួយ បទដ្ឋាននេះលែងជាគោលអន្តរជាតិសម្រាប់សម្រាប់ការ

[33] (Ibid, World Bank, 2004)
[34] IFC (2009). *Good Practices Note on Addressing Grievances from Project-Affected Communities – Guidance for Projects and Companies on Designing Grievance Mechanisms*. International Finance Corporation. Washington, USA
[35] Nazari, M. (2010). *IFC Performance Standards: Lessons Learned*. Environment and Communities.

អនុវត្តល្អទៀតហើយ ប៉ុន្តែវាបានក្លាយទៅជាបទដ្ឋានដែលចាំបាច់ត្រូវតែអនុវត្តន៍តាម ហើយឥលូវវាបានក្លាយទៅប្រតិបត្តិជាឧបករណ៍គ្រប់គ្រងហានិភ័យសម្រាប់គម្រោង ដែលផ្តល់មូលនិធិដោយ IFC។ បទដ្ឋានរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិនេះត្រូវបានគេឃើញផងដែរថាជាការបទដ្ឋានសកលមួយដែរ។

**ការតាំងទីលំនៅដ្ឋានឡើងវិញ៖** សម្រាប់គោលបំណងបច្ចុប្បន្ននេះ បទដ្ឋានសំខាន់នៃតាំងទីលំនៅដ្ឋានឡើងវិញដោយមិនស្ម័គ្រចិត្តរបស់ IFC គឺបទដ្ឋានស្តង់ដារអនុវត្តន៍ទី ៥ (PS5) ស្តីពីលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត (PS5) ដែលជំនួសគោលនយោបាយការពាររបស់ធនាគារពិភពលោក បើទាក់ទងនឹងវិស័យឯកជន។ បទដ្ឋានស្តង់ដារអនុវត្តន៍ PS5 ដោះស្រាយហានិភ័យនៃការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ដែលបណ្តាលមកពីគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ IFC។ បទដ្ឋាននេះគ្របដណ្តប់ទាំងពីរ គឺការផ្លាស់ប្តូរលំនៅរូបវន្ត (ផ្លាស់ប្តូរទីលំនៅ ឬការបាត់បង់ទីជម្រក ឬដី) និងការផ្លាស់ប្តូរសេដ្ឋកិច្ច (ការបាត់បង់ទ្រព្យសម្បត្តិ ឬលទ្ធភាពប្រើប្រាស់ទ្រព្យសម្បត្តិដែលនាំឱ្យមានការបាត់បង់ប្រភពប្រាក់ចំណូល ឬមធ្យោបាយផ្សេងទៀតក្នុងការទ្រទ្រង់ជីវភាពរស់នៅ) ដែលបណ្តាលមកពីលទ្ធកម្ម ឬការដកហូតដីធ្លីដែលទាក់ទងទៅនឹងគម្រោង ឬការរឹតបន្តឹងទៅលើលទ្ធភាពនៃការប្រើប្រាស់ដី (IFC, 2012)[36]។ បទដ្ឋាននេះបានតម្រូវឱ្យអតិថិជនចៀសវាង ឬយ៉ាងហោចណាស់កាត់បន្ថយផលប៉ះពាល់ល់ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត នៅពេលណាដែលអាចធ្វើទៅបានដោយពិចារណាលើជម្រើសនានាក្នុងការរចនាគម្រោង។ ករណីដែលការតាំងទីលំនៅដ្ឋានឡើងវិញមិនអាចចៀសវាងបាន អតិថិជនត្រូវបានទាមទារឱ្យផ្តល់នូវឱកាសសម្រាប់អ្នកតាំងទីលំនៅឡើងវិញនិងសហគមន៍របស់ពួកគេដើម្បីទាញយកផលប្រយោជន៍អភិវឌ្ឍន៍ត្រឹមត្រូវពីគម្រោងនេះ។ លើសពីនេះទៀត ផលវិបាកសង្គម និងសេដ្ឋកិច្ចអវិជ្ជមានត្រូវតែបន្ធូរបន្ថយដើម្បីកែលម្អ (ឬយ៉ាងហោចណាស់ស្តារ) ជីវភាពរស់នៅរបស់ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង (IFC, 2012)[37]។

នៅដែលទំនងជាមានការផ្លាស់ទីលំនៅអាចកើតឡើង បទដ្ឋានស្តង់ដារអនុវត្តន៍ PS5 តម្រូវឱ្យមានផែនការសកម្មភាពដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានឡើងវិញ (RAP) ដើម្បីដោះស្រាយសំណងការបង្កើតរៀបចំតំបន់តាំងទីលំនៅឡើងវិញ លំនៅដ្ឋានសងជំនួសគ្រប់គ្រាន់ និងជំនួយផ្សេងៗសម្រាប់ការតាំងទីលំនៅឡើងវិញ។ ក្នុងករណីដែលគម្រោងពាក់ព័ន្ធតែនឹងការផ្លាស់ប្តូរសេដ្ឋកិច្ច ផែនការស្តារជីវភាពឡើងវិញ (Livelihood Restoration Plan) គឺត្រូវបានទាមទារឱ្យធ្វើឡើងដើម្បីទូទាត់សំណងដល់ប្រជាជន និងសហគមន៍រងផលប៉ះពាល់។ ផែនការនេះរួមបញ្ចូលទាំងបទប្បញ្ញត្តិសម្រាប់ការសងសំណងដល់ជនរងគ្រោះផ្នែកសេដ្ឋកិច្ច និងសំណងទៅលើជំនួសលើទ្រព្យសម្បត្តិ និងជំនួយផ្នែកសេដ្ឋកិច្ច (ឧទាហរណ៍ ឥណទាន ការបណ្តុះបណ្តាល ឬឱកាសការងារ)។ ទោះបីជាយ៉ាងណា ដើម្បីជួយកុំឱ្យមានការដកហូត និងលុបបំបាត់នូវការចាំបាច់ក្នុងការប្រើសិទ្ធអំណាចរបស់រដ្ឋាភិបាលដើម្បីអនុវត្តន៍ការផ្លាស់ប្តូរទីលំនៅ អតិថិជនត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ដំណោះស្រាយដោយការចរចាដែលត្រូវតាមតម្រូវការរបស់បទដ្ឋាននេះ បើទោះបីជាពួកគេមានមធ្យោបាយនិងលទ្ធភាពស្របច្បាប់ដើម្បីទទួលបាន ឬដកហូតដីដោយគ្មានការយល់ព្រមរបស់អ្នកលក់ក៏ដោយ (IFC, 2012)[38]។

មានការអត្ថាធិប្បាយ និងការរិះគន់ជាច្រើនអំពីភាពគ្រប់គ្រាន់ និងភាពពាក់ព័ន្ធនៃបទដ្ឋានរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ឆ្នាំ២០០៦ (HIC, 2006[39]; IFC, 2009[40], 2010[41]; JACSES, 2009[42]; Nazari, 2010[43])។ ជា

[36] IFC. (2012). *Performance Standard 5 on Land Acquisition and Involuntary Resettlement.* The International Financial Corporation.
[37] (Ibid, IFC, 2012)
[38] (Ibid, IFC, 2012)
[39] HIC. (2006). *One step forward, one step back: An analysis of the International Financial Corporation's sustainability policy, performance standards and disclosure policy.* Ottawa, Canada: Halifax Initiative Coalition.
[40] IFC (2009). *Good Practices Note on Addressing Grievances from Project-Affected Communities – Guidance for Projects and Companies on Designing Grievance Mechanisms.* International Financial Corporation. Washington, USA

ការឆ្លើយតប បទដ្ឋានស្តង់ដារអនុវត្តន៍ PS5 ត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០១១ ដើម្បីបញ្ចូលបទពិសោធន៍និងមេរៀនរបស់ IFC និងមតិយោបល់ពីភាគីជំនាញៗខាងក្នុង និងខាងក្រៅ។ បទដ្ឋានដែលត្រូវបានកែលម្អនេះ ត្រូវបានគេដាក់ឱ្យប្រើប្រាស់ឡើងវិញនៅដើមឆ្នាំ២០១២។

បទដ្ឋានស្តង់ដារអនុវត្តន៍ PS5 ដែលបានកែលម្អ រួមបញ្ចូលសំណុំនៃតម្រូវការមួយចំនួនដែលមានរៀបរាប់នូវការទទួលខុសត្រូវរបស់អ្នកអភិវឌ្ឍន៍គម្រោង ដែលរដ្ឋាភិបាលមានតួនាទីផ្លូវការនៃដំណើរដោះស្រាយលើការតាំងទីលំនៅឡើងវិញ។ បើយោងតាមបទដ្ឋាននេះ ស្ថិតក្រោមការគ្រប់គ្រងការដោះស្រាយលើការតាំងទីលំនៅឡើងវិញរបស់រដ្ឋាភិបាល វិស័យឯកជនត្រូវបានគេរំពឹងថានឹងសហការជាមួយភ្នាក់ងាររបស់រដ្ឋាភិបាលទៅលើ "កម្រិតដែលបានអនុញ្ញាត" ដើម្បីធានាថាការធ្វើផែនការ និងការអនុវត្តការដោះស្រាយការតាំងទីលំនៅឡើងវិញ គឺស្របជាមួយនឹងបទដ្ឋាននេះ។ លើសពីនេះទៀត អ្នកអភិវឌ្ឍន៍គម្រោងត្រូវបានគេតម្រូវឱ្យដើរតួនាទីយ៉ាងសកម្មបន្ថែមទៀត និងចូលរួមពិភាក្សានៅក្នុងដំណើរការលទ្ធកម្មដី និងការតាំងទីលំនៅឡើងវិញ ជាពិសេសនៅពេលដែលសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលនៅមានកម្រិត។ ខណៈពេលដែលការទទួលស្គាល់ថាអ្នកវិនិយោគទុននឹងត្រូវបានគេរឹតបណ្តឹងលើសមត្ថភាពក្នុងការដាក់ឥទ្ធិពលទៅលើលទ្ធផលនៃការធ្វើផែនការ បទដ្ឋានស្តង់ដារអនុវត្តន៍ PS 5 ដែលបានកែលម្អនេះ បានសង្កត់ធ្ងន់លើការទទួលខុសត្រូវរបស់អ្នកអភិវឌ្ឍន៍គម្រោងក្នុងគិតគូរទៅលើតម្រូវការធនធាន តម្រូវការការធ្វើផែនការ និងហានិភ័យនៃគម្រោងទៅលើប្រជាជនដែលនឹងត្រូវផ្លាស់ទីលំនៅ (Vo & Brereton, 2014)[44]។ បទពិសោធន៍នានា បានបង្ហាញឱ្យឃើញថាការចូលរួមដោយផ្ទាល់របស់អ្នកខ្ចីប្រាក់នៅក្នុងសកម្មភាពដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅឡើងវិញ អាចបណ្តាលឱ្យការអនុវត្តសកម្មភាពប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងទាន់ពេលវេលា ក៏ដូចជាការអនុវត្តនូវវិធីសាស្ត្របែបច្នៃប្រឌិតថ្មីៗក្នុងការកែលម្អជីវភាពរស់នៅរបស់អ្នកដែលរងផលប៉ះពាល់ដោយការតាំងទីលំនៅឡើងវិញនេះ (IFC, 2012)[45]។

**ការផ្តល់សំណង៖** អតិថិជននឹងពិចារណាការរចនាលើជម្រើសនានាដែលអាចធ្វើទៅបានសម្រាប់គម្រោងដើម្បីចៀសវាង ឬកាត់បន្ថយការផ្លាស់ប្តូរជារូបវន្ត និងឬផលប៉ះពាល់លើសេដ្ឋកិច្ច ក្នុងខណៈពេលអតិថិជនព្យាយាមរក្សាតុល្យភាពនៃការបាត់បង់ និងផលប្រយោជន៍ផ្នែកបរិស្ថាន សង្គម និងហិរញ្ញវត្ថុ ដោយយកចិត្តទុកដាក់ជាពិសេសទៅលើផលប៉ះពាល់លើជនក្រីក្រ និងក្រុមងាយរងគ្រោះ។ នៅពេលការផ្លាស់ប្តូរលំនៅមិនអាចចៀសវាងបាន អតិថិជននឹងផ្តល់ជូនប្រជាជន និងសហគមន៍ដែលរងផលប៉ះពាល់នូវសំណងសម្រាប់ការខាតបង់ទ្រព្យសម្បត្តិក្នុងថ្លៃជំនួសពេញលេញ និងជំនួយផ្សេងទៀតដើម្បីជួយឱ្យពួកគេមានលទ្ធភាពធ្វើឱ្យប្រសើរឡើង ឬស្តារនូវស្តង់ដារនៃការរស់នៅរបស់ពួកគេ។ ស្តង់ដារនៃសំណងនឹងត្រូវមានតម្លាភាព និងត្រូវបានអនុវត្តន៍ដូចៗគ្នាជាមួយសហគមន៍ និងអ្នកទាំងអស់ដែលរងផលប៉ះពាល់ដោយការផ្លាស់ទីលំនៅ។ នៅពេលដែលជីវភាពរបស់ជនផ្លាស់ទីលំនៅពឹងផ្អែកលើការបង្កបង្កើនផលពីដី ឬនៅតាមទីតាំងដែលដីត្រូវបានកាន់កាប់ដោយសមូហភាព អតិថិជននឹងផ្តល់ជូននូវសំណងជាដី ប្រសិនជាអាចធ្វើទៅបាន។ អតិថិជនអាចកាន់កាប់ដី និងទ្រព្យសម្បត្តិដែលបានលទ្ធកម្មរួច បន្ទាប់ពីការទូទាត់សំណងត្រូវបានធ្វើឡើង និងនៅពេលដែលទីតាំងសម្រាប់ការតាំងទីលំនៅឡើងវិញ និងជំនួយផ្លាស់ទីត្រូវបានរៀបចំនិងចាត់ចែងរួចរាល់ បន្ថែមពីលើសំណងដែលបានផ្តល់ជូនខាងដើម។ អតិថិជននឹងផ្តល់ឱកាសដល់សហគមន៍និងអ្នកដែលត្រូវ

---

[41] IFC. (2010). *Progress Report on IFC's Policy and Performance Standards on Social and Environmental Sustainability, and Access to Information Policy:* Review and Update Process: International Financial Corporation.

[42] JACSES. (2009). *Recommendations to International Financial Corporation (IFC) on Policy and Performance Standards on Social & Environmental Sustainability, and Policy on Disclosure of Information.* Japan Center for a Sustainable Environment and Society. Tokyo, Japan.

[43] Nazari, M. (2010). *IFC Performance Standards: Lessons Learned.* Environment and Communities.

[44] Vo, M. & Brereton, D. (2014). *Involuntary Resettlement in the Extractive Industries: Some lessons from a Vietnamese Mining Project.* The University of Queensland.

[45] IFC. (2012). Performance Standard 5 on Land Acquisition and Involuntary Resettlement. The International Finance Corporation.

បានផ្លាស់ទីលំនៅ ដើម្បីទាញយកផលប្រយោជន៍សមស្របពីគម្រោងអភិវឌ្ឍន៍ (IFC, 2012)[46]។ ក្នុងបទដ្ឋានរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិនាពេលបច្ចុប្បន្ននេះ អតិថិជន ឬវិនិយោគិន ត្រូវបានលើកទឹកចិត្តក្នុងការសហការជាមួយភ្នាក់ងាររដ្ឋាភិបាលនៅក្នុងផ្នែកគន្លឹះមួយចំនួនរួមមាន៖ (ក). ការបង្កើតនូវវិធីសាស្ត្រក្នុងការកំណត់ និងការផ្តល់សំណងគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ (ខ). ការចែកចាយនៃការទូទាត់សំណង និង (គ). ការរចនា និងការអនុវត្តកម្មវិធីតាមដានត្រួតពិនិត្យ (Vo & Brereton, 2014)[47]។

ការផ្លាស់ប្តូរទីលំនៅដែលបណ្តាលមកពីគម្រោង ត្រូវបានចែកជាពីរប្រភេទ គឺផ្នែករូបវ័ន្ត និងផ្នែកសេដ្ឋកិច្ច។ ជនផ្លាស់ប្តូរទីលំនៅបែបរូបវ័ន្តត្រូវបានផ្តល់ជូននូវជម្រើសក្នុងចំណោមជម្រើសការតាំងទីលំនៅឡើងដែលអាចធ្វើទៅបានរួមមាន (ក). សាងសង់លំនៅដ្ឋានជំនួស ឬសំណងជាសាច់ប្រាក់ដែលសមស្រប និង (ខ). ផ្តល់ជំនួយផ្លាស់ប្តូរទីលំនៅទៅនឹងតម្រូវការនៃក្រុមនីមួយៗដែលរងផលប៉ះពាល់។ ម្យ៉ាងទៀត ការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ចដែលបណ្តាលឱ្យមានការបាត់បង់ទ្រព្យសម្បត្តិ និងឬមធ្យោបាយនៃការកសាងជីវភាពរស់នៅ គឺត្រូវបានទាមទារឱ្យផ្តល់សំណងនូវថ្លៃជំនួសពេញលេញ ដោយអាស្រ័យលើករណីជាក់លាក់នៃជន ឬក្រុមដែលត្រូវផ្លាស់ប្តូរទីលំនៅ។ បន្ថែមទៅលើសំណងសម្រាប់ការបាត់បង់ទ្រព្យសម្បត្តិ អ្នកដែលផ្លាស់ប្តូរទីលំនៅត្រូវបានផ្តល់ជូនផងដែរនូវឱកាសដើម្បីបង្កើន ឬយ៉ាងហោចណាស់ស្តារមធ្យោបាយនៃសមត្ថភាពរកប្រាក់ចំណូលរបស់ពួកគាត់ កម្រិតនៃការផលិតកម្ម និងស្តង់ដារនៃការរស់នៅជាដើម (IFC, 2012)[48]។

**យន្តការដោះស្រាយបណ្តឹងតវ៉ា៖** ទាក់ទងទៅនឹងពាក្យបណ្តឹងសារទុក្ខ អតិថិជននឹងបង្កើតយន្តការបណ្តឹងមួយស្របជាមួយបទដ្ឋានស្តង់ដារទី១ (PS1) ឱ្យបានលឿនតាមដែលអាចធ្វើបាននៅក្នុងដំណាក់កាលអភិវឌ្ឍន៍គម្រោង។ យន្តការបណ្តឹងគួរតែត្រូវបានធ្វើឱ្យស្របទៅនឹងហានិភ័យ និងផលប៉ះពាល់អវិជ្ជមាននៃគម្រោង និងសម្រាប់ប្រជាជនឬសហគមន៍រងផលប៉ះពាល់ដែលជាអ្នកនឹងប្រើប្រាស់នូវយន្តការជាចម្បង។ យន្តការនេះគួរតែស្វែងរកការដោះស្រាយការព្រួយបារម្ភភ្លាមៗដោយអនុវត្តន៍ដំណើរការពិគ្រោះយោបល់ដែលមានតម្លាភាព និងអាចងាយយល់បាន និងដែលមានលក្ខណៈសមរម្យតាមវប្បធម៌និងអាចចូលរួមបានដោយងាយស្រួល និងមិនត្រូវការចំណាយដែលជាបន្ទុកភាគីដែលជាប្រភពដើមបញ្ហា ឬដែលបានលើកការព្រួយបារម្ភឡើងមក។ យន្តការនេះមិនគួររារាំងដល់ការចូលដោះស្រាយតាមផ្លូវតុលាការ ឬដំណោះស្រាយតាមបែបរដ្ឋបាលទេ។ អតិថិជននឹងជូនដំណឹងដល់ប្រជាជន ឬសហគមន៍ដែលរងផលប៉ះពាល់អំពីយន្តការនៅក្នុងដំណើរការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងឡាយ (IFC, 2012)[49]

## ៣.៤ ការងារដោះស្រាយទំនាស់ដីធ្លី និងអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជា

ការងារដោះស្រាយទំនាស់ដីធ្លី និងអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជាអាចធ្វើឡើងដោយផ្អែកទៅស្ថានភាពនៃការចុះបញ្ជី។ ក្នុងករណីដី ឬអចលនទ្រព្យដែលត្រូវបានចុះបញ្ជី និងផ្តល់ប័ណ្ណកម្មសិទ្ធិត្រឹមត្រូវតាមច្បាប់ ហើយត្រូវបានបុគ្គលផ្សេងទៀត ឬមានក្រុមហ៊ុនវិនិយោគឯកជនរំលោភបំពាន នោះម្ចាស់កម្មសិទ្ធិត្រូវដាក់ពាក្យបណ្តឹងទៅកាន់តុលាការ និងអនុវត្តតាមនីតិវិធីនៃប្រព័ន្ធតុលាការដែលមានជាក់ស្តែង។ ប៉ុន្តែម្ចាស់កម្មសិទ្ធិអាចជ្រើសរើសការដោះស្រាយការរំលោភបំពានតាមរយៈដំណើរការក្រៅប្រព័ន្ធតុលាការ ដោយមានការសម្របសម្រួលគ្នាតាមឋានានុក្រមនៃអាជ្ញាធរដែលពាក់ព័ន្ធ។ ប្រសិនបើការដោះស្រាយតាមមធ្យោបាយនេះមិនជោគជ័យ ម្ចាស់កម្មសិទ្ធិអាចប្រើប្រាស់ប្រព័ន្ធតុលាការជាជម្រើសចុងក្រោយ។

[46] (ibid, IFC, 2012)
[47] (ibid) Vo, M. & Brereton, D. (2014)
[48] (ibid, IFC, 2012)
[49] (ibid, IFC, 2012)

ចំពោះដី ឬអចលនទ្រព្យដែលមិនទាន់បានចុះបញ្ជី ភាគីពាក់ព័ន្ធក្នុងករណីទំនាស់នេះត្រូវអនុវត្តតាមនីតិវិធី និងយន្តការដូចខាងក្រោម៖

- ក្នុងករណីទំនាស់ដីធ្លីកើតឡើងទៅលើប្រជាពលរដ្ឋណាម្នាក់ ឬក្រុមហ៊ុនវិនិយោគឯកជននៅក្នុងតំបន់ពួកគេ ភាគីដែលត្រូវបានគេរំលោភនោះអាចដាក់ពាក្យបណ្តឹងស្វែងរកដំណោះស្រាយទៅកាន់ក្រុមប្រឹក្សាឃុំ-សង្កាត់ដែលមានតួនាទីជាអ្នកសម្រុះសម្រួលនៅកម្រិតថ្នាក់មូលដ្ឋាន។ ក្នុងករណីដែលបណ្តឹងមិនត្រូវបានដោះស្រាយឱ្យមានប្រសិទ្ធភាព ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ជូនករណីនេះបន្តទៅអាជ្ញាធរថ្នាក់លើទៀត
- គណៈកម្មការសុរិយោដីស្រុក ខណ្ឌ ខេត្ត ក្រុង និងថ្នាក់ជាតិមានបេសកកម្មដោះស្រាយវិវាទទាក់ទងអចលនវត្ថុដែលមិនទាន់ចុះបញ្ជីសុរិយោដី។ ក្នុងករណីគណៈកម្មការនេះមិនអាចដោះស្រាយវិវាទនេះបាន សំណុំរឿងទំនាស់នេះត្រូវបញ្ជូនបន្តទៅកាន់គណៈកម្មការរដ្ឋបាល។
- គណៈកម្មការរដ្ឋបាលត្រូវបានបង្កើតឡើងដើម្បីដឹកនាំការចុះបញ្ជីជាប្រព័ន្ធនៅក្នុងតំបន់វិនិច្ឆ័យ។ ភារៈកិច្ចមួយនៃគណៈកម្មការនេះគឺធ្វើការដោះស្រាយវិវាទដីធ្លីដែលកើតមាននៅក្នុងកំឡុងពេលនៃការចុះបញ្ជីជាលក្ខណៈប្រព័ន្ធ។ ក្នុងករណីដែលគណៈកម្មការនេះមិនអាចដោះស្រាយបាន សំណុំរឿងទំនាស់នេះត្រូវបញ្ជូនបន្តទៅកាន់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គឺជាយន្តការថ្នាក់ជាតិដែលបំពេញមុខងារបន្ថែមដល់គណៈកម្មការសុរិយោដី។ អាជ្ញាធរនេះត្រូវបានផ្តល់សិទ្ធិត្រួតពិនិត្យលើករណីទំនាស់ដីធ្លីនានាដែលផុតពីភារកិច្ចរបស់គណៈកម្មការសុរិយោដី។
- តុលាការមានសមត្ថកិច្ចដោះស្រាយទំនាស់ដីណាដែលបានចុះបញ្ជី និងដីដែលបានផ្តល់បណ្ណកម្មសិទ្ធិរួចហើយ។ ប៉ុន្តែតុលាការក៏មានសមត្ថកិច្ចដោះស្រាយរាល់វិវាទដីធ្លីទាំងអស់រួមទាំងដីមិនបានចុះបញ្ជីដែលភាគីវិវាទមិនបានយល់ព្រមតាមសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីផងដែរ។

ក្រៅអំពីយន្តការ និងនីតិវិធីខាងលើនេះ ភាគីពាក់ព័ន្ធនិងទំនាស់អាចសុំការជួយអន្តរាគមន៍ដោយផ្ទាល់ពីក្រសួងដែលពាក់ព័ន្ធដូចជាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងបរិស្ថាន, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទជាដើម។

ដ្យាក្រាមទី៦៖ យន្តការដោះស្រាយទំនាស់ដីធ្លី និងអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជា[50]




## ៣.៥ បទពិសោធន៍នៃវិធីសាស្ត្រដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងវិនិយោគឯកជន

សម្រាប់គម្រោងវិនិយោគឯកជន ប្រភេទនៃផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ភាគីពាក់ព័ន្ធ និងប្រជាពលរដ្ឋរងនូវផលប៉ះពាល់មិនមានលក្ខណៈខុសគ្នាទាំងស្រុងពីផលប៉ះពាល់ដែលកើតចេញពីគម្រោងសាធារណៈនោះឡើយ។ នីតិវិធី យន្តការ និងបទពិសោធន៍ដោះស្រាយផលប៉ះពាល់ពីគម្រោងសាធារណៈរបស់រដ្ឋ ក៏អាចយកមកប្រើប្រាស់បានសម្រាប់ការងារដោះស្រាយរបស់គម្រោងវិនិយោគឯកជន ដោយចាំបាច់ត្រូវធ្វើការកែសម្រួលនិងបត់បែនទៅតាមស្ថានភាពគម្រោងជាក់ស្តែង។ ខាងក្រោមនេះជាគោលការណ៍ណែនាំមួយចំនួនដែលបានដកស្រង់ចេញពីបទពិសោធន៍ជាក់ស្តែងដែលម្ចាស់គម្រោងវិនិយោគឯកជន ចាំបាច់ត្រូវគិតគូរពិចារណាឱ្យបានល្អិតល្អន់មុននឹងរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់។ ម្ចាស់គម្រោងត្រូវអនុវត្តតាមចំណុចសំខាន់ៗដូចមានរៀបរាប់ខាងក្រោមនេះ៖

- **ក. សិក្សាស្វែងយល់អំពីប្រភេទ ទំហំ និងកម្រិតនៃហេតុផលប៉ះពាល់៖** ម្ចាស់គម្រោងត្រូវតែឈ្វេងយល់ជាចាំបាច់អំពីស្ថានភាពនៃផលប៉ះពាល់ដែលអាចកើតមានពីសកម្មភាពគម្រោងដែលបានស្នើឡើង។ ម្ចាស់គម្រោងអាចចាត់តាំងក្រុមការងាររបស់ខ្លួនផ្ទាល់ ឬធ្វើការជាមួយក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេសក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់នានាទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត។ ការសិក្សាប្រមូលព័ត៌មានអាចធ្វើឡើងតាមបច្ចេកទេសមួយចំនួនដែលត្រូវបានប្រើប្រាស់នៅក្នុងការងារដោះស្រាយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍របស់រដ្ឋាភិបាល ដែលរួមមានការសិក្សាអង្កេតវាស់វែងលម្អិត (Detail Measurement Survey – DMS) ការធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិដែលបាត់បង់ (Inventory of Loss – IOL) និងការសិក្សាថ្លៃជំនួស (Replacement Cost Study – RCS) ជាដើម។ ការឈ្វេងយល់អំពីផលប៉ះពាល់និងការប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធទាំងនេះនឹងជួយជាមូលដ្ឋានក្នុង

[50] រូបគំនូរមនុស្សប្រុសមានប្រភពមកពី https://dribbble.com/shots/5448238-vector-art, ចូលទៅទស្សនានិងថតចម្លងប្រើប្រាស់នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០

ការកំណត់រកនូវនិតីវិធី និងយុទ្ធសាស្ត្រក្នុងការរៀបចំផែនការដោះស្រាយផលប៉ះពាល់នៅពេលក្រោយៗទៀត។

- **ខ. សិក្សាអំពីមូលដ្ឋានគតិយុត្តៈ** មុនដំបូងម្ចាស់គម្រោងត្រូវសិក្សាអំពីក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធសំខាន់ៗក្នុងការដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត និងការស្តារជីវភាពឡើងវិញរបស់ប្រជាពលរដ្ឋរងគ្រោះ។ ម្ចាស់គម្រោងអាចធ្វើការជាមួយក្រុមហ៊ុនទីប្រឹក្សាក្នុងការរៀបចំឯកសារ និងពិគ្រោះយោបល់អំពីច្បាប់ និងនីតិវិធីនានាដែលចាំបាច់ក្នុងការដោះស្រាយ។

- **គ. នីតិវិធី និងយន្តការដោះស្រាយៈ** ម្ចាស់គម្រោងចាំបាច់ត្រូវសិក្សា និងឈ្វេងយល់ឱ្យបានលម្អិតអំពីនីតិវិធីតាមផ្លូវច្បាប់ និងយន្តការដោះស្រាយផលប៉ះពាល់នានាដែលអាចអនុវត្តន៍បាននៅក្នុងទីតាំងគម្រោងរបស់ខ្លួន។ ម្ចាស់គម្រោងអាចពិភាក្សាជាមួយក្រុមហ៊ុនទីប្រឹក្សា ឬអាជ្ញាធរមូលដ្ឋានក្នុងឈ្វេងយល់ និងសុំកិច្ចសហការនានាដែលចាំបាច់នៅពេលបន្ទាប់។ ជាទូទៅការដោះស្រាយទំនាស់លើអចលនទ្រព្យ (ជាពិសេសទំនាស់ដីធ្លី) នៅក្នុងប្រទេសកម្ពុជារវាងបុគ្គលនិងបុគ្គល ឬរវាងបុគ្គលនិងក្រុមហ៊ុនវិនិយោគឯកជន ត្រូវប្រើប្រាស់នូវនីតិវិធីដោះស្រាយតាមកម្រិតដូចជា (១). ក្រុមប្រឹក្សាឃុំ-សង្កាត់ (២). គណៈកម្មការសុរិយោដី (ស្រុកខណ្ឌ ខេត្តក្រុង និងថ្នាក់ជាតិ) (៣). គណៈកម្មការរដ្ឋបាល (៤). អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និង (៥). តុលាការ។

- **ឃ. ភាគីពាក់ព័ន្ធៈ** ម្ចាស់គម្រោងត្រូវឈ្វេងយល់អំពីភាគីពាក់ព័ន្ធសំខាន់ៗដោយផ្តោតទៅលើ ១) តួនាទីនិងការទទួលខុសត្រូវ និង២) បញ្ហា និងតម្រូវការរបស់ភាគីនីមួយៗជាពិសេសប្រជាពលរដ្ឋរងផលប៉ះពាល់។ ភាគីពាក់ព័ន្ធសំខាន់ៗមានដូចជាអាជ្ញាធរឃុំ/សង្កាត់ គណៈកម្មការសុរិយោដីស្រុកខណ្ឌ ខេត្តក្រុង និងថ្នាក់ជាតិ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី តុលាការ ឬអាជ្ញាធរពាក់ព័ន្ធផ្សេងទៀតដូចជាដែនជម្រកសត្វព្រៃ និងឧទ្យានជាតិជាដើម។

- **ង. រៀបចំត្រៀមឯកសារអំពីព័ត៌មានប្រជាពលរដ្ឋរងផលប៉ះពាល់ និងទ្រព្យសម្បត្តិប៉ះពាល់ៈ** ម្ចាស់គម្រោងត្រូវរៀបចំចងក្រងនូវឯកសារព័ត៌មានជាមូលដ្ឋានសំខាន់ៗអំពីចំនួនប្រជា-ពលរដ្ឋរងផលប៉ះពាល់ និងទ្រព្យសម្បត្តិទាំងឡាយដែលនឹងត្រូវប៉ះពាល់ពីសកម្មភាពគម្រោង សំណូមពរនិងអនុសាសន៍របស់ប្រជាពលរដ្ឋ ព្រមទាំងនីតិវិធីក្នុងការដោះស្រាយផងដែរ។ ម្ចាស់គម្រោងអាចធ្វើការចងក្រងនូវព័ត៌មានទាំងនេះដោយផ្ទាល់ ឬធ្វើការសហការជាមួយក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេសដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់ដោយប្រើប្រាស់បច្ចេកទេសសិក្សាដូចជា DMS, IOL និង RCS ជាដើម។ ព័ត៌មាន និងទិន្នន័យទាំងនេះនឹងមានសារៈប្រយោជន៍ណាស់សម្រាប់ជាមូលដ្ឋានក្នុងការដោះស្រាយ និងចរចាសម្រាប់ដំណោះស្រាយនានា។

ខាងក្រោមនេះជាបទពិសោធន៍ជាក់ស្តែងក្នុងការរៀបចំនីតិវិធី និងផែនការដោះស្រាយផលប៉ះពាល់នៅក្នុងបរិបទនៃគម្រោងវិនិយោគ ឬអភិវឌ្ឍន៍ឯកជន។ ចំណុចទាំងឡាយដែលបានលើកឡើងនៅក្នុងផ្នែកនេះ អាចមានការប្រែប្រួលទៅតាមលក្ខណៈនៃគម្រោង ទីតាំង នីតិវិធី និងភាគីពាក់ព័ន្ធដែលមានជាក់លាក់ ប៉ុន្តែចំណុចទាំងនេះអាចជួយផ្តល់នូវគំនិតគោល ឬអនុសាសន៍ល្អៗបន្ថែមសម្រាប់ការអនុវត្តការងារដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងក្រោយៗទៀត។ លំហូរការងាររៀបចំ និងដោះស្រាយផលប៉ះពាល់មានរៀបរាប់ និងសង្ខេបនៅក្នុងដ្យាក្រាមទី៧ ខាងក្រោមៈ

❖ ❶ ម្ចាស់គម្រោងវិនិយោគឯកជន (ឬដោយមានជំនួយពីអ្នកទីប្រឹក្សាបច្ចេកទេសដែលមានបទពិសោធន៍) ត្រូវតែចងក្រងជាឯកសារព័ត៌មានគ្រប់គ្រួសារ និងទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ទាំងអស់។ ទ្រព្យសម្បត្តិទាំងអស់ត្រូវរាប់បញ្ចូលទាំងទ្រព្យសម្បត្តិសំខាន់ៗ និងទូទៅ (ឧទាហរណ៍ ផ្ទះ ហាង ជង្រុកស្រូវ ដីលំនៅដ្ឋាន ឬដីស្រែចម្ការ ឬដំណាំ និងដើមឈើហូបផ្លែផងដែរ)។ គម្រោងត្រូវប្រមូលព័ត៌មានលម្អិតពីគ្រួសារនីមួយៗ ហើយអាជ្ញាធរមូលដ្ឋានត្រូវជូនដំណឹងជាមុនទៅដល់ប្រជាជនដែលរងផលប៉ះពាល់អំពីកម្មវិធីចុះស្រង់ព័ត៌មានទាំងនេះ[51]។ នៅក្នុងច្បាប់អស្សាមិករណ៍ វិធីសាស្ត្រប្រមូលព័ត៌មានទាំងនេះរួមមាន "ការអង្កេតវាស់វែងលម្អិត (DMS) សារពើភ័ណ្ឌនៃទ្រព្យសម្បត្តិដែលបាត់បង់ (IOL) និងការសិក្សាអំពីថ្លៃជំនួស (RCS)" ដែលអាចអនុវត្តបានក្នុងការប្រមូលព័ត៌មានអំពីទ្រព្យសម្បត្តិដែលបាត់បង់។ វិធីសាស្ត្រទាំងនេះក៏អាចយកមកប្រើប្រាស់សម្រាប់ករណីនៃគម្រោងឯកជនផងដែរ។ DMS និង IOL គឺត្រូវការការចូលរួមជាចាំបាច់ ជាពិសេសគាគីពាក់ព័ន្ធសំខាន់ៗដូចជាអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋរងផលប៉ះពាល់ ដើម្បីផ្តល់ព័ត៌មានទាក់ទងនឹងការខាតបង់ទាំងអស់ដោយសារគម្រោង។ ក្រុមហ៊ុនម្ចាស់គម្រោងត្រូវពិភាក្សាបច្ចេកទេសលម្អិតជាមួយក្រុមហ៊ុនទីប្រឹក្សាណាមួយដែលមានជំនាញ ក្នុងការរៀបចំនីតិវិធីសិក្សាប្រមូលព័ត៌មានលម្អិតតាមវិធីសាស្ត្រទាំងអស់នេះ។

❖ ❷ នៅពេលដែលព័ត៌មានពាក់ព័ន្ធអំពីប្រជាជន និងទ្រព្យសម្បត្តិដែលទទួលរងផលប៉ះពាល់ត្រូវបានចងក្រងជាឯកសារបានយ៉ាងល្អហើយ នោះម្ចាស់គម្រោងឯកជននឹងជួបពិភាក្សាជាមួយអាជ្ញាធរខេត្ត ឬគណៈកម្មការទាំងឡាយណាដែលទទួលបន្ទុកលើជម្លោះដីធ្លី ឬការគ្រប់គ្រងផលប៉ះពាល់លើការរុះរើលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត ដើម្បីពិភាក្សារកដំណោះស្រាយសមស្របទៅនឹងតម្រូវការរបស់ប្រជាជនដែលទទួលរងផលប៉ះពាល់ទាំងអស់។ ការជួបពិភាក្សា និងការចរចាគ្នាអាចនឹងត្រូវធ្វើឡើងជាច្រើនដងក្នុងការស្វែងរករូបមន្ត និងនីតិវិធីត្រឹមត្រូវដែលអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ នៅក្នុងដំណាក់កាលនេះ ម្ចាស់គម្រោងឯកជន និងអាជ្ញាធរមានសមត្ថកិច្ចអាចនឹងមានការជួបប្រជុំ និងពិភាក្សាជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ក្នុងការស្វែងរកដំណោះស្រាយរួមគ្នា មុននឹងឈានដល់ការទូទាត់សំណងជាផ្លូវការ[52]។

❖ ❸ មុនពេលប្រតិបត្តិការគម្រោង ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ត្រូវតែមានការផ្តល់សំណងសមរម្យ។ ការទូទាត់សំណងនេះត្រូវធ្វើឡើងដោយគណៈកម្មការដែលបានបង្កើតឡើង និងដោយមានការចូលរួមពីក្រុមហ៊ុនម្ចាស់គម្រោង។ ជម្រើសសំណងអាចជា ១) សាច់ប្រាក់ និង២) ទីតាំង ឬកន្លែងសម្រាប់ការតាំងទីលំនៅថ្មី និងប្រាក់មួយចំនួនសម្រាប់ជួយដល់ការរស់នៅថ្មីរបស់ពួកគាត់ រួមទាំងការស្តារជីវភាពរស់នៅរបស់ពួកគាត់ផងដែរនៅក្នុងកំឡុងពេលនៃការផ្លាស់ប្តូរជីវភាពរបស់ពួកគាត់។ សម្រាប់គម្រោងដែលមានស្តង់ដារអន្តរជាតិ ឬទទួលថវិកាពីធនាគារអន្តរជាតិដែលតម្រូវឱ្យមានការគោរពស្តង់ដាររបស់ពួកគេ ផែនការស្តារជីវភាពរស់នៅឡើងវិញចាំបាច់ត្រូវតែរៀបចំឡើង និងត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួន។

---

51 កាលបរិច្ឆេទចុងក្រោយនេះត្រូវជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋដែលរងគ្រោះយ៉ាងហោចណាស់ ២សប្តាហ៍មុនពេលកម្មវិធីចុះប្រមូលព័ត៌មានលម្អិតត្រូវអនុវត្តឡើងដើម្បីចៀសវាងការខកខានណាមួយដែលអាចនាំឱ្យមានការបាត់បង់នូវផលប្រយោជន៍របស់ភាគីពាក់ព័ន្ធនានា។

52 នៅក្នុងការចរចានេះ គណៈកម្មការដោះស្រាយ និងម្ចាស់គម្រោងឯកជនត្រូវត្រៀមរៀបចំនូវឯកសារមួយចំនួនដូចជាលិខិតបញ្ជាក់អំពីជម្រើសសំណងដែលត្រូវបានឯកភាពគ្នាជាមួយប្រជាពលរដ្ឋ។ លិខិតនេះនឹងជួយរក្សាបាននូវជំហរមិនងាករេ ឬផ្លាស់ប្តូរចិត្តរបស់ប្រជាពលរដ្ឋនៅពេលក្រោយ។ លិខិតបញ្ជាក់នេះត្រូវមានការផ្តិតមេដៃ ឬជាសាក្សីពីមេឃុំ និងតំណាងប្រជាពលរដ្ឋម្នាក់។

❖ ❹ នៅពេលជម្រើសសំណងត្រូវបានជ្រើសរើស និងសម្រេចជាមួយប្រជាពលរដ្ឋដែលរងគ្រោះរួចរាល់ហើយ គណៈកម្មការដោះស្រាយ និងក្រុមហ៊ុនម្ចាស់គម្រោងត្រូវរៀបចំពិធីជាផ្លូវការក្នុងការបើកប្រាក់សំណងជូនប្រជាពលរដ្ឋ។ រាល់ការទូទាត់សំណងទាំងអស់ ម្ចាស់គម្រោងចាំបាច់ត្រូវតែចងក្រងជាឯកសារច្បាស់លាស់ (ជាមួយនឹងស្នាមមេដៃ និងរូបថតផងដែរ)[53]។ វិធីសាស្រ្តក្នុងការទូទាត់សំណងជាប្រាក់ (ក្នុងករណីដែលចំនួនប្រាក់ច្រើនសម្រាប់គ្រួសារនីមួយៗ) ម្ចាស់គម្រោង និងគណៈកម្មការដោះស្រាយត្រូវពិភាក្សាគ្នាក្នុងការកំណត់យកនូវវិធីសាស្រ្តទូទាត់ណាមួយ ដែលមានសុវត្ថិភាពបំផុតទាំងភាគីអ្នកទូទាត់ និងប្រជាពលរដ្ឋដែលទទួលសំណង។

❖ ❺ នៅពេលដែលប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ទាំងអស់ ទទួលបានសំណងរួចរាល់ហើយនោះ ម្ចាស់គម្រោងឯកជនត្រូវតែសរសេររបាយការណ៍សង្ខេបអំពីនីតិវិធី និងដំណោះស្រាយទាំងអស់ដែលបានអនុម័តក្នុងការដោះស្រាយបញ្ហាលើការរុះរើលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត ហើយផ្ញើឱ្យគណៈកម្មការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត និងក្រសួងទទួលបន្ទុកនានាសម្រាប់ការទទួលស្គាល់ និងសម្រាប់ជាឯកសារកាលប្បវត្តិជាដើម។

❖ ❻ ម្ចាស់គម្រោងឯកជនអាចចាប់ផ្តើមអនុវត្តន៍ផែនការសកម្មភាពរបស់ខ្លួនសម្រាប់ការវិនិយោគនៅពេលដែលបញ្ហានៃការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តទាំងអស់ត្រូវបានដោះស្រាយរួចរាល់។

ដ្យាក្រាមទី៧៖ លំហូរការងារដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍ឯកជន




ប្រភព៖ សំ ចាន់ធី (២០១៨)[54]

[53] ជាទូទៅ ម្ចាស់គម្រោងត្រូវត្រៀម ១) កិច្ចសន្យាជាផ្លូវការក្នុងការយល់ព្រមទទួលសំណង និង២) វិក័យប័ត្រទទួលប្រាក់ដែលឯកសារទាំងអស់នេះត្រូវមានសាក្សី និងការដឹងលឺគ្រប់គ្រាន់ពីអាជ្ញាធរមូលដ្ឋាន និងតំណាងប្រជាពលរដ្ឋ។

[54] សំ ចាន់ធី (២០១៨) របាយការណ៍ជំនួយបច្ចេកទេសស្តីពីការពិនិត្យលើបញ្ហានៃការតាំងទីលំនៅឡើងវិញ ការទូទាត់សំណង និងយន្តការបណ្តឹងសម្រាប់គម្រោងវិនិយោគឯកជននៅក្នុងប្រទេសកម្ពុជា នៅក្នុងបរិបទនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ក្រសួងបរិស្ថាន និងគណៈកម្មាធិការបម្រើក្វេគ័រអាមេរិកកាំង (AFSC)។ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

## ៣.៦ ឯកសារគោលសម្រាប់ម្ចាស់គម្រោងក្នុងការងារដោះស្រាយផលប៉ះពាល់

- របាយការណ៍ផលប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋ
- សៀវភៅ ឬឯកសារផ្សព្វផ្សាយអំពីគម្រោង គោលការណ៍ និងផែនការដោះស្រាយផលប៉ះពាល់
- កំណត់ហេតុនៃកិច្ចពិគ្រោះយោបល់ជាផ្លូវការជាមួយភាគីពាក់ព័ន្ធនានា
- កិច្ចសន្យាព្រមព្រៀងទទួលសំណង និងដំណោះស្រាយផ្សេងៗ
- របាយការណ៍បូកសរុបលទ្ធផលនៃការងារដោះស្រាយផលប៉ះពាល់

## ៣.៧ នីតិវិធីរៀបចំរបាយការណ៍ផលប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋ

ក្នុងករណីដែលគម្រោងវិនិយោគឯកជនរបស់អ្នក ត្រូវបានតម្រូវឱ្យរៀបចំនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬពេញលេញ ហើយគម្រោងរបស់អ្នកអាចបង្កឱ្យមានការរុះរើ ឬប៉ះពាល់ទៅលើការតាំងទីលំនៅ និងជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានណាមួយ ម្ចាស់គម្រោងត្រូវធានាថារបាយការណ៍វាយតម្លៃហេតុប៉ះពាល់របស់ខ្លួនមានព័ត៌មាន ឬទិន្នន័យគ្រប់គ្រាន់ និងមាន ឬបានលើកឡើងនូវវិធានការនិងយន្តការនានាដែលអាចធានាបាននូវនីតិវិធីដោះស្រាយប្រកបដោយប្រសិទ្ធភាពខ្ពស់ជាមួយប្រជាពលរដ្ឋរងគ្រោះ ក្រោមក្របខ័ណ្ឌគតិយុត្ត និងស្ថាប័នទទួលខុសត្រូវដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា។ ម្ចាស់គម្រោងត្រូវភ្ជាប់មកជាមួយនូវភស្តុតាងអំណះអំណាង ឬកំណត់ហេតុនៃកិច្ចប្រជុំពិភាក្សា ឬការផ្តល់អនុសាសន៍ពីភាគីពាក់ព័ន្ធទៅលើការរៀបចំនីតិវិធីដោះស្រាយដែលបានលើកឡើងនៅក្នុងរបាយការណ៍។ ព័ត៌មាន និងយន្តការទាំងនេះមានសារៈសំខាន់ណាស់សម្រាប់ក្រសួងបរិស្ថាន និងមន្ត្រីតំណាងអន្តរក្រសួងក្នុងការត្រួតពិនិត្យ និងសម្រេចថាតើលិខិតឯកភាពលើរបាយការណ៍គួរតែផ្តល់ឱ្យឬយ៉ាងណា។ ដើម្បីរៀបចំព័ត៌មានទាំងនេះឱ្យមានលក្ខណៈស្តង់ដារ និងធានាបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយ ម្ចាស់គម្រោងគួរអនុវត្តន៍នូវវិធីសាស្ត្រដូចខាងក្រោម៖

- ម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬពេញលេញជាមួយក្រុមហ៊ុនទីប្រឹក្សាឯករាជ្យ ដោយត្រូវរំលេចនូវការសិក្សាដាច់ដោយឡែកអំពីផលប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋដែលរបាយការណ៍ទាំងនេះចាំបាច់ត្រូវដាក់ជូនក្រសួងបរិស្ថាន និងក្រុមការងារអន្តរក្រសួងធ្វើការត្រួតពិនិត្យ និងផ្តល់លិខិតឯកភាពជាមុនសិន មុនពេលអនុវត្តន៍គម្រោង។
- បច្ចេកទេសក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬពេញលេញត្រូវផ្អែកទៅលើការពិភាក្សានិងការរៀបចំផែនការសិក្សាវាយតម្លៃហេតុប៉ះពាល់ជាមួយក្រុមហ៊ុនទីប្រឹក្សាដែលបានចុះបញ្ជីជាមួយក្រសួងបរិស្ថានត្រឹមត្រូវ និងមានជំនាញបទពិសោធន៍ច្បាស់លាស់លើការងារសិក្សា និងដោះស្រាយទៅលើការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។ ដោយឡែក នីតិវិធីក្នុងការរៀបចំរបាយ-ការណ៍ផលប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋត្រូវពិចារណានូវលំហូរការងារដូចខាងក្រោម៖
  - *ដំណាក់កាលរៀបចំរបាយការណ៍*
    - ត្រូវធ្វើការសិក្សាអង្កេតវាស់វែងលម្អិត (Detail Measurement Survey – DMS)
    - ត្រូវធ្វើសារពើភ័ណលើទ្រព្យសម្បត្តិដែលត្រូវបាត់បង់ (Inventory of Loss – IOL)
    - ត្រូវធ្វើការសិក្សាថ្លៃជំនួស (Replacement Cost Study– RCS)
    - ត្រូវធ្វើការរៀបចំរបាយការណ៍ផលប៉ះពាល់ ផែនការដោះស្រាយ និងការធ្វើគម្រោងថវិកា

សម្រាប់កិច្ចការងារទាំងអស់នេះ ម្ចាស់គម្រោងអាចអនុវត្តន៍ដោយខ្លួនឯងក៏បាន ប្រសិនបើបានយល់ពីវិធីសាស្ត្រច្បាស់លាស់ ឬអាចប្រើប្រាស់សេវាកម្មពីក្រុមហ៊ុនទីប្រឹក្សាឯកជនដែលមានជំនាញនិងបទពិសោធន៍ឱ្យជួយរៀបចំរបាយការណ៍នេះឡើង។ ដោយឡែក របាយការណ៍ផលប៉ះពាល់ត្រូវមាននូវចំណុចសំខាន់ៗដូចខាងក្រោម៖

១- សេចក្តីសង្ខេប

២- សេចក្តីផ្តើម (លទ្ធផលគម្រោង ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត គោលបំណងនៃការធ្វើលទ្ធកម្មដី និងផែនការតាំងទីលំនៅឡើងវិញ)

៣- គោលការណ៍ច្បាប់ (គោលនយោបាយរបស់ប្រទេសកម្ពុជា និងគោលបំណងនៃការតាំងទីលំនៅឡើងវិញ និងគោលការណ៍នានារបស់គម្រោង)

៤- ទំហំនៃការធ្វើលទ្ធកម្មដី និងការតាំងទីលំនៅឡើងវិញ (សេចក្តីសង្ខេបនៃហេតុប៉ះពាល់របស់ អនុគម្រោង ជនរងគ្រោះ ការបាត់បង់ផ្នែករូបសាស្ត្រ ការខាតបង់ផ្នែកសេដ្ឋកិច្ច ហេតុប៉ះពាល់នៃការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តទៅលើស្ត្រី ក្រុមងាយរងគ្រោះ វិធានការចៀសវាង និងកាត់បន្ថយហេតុប៉ះពាល់នៃការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត)

៥- ព័ត៌មានផ្នែកសេដ្ឋកិច្ច-សង្គម (ដូចជាស្ថានភាពសង្គម-វប្បធម៌ អ្នកកាន់កាប់តំបន់រងគ្រោះបច្ចុប្បន្ន ការពិពណ៌នាអំពីប្រព័ន្ធផលិតកម្ម ពលកម្ម និងសមាជិកគ្រួសារ ព័ត៌មានគោលអំពីជីវភាព (កម្រិតផលិតកម្ម និងចំណូល) ទំហំនៃការខាតបង់ទ្រព្យសម្បត្តិ (ទាំងស្រុង ឬដោយផ្នែក) និងការសិក្សាដទៃទៀត (ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេវាកម្មសង្គម លក្ខណៈសង្គម និងវប្បធម៌នៃសហគមន៍ដែលត្រូវជម្លៀសចេញ។)

៦- ការផ្សព្វផ្សាយព័ត៌មាន ការប្រឹក្សាយោបល់ និងការចូលរួម (ព័ត៌មាន និងយុទ្ធនាការអប់រំ និងការប្រឹក្សាយោបល់ក្នុងអំឡុងពេលធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពសម្រាប់ការតាំងទីលំនៅឡើងវិញ ការប្រឹក្សាយោបល់ និងការចូលរួមក្នុងអំឡុងពេលអនុវត្តន៍ផែនការនេះ)

៧- យន្តការដោះស្រាយបណ្តឹងតវ៉ា

៨- ការផ្តល់សិទ្ធិ ជំនួយ និងអត្ថប្រយោជន៍ (ទំហំនៃប្រាក់សំណងនិងជំនួយ ការផ្តល់សិទ្ធិដល់គម្រោងកម្មវិធីស្តារប្រាក់ចំណូល និងជំនួយដល់ក្រុមងាយរងគ្រោះ)

៩- ផែនការថវិកា និងហិរញ្ញវត្ថុ (គោលការណ៍នៃតម្លៃជំនួស អត្រាសំណង និងជំនួយរដ្ឋបាល ការត្រួតពិនិត្យខាងក្រៅ និងការចំណាយរំពឹងទុក នីតិវិធីនៃការបង់សំណង ប្រាក់សំណងសម្រាប់ហេតុប៉ះពាល់បណ្តោះអាសន្នក្នុងអំឡុងពេលសាងសង់ ការសង្ខេប និងការផ្តល់ហិរញ្ញវត្ថុសម្រាប់ការចំណាយលើការផ្លាស់ប្តូរទីលំនៅ)

១០- ការរៀបចំស្ថាប័ន (ការរៀបចំ និងការអនុវត្តផែនការសកម្មភាពសម្រាប់ការតាំងទីលំនៅថ្នានដោយមិនស្ម័គ្រចិត្តទាំងមូល និងការផ្សារភ្ជាប់ទំនាក់ទំនងទៅនឹងការផ្តល់កិច្ចសន្យាសម្រាប់ការងារសាងសង់នានា)

១១- ការតាមដានត្រួតពិនិត្យ និងការរាយការណ៍ (ការត្រួតពិនិត្យផ្ទៃក្នុង ការត្រួតពិនិត្យ និងវាយតម្លៃពីខាងក្រៅ)

១២- កាលបរិច្ឆេទសម្រាប់អនុវត្តការងារ

១៣- ឧបសម្ព័ន្ធដូចដែលបានភ្ជាប់ជូន៖

- ទំហំនៃការធ្វើលទ្ធកម្មដីតាមភូមិ
- បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ និងដើមឈើដែលប៉ះពាល់ក្នុងគ្រួសារនីមួយៗ
- បញ្ជីរាយនាមគ្រួសារដែលងាយរងគ្រោះ
- របាយការណ៍នៃកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ
- សៀវភៅណែនាំអំពីគម្រោងវិនិយោគ
- ការសិក្សាពីតម្លៃជំនួស។

តម្រូវការព័ត៌មានទាំងនេះគឺមានសារៈសំខាន់សម្រាប់គណៈកម្មការអន្តរក្រសួង និងក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ក្រសួងបរិស្ថាន ដើម្បីធានាថាគម្រោងអភិវឌ្ឍន៍ឯកជននឹងកាត់បន្ថយបាននូវហេតុប៉ះពាល់សេដ្ឋកិច្ច-សង្គមទៅលើគ្រួសាររងគ្រោះ ដោយសារការប៉ះទង្គិចនានាពីសកម្មភាពគម្រោងការរុះរើនិងការផ្លាស់ប្ដូរទីលំនៅឡើងវិញ និងដើម្បីជាជំនួយដល់អ្នកធ្វើការសម្រេចចិត្តទៅលើគម្រោង និងបញ្ហានៃការតាំងទីលំនៅឋានដោយមិនស្ម័គ្រចិត្តនៅក្នុងបរិបទនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់ក្រសួងបរិស្ថាន។

*ដំណាក់កាលពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ៖* បន្ទាប់ពីរបាយការណ៍ត្រូវបានរៀបចំរួចរាល់ ម្ចាស់គម្រោងវិនិយោគឯកជនចាំបាច់ត្រូវរៀបចំកិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដែលមានដូចជាអាជ្ញាធរ ភូមិ-ឃុំ-ស្រុក គណៈកម្មការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត និងប្រជាពលរដ្ឋរងផលប៉ះពាល់។ គោលបំណងសំខាន់នៃកិច្ចពិគ្រោះយោបល់នេះគឺដើម្បីផ្សព្វផ្សាយនូវលទ្ធផល និងផែនសកម្មភាពអនុវត្តបន្តដែលមានក្នុងរបាយការណ៍ និងដើម្បីបញ្ជាក់អំពីជម្រើសដំណោះស្រាយនានាដែលសមស្រប និងអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ កិច្ចប្រជុំពិគ្រោះយោបល់អាចត្រូវរៀបចំឡើងជាច្រើនដងអាស្រ័យទៅលើតម្រូវការ និងស្ថានភាពនៃការដោះស្រាយរបស់ភាគីពាក់ព័ន្ធតាមតំបន់មូលដ្ឋាននីមួយៗ។

## ៣.៨ ជម្រើសសំណង

ជម្រើសផ្តល់សំណង ត្រូវបានកំណត់ក្នុងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា ឧទាហរណ៍.សារាចរលេខ ០៣ ដែលអនុម័តកាលពីឆ្នាំ២០១០ ស្ដីពីការដោះស្រាយការតាំងទីលំនៅបណ្ដោះអាសន្នលើដីរដ្ឋដែលបានកាន់កាប់ដោយខុសច្បាប់នៅក្នុងរាជធានី តំបន់ប្រជុំជន និងតំបន់ទីក្រុងត្រូវបានស្នើតាមជម្រើសសំណងបីយ៉ាង ១). ការផ្លាស់ប្ដូរទីលំនៅអាចធ្វើឡើងបានក្នុងករណីដែលការតាំងទីលំនៅនោះមិនអាចធ្វើការអភិវឌ្ឍនៅនឹងកន្លែងបាន ២). ប្រសិនបើអាចធ្វើបានឱ្យសមម្យេ គួរធ្វើការអភិវឌ្ឍនៅនឹងកន្លែង សម្រាប់ការតាំងទីលំនៅបណ្ដោះអាសន្នណាមួយនៅលើដីរដ្ឋដែលកាន់កាប់ដោយខុសច្បាប់ និង ៣). ទម្រង់ដ៏ទៃទៀតនៃគោលនយោបាយដោះស្រាយផ្អែកលើល័ក្ខខ័ណ្ឌពិតប្រាកដ។ ម្យ៉ាងទៀត សេចក្តីព្រាងអនុក្រឹត្យស្តីពីការដោះស្រាយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គម ដែលបណ្ដាលមកពីគម្រោងអភិវឌ្ឍន៍ឆ្នាំ២០០៧[55] បានចែងថា *សំណងសម្រាប់គ្រួសារដែលទទួលរងផលប៉ះពាល់នឹងត្រូវបានធ្វើឡើងអាស្រ័យទៅលើកម្រិតនៃផលប៉ះពាល់*។ តាមអនុក្រឹត្យនេះជម្រើសសំណងមានដូចបង្ហាញតាមក្រាហ្វិកទី៧ខាងក្រោម។

ក្រៅអំពីប្រភេទសំណងខាងលើ ជម្រើសសំណងមួយទៀតដែលមានសារៈសំខាន់បំផុតនោះ គឺការអនុវត្ត " **គោលការណ៍ស្បែកខ្លា** " ។ គំនិតនៃគោលការណ៍ស្បែកខ្លានេះត្រូវយកមកអនុវត្តជាដំបូងនៅក្នុងឆ្នាំ២០១០ និងក្នុងឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានចេញបទបញ្ជាលេខ ០១បប ស្ដីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធ

[55] សេចក្ដីព្រាងជាភាសាខ្មែរត្រូវបានកែសម្រួលឡើងវិញនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ (ចំណែកជាភាសាអង់គ្លេសកែសម្រួលថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧)

ភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច[56] ដោយបានបញ្ជាក់យ៉ាងសំខាន់ក្នុងការអនុវត្តនូវរូបមន្តស្បែកខ្លានេះ រហូតមកដល់ពេលបច្ចុប្បន្ន ហើយត្រូវបានប្រើប្រាស់ជាពិសេសនៅក្នុងសេចក្តីសម្រេច ឬលិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់សិទ្ធិ ឬអាជ្ញាបណ្ណសម្បទានទៅឱ្យក្រុមហ៊ុនឯកជនក្នុងការអភិវឌ្ឍ ឬវិនិយោគទៅលើផ្នែកណាមួយនៃធនធាន ឬទ្រព្យសម្បត្តិរបស់រដ្ឋ។ គោលការណ៍នេះសង្កត់ធ្ងន់ថារាល់គម្រោងអភិវឌ្ឍន៍សាធារណៈ ឬវិនិយោគឯកជនក្តីត្រូវតែកាត់ ឬឆ្វៀលចេញនូវដី ទីតាំង ឬទ្រព្យសម្បត្តិដែលអាចប៉ះពាល់ដល់ការកាន់កាប់ស្របច្បាប់របស់ប្រជាពលរដ្ឋនៅតាមតំបន់មូលដ្ឋាន។ មូលដ្ឋានគន្លឹះសំខាន់នៃគោលការណ៍នេះគឺការទទួលស្គាល់នូវការកាន់កាប់ និងអាស្រ័យផលរបស់ប្រជាពលរដ្ឋជាងការបណ្តេញចេញដោយបង្ខំទៅលើប្រជាពលរដ្ឋទាំងនោះ ហើយត្រូវធានាមិនឱ្យប៉ះពាល់ដល់ដីធ្លីសហគមន៍ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងគោលដៅធ្វើឱ្យសម្បទានសេដ្ឋកិច្ចទាំងនោះបានផ្តល់ផលប្រយោជន៍ពិតប្រាកដជូនប្រទេសជាតិ និងប្រជាជនប្រកបដោយចីរភាព។

ដ្យាក្រាមទី៨៖ ជម្រើសសំណង




- ផ្តល់នូវជម្រើសរួមបញ្ចូលគ្នាទាំងដី ឬទ្រព្យសម្បត្តិ និងប្រាក់ ដោយផ្អែកលើកិច្ចព្រមព្រៀងជាមួយក្រុមគ្រួសារដែលទទួលរងផលប៉ះពាល់



- ផ្តល់នូវសំណងជំនួសសមរម្យដូចជាដី ឬទ្រព្យសម្បត្តិផ្សេងៗសម្រាប់ដី និងទ្រព្យសម្បត្តិដែលខូចខាត ឬដែលត្រូវដកហូត



- ផ្តល់ប្រាក់គ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យបុគ្គល ឬក្រុមគ្រួសារដែលទទួលរងផលប៉ះពាល់អាចទទួល ឬទិញដី ឬទ្រព្យសម្បត្តិដែលមានតម្លៃស្មើ ឬដែលមានផលិតភាពល្អប្រសើរជាងមុននៅក្នុងតំបន់ស្រដៀងគ្នាទៅតាមតម្លៃទីផ្សារបច្ចុប្បន្ន នៅពេលធ្វើលទ្ធកម្មដី ឬនៅពេលទូទាត់ចំណាយ (តម្លៃជំនួស)



[56] បទបញ្ជាលេខ ០១បប ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលកម្ពុជា។

ដ្យាក្រាមទី៩៖ គំរូអនុវត្តរូបមន្តស្បែកខ្លា




**ផ្ទៃដីសម្បទានសេដ្ឋកិច្ច**

### ៣.៩ ភាគីពាក់ព័ន្ធមានសមត្ថកិច្ចក្នុងការអនុវត្ត តាមដាន និងពិនិត្យការងារដោះស្រាយផលប៉ះពាល់

ស្ថិតក្នុងបរិបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅពេលដែលផែនការដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តត្រូវបានរៀបចំនិងឯកភាពរួចរាល់ ភាគីពាក់ព័ន្ធសំខាន់ៗដែលចាំបាច់ត្រូវអនុវត្ត តាមដាន និងពិនិត្យការងារដោះស្រាយផលប៉ះពាល់។ ស្ថាប័ន និងភាគីដែលទទួលបន្ទុកលើការគាំទ្រការងារដោះស្រាយបញ្ហាការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ជាពិសេសសម្រាប់គម្រោងវិនិយោគឯកជន អាចកំណត់បានថាជាភាគីពាក់ព័ន្ធផ្លូវការ។ ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ យន្តការរដ្ឋបាលដែលមានរចនាសម្ព័ន្ធចាត់ចែងត្រឹមត្រូវដែលមានដូចជាក្រុមប្រឹក្សាឃុំ-សង្កាត់ ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខេត្ត ដែលមានតួនាទីនិងភារកិច្ចក្នុងការជួយដល់ការអភិវឌ្ឍនៅមូលដ្ឋាន និងដោះស្រាយរាល់វិវាទនានាដែលកើតមាននៅក្នុងតំបន់មូលដ្ឋាន។ ជាធម្មតា អភិបាលខេត្ត គឺជាអ្នកបង្កើតក្រុមអ្នកការងារដោះស្រាយមួយដែលមានសមាជិកភាគច្រើនដែលជាអ្នកធ្លាប់មានបទពិសោធន៍ក្នុងការដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តនៅក្នុងគម្រោងសាធារណៈដើម្បីដោះស្រាយផលប៉ះពាល់ក្នុងគម្រោងវិនិយោគឯកជនវិញម្តង។ ភាគីពាក់ព័ន្ធសំខាន់ៗដែលដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងសាធារណៈក៏អាចមានឥទ្ធិពល និងភាពចាំបាច់ក្នុងការជួយដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងវិនិយោគឯកជនផងដែរ។ ខាងក្រោមនេះជាការសង្ខេបនូវតួនាទីរបស់ភាគីពាក់ព័ន្ធរួមមាន៖

- *តុលាការ៖* តុលាការជាយន្តការនៅដំណាក់កាលចុងក្រោយនៅពេលដែលការដោះស្រាយ ឬសម្របសម្រួលគ្នាក្រៅប្រព័ន្ធតុលាការមិនបានសម្រេចរវាងម្ចាស់គម្រោងវិនិយោគឯកជន និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់។
- *ក្រសួងសាមីដែលពាក់ព័ន្ធ* (ឧ. ក្រសួងបរិស្ថាន ក្រសួងរ៉ែនិងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ល។) ក៏មានភាគព្វកិច្ចចូលរួមដោះស្រាយទៅលើការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តដែលបង្កឡើងដោយក្រុមហ៊ុនវិនិយោគឯកជនដែលទទួលបានសិទ្ធិវិនិយោគពីក្រសួងសាមីទាំងនោះ។ ក្រសួងត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋានតាមបណ្តាខេត្តនីមួយៗ ក្នុងការប្រមូលព័ត៌មាន និងទិន្នន័យ និងជួបពិភាក្សាស្វែងរកដំណោះស្រាយទៅតាមសមត្ថកិច្ច និងវិធីសាស្ត្រដែលអាចអនុវត្តបាន។
- *ក្រុមប្រឹក្សាឃុំ-សង្កាត់ និងស្រុក៖* ក្រុមប្រឹក្សាទាំងនេះមានតួនាទីរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព ការអភិវឌ្ឍ សេវារដ្ឋបាលសាធារណៈដែលចាំបាច់ និងតម្រូវការក្នុងការដោះស្រាយនូវវិវាទនានារវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ និងជាមួយក្រុមហ៊ុនវិនិយោគឯកជនដែលមានវត្តមាននៅក្នុងតំបន់មូលដ្ឋាន។

- *គណៈកម្មការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត៖* គណៈកម្មការនេះត្រូវបានបង្កើតឡើងនៅតាមបណ្តាខេត្តនីមួយៗដែលមានបញ្ហាកើតឡើងរវាងប្រជាពលរដ្ឋនិងក្រុមហ៊ុន និងជួយដោះស្រាយនូវបណ្តឹងនានាផងដែរ។ គណៈកម្មការនេះត្រូវធ្វើការសម្របសម្រួលរវាងភាគីវិវាទទាំងអស់ និងជួយដោះស្រាយរហូតដល់ដំណាក់កាលចុងក្រោយ។ បើវិវាទនៅតែមិនអាចដោះស្រាយបាន សំណុំរឿងនេះនឹងត្រូវបញ្ជូនទៅតុលាការ
- *ម្ចាស់គម្រោងវិនិយោគឯកជន៖* ជាធម្មតាពួកគេមានតួនាទីសំខាន់ក្នុងការដោះស្រាយផលប៉ះពាល់តាមរយៈសំណង ឬជម្រើសផ្សេងទៀតដែលទាក់ទងនឹងការដោះស្រាយវិវាទ។ ការចរចាជាមួយប្រជាជនដែលរងផលប៉ះពាល់នៅក្នុងប្រទេសកម្ពុជាភាគច្រើនពឹងផ្អែកលើអាជ្ញាធរមូលដ្ឋាន ឬគណៈកម្មការដែលបានបង្កើតឡើងសម្រាប់គម្រោងនោះនៅតាមតំបន់ជាក់ស្តែង។ ម្ចាស់គម្រោងត្រូវចូលរួមពិភាក្សា និងដោះស្រាយជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋរងផលប៉ះពាល់នៅគ្រប់ដំណាក់កាលទាំងអស់រហូតដល់វិវាទត្រូវបានដោះស្រាយសមរម្យ។
- *ប្រជាពលរដ្ឋរងគ្រោះ៖* ក្រុមនេះជាភាគីពាក់ព័ន្ធដែលមិនអាចខ្វះបានក្នុងការដោះស្រាយវិវាទលើការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត និងជាអ្នកសម្រេចលើជម្រើសសំណង និងការទទួលបាននូវអត្ថប្រយោជន៍នានាដែលបានឯកភាព និងដោះស្រាយជូន។ ប្រជាពលរដ្ឋមានសិទ្ធិគ្រប់គ្រាន់ក្នុងការស្វែងរកជំនួយពីស្ថាប័នមានសមត្ថកិច្ចក្នុងតំបន់មូលដ្ឋានរបស់ពួកគេបាន និងអាចចូលរួមដោះស្រាយដោយស្ម័គ្រចិត្តក្នុងការដោះស្រាយតាមការសម្របសម្រួលក្រៅប្រព័ន្ធតុលាការ និង/ឬអាចដាក់ពាក្យបណ្តឹង (ក្នុងករណីមិនពេញចិត្តក្នុងការដោះស្រាយកន្លងមក) ទៅកាន់តុលាការទាំងបីថ្នាក់ (សាលាដំបូងរាជធានីខេត្ត សាលាឧទ្ធរណ៍តំបន់ និងតុលាការកំពូល)។ តុលាការនឹងចាត់ការសំណុំរឿងទៅតាមនីតិវិធីរបស់តុលាការដូចមានលើកឡើងនៅក្នុងចំណុច ៣.១០ ខាងក្រោម។

ដ្យាក្រាមទី១០៖ ភាគីពាក់ព័ន្ធសំខាន់ៗ



## ៣.១០ យន្តការដោះស្រាយបណ្តឹងតវ៉ា

យន្តការដោះស្រាយបណ្តឹងតវ៉ាជាយន្តការមួយដែលយកចិត្តទុកដាក់ពិនិត្យ និងពិចារណាអំពីការព្រួយបារម្ភ ការតវ៉ា និងបណ្តឹងផ្សេងៗរបស់ប្រជាពលរដ្ឋរងនូវផលប៉ះពាល់ត្រូវបានដោះស្រាយប្រកបដោយតម្លាភាព និងយុត្តិធម៌។ គោលបំណងសំខាន់នៃការដោះស្រាយបណ្តឹងតវ៉ា គឺដើម្បីដោះស្រាយនូវពាក្យបណ្តឹងឱ្យបានលឿនតាមដែលអាចធ្វើបាននៅថ្នាក់មូលដ្ឋាន តាមរយៈដំណើរការនៃការផ្សះផ្សាមួយ និងដើម្បីផ្តល់នូវនីតិវិធីច្បាស់លាស់ និងតម្លាភាពសម្រាប់បណ្តឹងឧទ្ធរណ៍ ក្នុងករណីមិនមានការដោះស្រាយបញ្ហានោះឱ្យបានត្រឹមត្រូវ។ ប្រជាពលរដ្ឋ និងគ្រួសារដែលមានផ្ទះសម្បែងដែលទទួលរងផលប៉ះពាល់មានសិទ្ធិដាក់ពាក្យប្តឹងទាក់ទងនឹងទិដ្ឋភាពណាមួយនៃសកម្មភាពរបស់គម្រោងវិនិយោគឯកជន។ យន្តការដោះស្រាយបណ្តឹងតវ៉ាដែលកំណត់ច្បាស់លាស់មួយត្រូវបានបង្កើតឡើងដើម្បីដោះស្រាយការតវ៉ា និងពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងគ្រួសារដែលទទួលរងផលប៉ះពាល់ឱ្យទាន់ពេលវេលា និងជាទីពេញចិត្ត។ ប្រជាពលរដ្ឋ និងគ្រួសារដែលទទួលរងផលប៉ះពាល់ទាំងអស់អាចអនុវត្តនូវនីតិវិធីតាមដំណាក់កាលសំខាន់ៗដូចខាងក្រោមដើម្បីឈានដល់ការធ្វើសេចក្តីសម្រេចចិត្ត និងដោះស្រាយលើបណ្តឹងតវ៉ានានា៖

- **ដំណាក់កាលដោះស្រាយក្រៅប្រព័ន្ធតុលាការ**
  - **ដំណាក់កាលទី១៖** នៅពេលប្រជាពលរដ្ឋទទួលបាននូវការជូនដំណឹងឱ្យមានការរុះរើលំនៅដ្ឋាន ឬដឹងលឺអំពីសកម្មភាពរបស់គម្រោងដែលអាចបង្កជាផលប៉ះពាល់ទៅលើលំនៅដ្ឋាន និងការកាន់កាប់ទ្រព្យសម្បត្តិឯកជន ប្រជាពលរដ្ឋទាំងនោះអាចដាក់ពាក្យបណ្តឹងតវ៉ាស្វែងរកដំណោះស្រាយ ឬការបេកស្រាយពីភាគីម្ចាស់គម្រោងវិនិយោគឯកជននៅសាលាឃុំ-សង្កាត់នៅតាមមូលដ្ឋានរបស់ខ្លួន[57]។ ការដាក់ពាក្យបណ្តឹងតវ៉ា អាចធ្វើឡើងជាលាយលក្ខអក្សរ ឬជាពាក្យសម្តីដោយមានការជួយសម្របសម្រួលរបស់មន្ត្រីសាលាឃុំ-សង្កាត់។ នៅពេលដែលពាក្យបណ្តឹងតវ៉ាត្រូវបានរៀបចំ និងដាក់ជូនឃុំ-សង្កាត់រួចរាល់ មេឃុំ ឬចៅសង្កាត់មានរយៈពេល ១៥ថ្ងៃ[58] ក្នុងការកោះប្រជុំ និងស្តាប់អង្គហេតុនានារបស់ភាគីប្រជាពលរដ្ឋ និងម្ចាស់គម្រោងវិនិយោគឯកជន និងជជែកពិភាក្សាស្វែងរកដំណោះស្រាយណាមួយដែលសមស្របសម្រាប់ភាគីទាំងអស់។ ក្នុងករណីមិនអាចដោះស្រាយបាន មេឃុំ-ចៅសង្កាត់ត្រូវណែនាំគ្រួសាររងផលប៉ះពាល់ឱ្យបន្តទៅដំណាក់កាលបន្ទាប់ ហើយត្រូវរាយការណ៍នូវករណី ឬសំណុំរឿងដែលមិនអាចដោះស្រាយបាននេះ ទៅអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតនៅដំណាក់កាលបន្ទាប់។

  - **ដំណាក់កាលទី២៖** ការិយាល័យស្រុក ឬខណ្ឌមានតួនាទីបន្ទាប់សម្រាប់ដោះស្រាយពាក្យបណ្តឹងតវ៉ា[59] ដើម្បីឱ្យមានការពេញចិត្តដល់អ្នកដែលមានបញ្ហាទាំងអស់។ ការិយាល័យនេះមានរយៈពេល

[57] តួនាទីនិងភារកិច្ចរបស់ឃុំ-សង្កាត់មានចែងលម្អិតនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងឃុំសង្កាត់ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ដែលជំពូកទី៤ ចែងអំពីតួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំសង្កាត់ (មាត្រា៤១-៥២)។ ច្បាប់នេះត្រូវបានសភាអនុម័តកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០១។

[58] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១២) នីតិវិធីគោលសម្រាប់ការងារដោះស្រាយផលប៉ះពាល់។ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

[59] តួនាទីនិងភារកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក-ខណ្ឌមានចែងលម្អិតនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក-ខណ្ឌ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលជំពូកទី៤ ចែងអំពីតួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំសង្កាត់ (មាត្រា៤១-៥២)។ ច្បាប់នេះត្រូវបានសភាអនុម័តកាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨ នាសម័យប្រជុំសភាលើកទី៧ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៤ នីតិកាលទី២។

១៥ថ្ងៃ[60]ក្នុងការសិក្សា និងពិភាក្សាស្វែងរកដំណោះស្រាយជាមួយភាគីពាក់ព័ន្ធ។ ប្រសិនបើមានពាក្យបណ្តឹងណាមួយដែលមិនអាចដោះស្រាយបាននៅក្នុងដំណាក់កាលនេះ នោះការិយាល័យស្រុក ឬខណ្ឌនឹងបញ្ជូនករណី ឬសំណុំរឿងនេះទៅកាន់អាជ្ញាធរថ្នាក់ខេត្ត ដើម្បីធ្វើការដោះស្រាយបន្ត ហើយត្រូវរាយការណ៍នូវករណីដែលមិនអាចដោះស្រាយបាននេះ ទៅអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតនៅដំណាក់កាលបន្ទាប់ទៀត។

- **ដំណាក់កាលទី៣៖** អាជ្ញាធរខេត្តនឹងជួបជាមួយភាគីដែលពាក់ព័ន្ធទាំងអស់ និងព្យាយាមដោះស្រាយបណ្តឹងទាំងនោះ។ អាជ្ញាធរខេត្តនេះនឹងស្នើសុំឱ្យពិនិត្យមើលឯកសារ និងកំណត់ហេតុនានាដើម្បីស្វែងរកនូវដំណោះស្រាយណាមួយដែលសមស្របជាមួយភាគីពាក់ព័ន្ធទាំងអស់។ ក្នុងរយៈពេល៣០ថ្ងៃ[61] អាជ្ញាធរខេត្តនេះត្រូវតែធ្វើការសម្រេចចិត្តជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការចរចា ឬដំណោះស្រាយណាមួយសម្រាប់ភាគីពាក់ព័ន្ធ។ ក្នុងករណីដែលភាគីណាមួយមិនពេញចិត្ត ឬមិនអាចទទួលយកបាននូវដំណោះស្រាយ ឬសេចក្តីសម្រេចនោះទេ អាជ្ញាធរខេត្តអាចអនុវត្តនីតិវិធីរដ្ឋបាលហើយណែនាំគ្រួសារដែលរងផលប៉ះពាល់ ឬភាគីពាក់ព័ន្ធឱ្យបន្តទៅដំណាក់កាលបន្ទាប់ទៀត។

- **ដំណាក់កាលទី៤៖** អាជ្ញាធរខេត្តអាចនឹងបញ្ជូនសំណុំរឿងដែលមិនអាចដោះស្រាយបាននៅថ្នាក់ខេត្តទៅកាន់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ អាជ្ញាធរនេះត្រូវបានផ្តល់សិទ្ធិត្រួតពិនិត្យលើករណីទំនាស់ដីធ្លីនានាដែលផុតពីការកិច្ចរបស់គណៈកម្មការសុរិយោដីខេត្ត។ តួនាទីអាជ្ញាធរនេះមានបញ្ជាក់នៅក្នុងចំណុច ៣.២ខាងលើ។ អាជ្ញាធរនេះទទួលដោះស្រាយសំណុំរឿងទំនាស់លើការកាន់កាប់ និងប្រើប្រាស់លើអចលនទ្រព្យទាំងឡាយណាដែលមានការចុះបញ្ជីត្រឹមត្រូវ។ អាជ្ញាធរនេះនឹងត្រូវការពេលវេលាមួយចំនួនក្នុងការសិក្សា និងត្រួតពិនិត្យឯកសារ និងសំណុំរឿងនេះ ហើយអាចនឹងកោះហៅភាគីពាក់ព័ន្ធទាំងអស់ក្នុងការជជែក និងពិភាក្សាស្វែងរកដំណោះស្រាយទៅលើករណីទំនាស់។ ប្រសិនបើភាគីណាមួយមិនពេញចិត្តចំពោះដំណោះស្រាយនៅក្នុងដំណាក់កាលនេះ ភាគីនោះអាចបន្តនីតិវិធីបណ្តឹងតវ៉ាទៅតាមផ្លូវតុលាការនៅក្នុងតំបន់។

- **ដំណាក់កាលដោះស្រាយតាមប្រព័ន្ធតុលាការ**
  - **ដំណាក់កាលទី៥៖** ភាគីពាក់ព័ន្ធជាពិសេសប្រជាពលរដ្ឋដែលរងគ្រោះអាចដាក់ពាក្យបណ្តឹងអំពីការរំលោភបំពាននានាពីការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុនវិនិយោគឯកជនទៅលើទ្រព្យសម្បត្តិ និងការកាន់កាប់ស្របច្បាប់របស់ខ្លួន។ ជាទូទៅតាមផ្លូវតុលាការ ប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី[62] និង/ឬ បណ្តឹងព្រហ្មទណ្ឌ (ឬបណ្តឹងអាជ្ញា)[63] ដោយអាស្រ័យទៅតាមប្រភេទបទល្មើស

[60] ដូចឯកសារដើមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១២)

[61] ដូចឯកសារដើមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១២)

[62] បណ្តឹងរដ្ឋប្បវេណី ជាបណ្តឹងដែលទាក់ទងនឹងសិទ្ធិឯកជន ឬជាបណ្តឹងដែលទាមទារឱ្យជនប្រព្រឹត្តបទល្មើសជួសជុលសងការខូចខាតផ្នែកសម្ភារៈ ការព្យាបាលរូបរាងកាយ និងការសងជំងឺចិត្តទៅតាមភាពជាក់ស្តែងនៃការរងគ្រោះសមល្មមនឹងកំហូចខាតដែលខ្លួនបានបាត់បង់។ បណ្តឹងរដ្ឋប្បវេណីក៏មានគោលបំណងឱ្យតុលាការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារបុគ្គលឯកជន។ ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទផ្នែករដ្ឋប្បវេណី។ ប្រព័ន្ធតុលាការផ្នែករដ្ឋប្បវេណីមានភាពខុសគ្នាខ្លះពីប្រព័ន្ធតុលាការផ្នែកព្រហ្មទណ្ឌទាំងគោលការណ៍និងទាំងនីតិវិធី។ ចំពោះរបៀបប្តឹងចូលទៅតុលាការ ប្រភេទសេចក្តីសម្រេច និងសិទ្ធិរបស់គូភាគី ក៏មានភាពខុសគ្នាខ្លះដែរ។ ក្នុងរឿងរដ្ឋប្បវេណីចំពោះអ្នកប្តឹងគេហៅថា ដើមបណ្តឹង រីឯអ្នកត្រូវបានគេប្តឹងហៅថា ចុងចម្លើយ។ ក្នុងរឿងរដ្ឋប្បវេណី ភាគីជាអ្នកមានសកម្មភាពច្រើនព្រោះភាគីជាអ្នកស្វែងរកភស្តុតាងដើម្បីដាក់ឱ្យតុលាការជឿដើម្បីការពារផលប្រយោជន៍ និងទាមទារផលប្រយោជន៍ដែល

ដែលកើតមាន។ ប្រសិនបើភាគីណាមួយមិនពេញចិត្តនឹងដំណោះស្រាយមុនៗ ពួកគេអាចនាំយករឿងក្តីនេះទៅកាន់សាលាដំបូងរាជធានី-ខេត្ត។ នេះគឺជាដំណាក់កាលចុងក្រោយសម្រាប់ការវិនិច្ឆ័យលើពាក្យបណ្តឹងតវ៉ា។ តុលាការនឹងធ្វើសេចក្តីសម្រេចស្ថាពរជាលាយលក្ខណ៍អក្សរ (សាលក្រម-សាលដីការ) និងបញ្ជូនច្បាប់ចម្លងទៅកាន់ភាគីពាក់ព័ន្ធលើបណ្តឹងតវ៉ានេះ។ ប្រសិនបើភាគីណាមួយនៅតែមិនពេញចិត្តនឹងសាលក្រមសាលាដំបូងរាជធានី-ខេត្ត ភាគីនោះអាចនាំយកករណីនេះទៅសាលាឧទ្ធរណ៍តំបន់ និងតុលាការកំពូលបន្តទៀតបាន ហើយសាលក្រមបិទបណ្តឹងសារទុក្ខជាសេចក្តីសម្រេចចុងក្រោយដែលត្រូវដោះស្រាយ និងរំលត់បណ្តឹងទាំងអស់។

---

ខ្លួនគិតថាបានខូចខាត។ ព្រះរាជអាជ្ញាមិនមានតួនាទីអ្វីសំខាន់ទេក្នុងរឿងស៊ីវិល។ គាត់មានតួនាទីត្រឹមតែផ្តល់យោបល់តែប៉ុណ្ណោះ។ ពាក្យបណ្តឹងអាចដាក់បាននូវការិយាល័យក្រឡាបញ្ជីនៃតុលាការដែលមានសមត្ថកិច្ច។ ទាំងរឿងស៊ីវិលនិងរឿងព្រហ្មទណ្ឌអាចប្តឹងទៅតុលាការបីថ្នាក់ដូចគ្នា គឺសាលាដំបូងរាជធានីខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូល។

[63] បណ្តឹងអាជ្ញា ជាបណ្តឹងស្របច្បាប់មួយដែលរដ្ឋទទួលបន្ទុកធ្វើបណ្តឹងដោយអយ្យការជាតំណាងដើម្បីធ្វើការចោទប្រកាន់ទៅលើបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសទាក់ទងនឹងរឿងព្រហ្មទណ្ឌ។ បណ្តឹងអាជ្ញាមានគោលបំណង ពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជនល្មើសនោះតាមច្បាប់កំណត់ ហើយអនុវត្តទៅលើបុគ្គលគ្រប់រូបដោយឥតប្រកាន់ពូជសាសន៍ សញ្ជាតិ សាសនា ភេទ ឬឋានៈក្នុងសង្គមឡើយ។ ទាក់ទងនិងរឿងព្រហ្មទណ្ឌ ករណីជាបទល្មើសជាក់ស្តែងមិនថាតែនគរបាល ប៉ូលិសទេសូម្បីតែប្រជា-ជនសាមញ្ញក៏អាចមានសិទ្ធិឃាត់ខ្លួនជនល្មើសបានដែរ។ ពេលឃាត់ខ្លួនរួចហើយត្រូវបញ្ជូនខ្លួនជនល្មើសទៅឱ្យនគរបាលយុត្តិធម៌ដែលនៅជិតបំផុតពីទីកន្លែងកើតហេតុ។ នគរបាលអាចឃាត់ខ្លួនជនល្មើសបានរយៈពេល៤៨ម៉ោង។ បន្ទាប់ពីធ្វើការសើបសួរ និងធ្វើកំណត់ហេតុរួចនគរបាលត្រូវបញ្ជូនជនល្មើសទៅឱ្យព្រះរាជអាជ្ញាដើម្បីធ្វើការពិនិត្យពិរុទ្ធភាពថាមានឬគ្មានពិរុទ្ធ។ បើគ្មានពិរុទ្ធភាពអ្វីទេត្រូវដោះលែងជននោះឱ្យមានសេរីភាពវិញ ក៏ប៉ុន្តែប្រសិនបើរកឃើញថាមានពិរុទ្ធភាព នោះព្រះរាជអាជ្ញានឹងធ្វើការចោទប្រកាន់ហើយបញ្ជូនជនល្មើសឱ្យទៅចៅក្រមស៊ើបអង្កេតដើម្បីធ្វើការស៊ើបសួរ។ ពេលនោះចៅក្រមស៊ើបអង្កេតអាចសម្រេចឃុំខ្លួន ឬមិនឃុំខ្លួនជននោះបាន។ បន្ទាប់ពីការស៊ើបអង្កេតចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបអង្កេតនឹងបញ្ជូនជនជាប់ចោទទៅចៅក្រមជំនុំជម្រះដើម្បីជំនុំជម្រះរឿងក្តីរកយុត្តិធម៌ជូនជនរងគ្រោះ។ ក្នុងរឿងព្រហ្មទណ្ឌជនរងគ្រោះគឺជាដើមបណ្តឹងរដ្ឋប្បវេណី ឯព្រះរាជអាជ្ញាជាម្ចាស់បណ្តឹងអាជ្ញា។ ជនរងគ្រោះត្រូវស្នើសុំទៅតុលាការដើម្បីឱ្យជនល្មើសសងជំងឺចិត្ត ឬជួសជុលព្យសនកម្មដល់ខ្លួនមុនពេលចៅក្រមសម្រេចក្តី។ យើងត្រូវយល់ផងដែរក្នុងរឿងព្រហ្មទណ្ឌមានទណ្ឌកម្មពីរ គឺទណ្ឌកម្មព្រហ្មទណ្ឌ (ដាក់ពន្ធនាគារនិងទោសពិន័យជាប្រាក់) និងសំណងរដ្ឋប្បវេណី។

ដ្យាក្រាមទី១១៖ នីតិវិធីសង្ខេបក្នុងការដោះស្រាយបណ្តឹងតវ៉ា




## ៣.១១ បញ្ហាមួយចំនួនសម្រាប់ការដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់

ការងារដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តជាការងារដែលមានលក្ខណៈស្មុគស្មាញ និងទាមទារឱ្យមានការចូលរួមដឹងលឺច្រើននៅក្នុងដំណើរការរៀបចំការងារដោះស្រាយចាប់ពីដំណាក់កាលដំបូងរហូតដល់ដំណាក់កាលបញ្ចប់។ បញ្ហាប្រឈមជាច្រើនតែងតែកើតមានក្នុងអំឡុងពេលនៃកិច្ចដំណើរការដោះស្រាយ ដែលភាគីពាក់ព័ន្ធទាំងអស់ចាំបាច់ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ និងត្រូវដោះស្រាយឱ្យមានប្រសិទ្ធភាពដើម្បីឱ្យដំណើរការដោះស្រាយសម្រេចបានជោគជ័យដូចការរំពឹងទុក។ ភាគីពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តទុកដាក់លើបញ្ហាដូចមានលើកឡើងខាងក្រោមនេះ៖

- ❶ ការជូនដំណឹងភ្លាមៗ និងពុំមានប្រសិទ្ធភាព៖ បើទោះបីជាបទបញ្ញត្តិ និងគោលការណ៍សុវត្ថិភាពតម្រូវឱ្យព័ត៌មានត្រូវធ្វើការចែកចាយគ្រប់គ្រាន់ និងទាន់ពេល ការអនុវត្តជាក់ស្តែងនៅតែមិនទាន់បានធ្វើឱ្យគ្រប់គ្រាន់នៅឡើយ។ គ្រួសាររងគ្រោះ ជាពិសេសអ្នកដែលរស់នៅតំបន់ដាច់ស្រយាលតែងតែទទួលបាននូវការជូនដំណឹងភ្លាមៗ និងពុំមានប្រសិទ្ធភាព។ នៅខណៈពេលដែលអ្នកអនុវត្តគម្រោងប្រញាប់ប្រញាល់ពន្លឿនដំណើរការដើម្បីបំពេញទៅតាមកាលបរិច្ឆេទ បញ្ហាប្រឈមសំខាន់គឺការខ្វះខាតនូវទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធ ការបាត់បង់នូវការចែករំលែកព័ត៌មានឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ។

- ❷ សំណងមិនគ្រប់គ្រាន់៖ ការអនុវត្តដែលពុំមានប្រសិទ្ធភាពដូចដែលជាទូទៅគឺមានសំណងមិនពេញ

លេញ។ មានន័យថាគ្រួសាររងគ្រោះ គឺពុំបានទទួលប្រាក់សំណងគ្រប់គ្រាន់នោះទេសម្រាប់ការខូចខាតជាក់ស្តែងហើយតម្លៃគឺពុំបានផ្អែកទៅលើតម្លៃទីផ្សារនោះឡើយ។

- ③ ការចូលរួមពេញលេញ ឬពិតប្រាកដពីសំណាក់អ្នកពាក់ព័ន្ធ៖ ដោយផ្អែកលើវត្តមានក្នុងកិច្ចប្រជុំ បទពិសោធន៍បានបង្ហាញច្បាស់ណាស់ថាការចូលរួមជាសាធារណៈពេញលេញដែលមានប្រសិទ្ធភាព គឺនៅតែមានចំណុចខ្វះខាតចំពោះគម្រោងអភិវឌ្ឍន៍ភាគច្រើន។ គ្រួសារដែលរងគ្រោះគឺពុំទទួលសេចក្តីជូនដំណឹង និងព័ត៌មានគ្រប់គ្រាន់មុនពេលការប្រឹក្សាយោបល់នោះឡើយ។

- ④ គណនេយ្យភាព និងតម្លាភាព (សំណងពុំយុត្តិធម៌)៖ ជាធម្មតាករណីនេះកើតឡើងនៅពេលដែលតម្លៃលើការខាតបង់ និងខូចខាតទាំងស្រុងពុំត្រូវបានទូទាត់។ មានករណីជាច្រើនដែលបង្ហាញថាបរិមាណ និងតម្លៃលើការខូចខាតត្រូវបានកាត់បន្ថយពីបញ្ជីសារពើភ័ណ្ឌដើមសម្រាប់ការខូចខាតនៅពេលទូទាត់សងគ្រួសារដែលរងគ្រោះ។ តម្លៃដែលសងគឺស្ថិតនៅក្រោមតម្លៃទីផ្សារជាក់ស្តែងផងដែរ។

- ⑤ ជម្រើសក្នុងការតាំងទីលំនៅឡើងវិញ (សេវាកម្ម ឬធនធានមិនសមស្របនិងមានកំណត់នៅនឹងកន្លែង)៖ ការអនុវត្តតាំងទីលំនៅពីមុនៗបានបង្ហាញថាគ្រួសាររងគ្រោះកាន់តែមានជីវភាពមិនសូវល្អបន្ទាប់ពីបានផ្លាស់ប្តូរទីលំនៅទៅកាន់កន្លែងថ្មី។ ជាទូទៅតំបន់តាំងទីលំនៅថ្មីគឺឆ្ងាយពីតំបន់ទីប្រជុំជន ឬទីក្រុង ដែលជាកន្លែងគេត្រូវធ្វើដំណើរទៅបំពេញការងារ ឬធ្វើជំនួញផ្សេងៗ។ ហេដ្ឋារចនាសម្ព័ន្ធទៀតសោតដូចជាសាលារៀន មណ្ឌលសុខភាពដើម ក៏មិនមានគ្រប់គ្រាន់ស្រាប់សម្រាប់ការប្រើប្រាស់។

- ⑥ ផលប៉ះពាល់នៃជីវភាពទៅលើប្រជាពលរដ្ឋ (តម្លៃឱកាសសម្រាប់អ្នកទៅ និងអ្នកនៅ)៖ ជាទូទៅគេអង្កេតឃើញថាអ្នកទៅ (ឧទាហរណ៍. អ្នកដែលតាំងទីលំនៅដ្ឋានថ្មី) បានបាត់បង់តម្លៃឱកាសសម្រាប់ជម្រើសនៃជីវភាពនៅក្នុងកន្លែងចាស់។ តាមរយៈការលក់ដូរទំនិញ និងការផ្តល់សេវាកម្ម ពួកគេធ្លាប់ប្រកបរបរចិញ្ចឹមជីវិតជាមួយអ្នកជិតខាងហើយពួកគេបានបាត់បង់ឱកាសនេះ នៅពេលដែលប្តូរទៅកាន់ទីតាំងថ្មី។ នៅខណៈពេលដែលអ្នកជិតខាងរបស់ពួកគាត់ (អ្នកដែលមិនផ្លាស់ប្តូរទីលំនៅ និងរស់នៅក្នុងសហគមន៍ក្បែរនោះ) ពុំអាចរកប្រាក់ចំណេញពីអ្នកជទៃទៀត និងអ្នកដែលផ្លាស់ទីលំនៅ។ មិនយូរមិនឆាប់ អ្នកទាំងអស់នោះនឹងចាប់ផ្តើមយុទ្ធសាស្ត្រចិញ្ចឹមជីវិតសារជាថ្មី ដែលជាបញ្ហាប្រឈមសម្រាប់ប្រជាជនក្រីក្រ។

- ⑦ ការខ្វះខាតការតាមដានទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបន្ទាប់ពីការតាំងទីលំនៅឡើងវិញ ឬបន្ទាប់ពីការទទួលយកដំណោះស្រាយរួចរាល់ហើយ៖ ម្ចាស់គម្រោងវិនិយោគឯកជនភាគច្រើនតែងគិតថាកិច្ចការងារដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត ត្រូវបានបញ្ចប់រួចរាល់នៅពេលដែលប្រជាពលរដ្ឋទទួលយកដំណោះស្រាយ។ កិច្ចការបន្ទាប់គឺត្រូវធ្វើការតាមដានទៅលើការតាំងទីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ដើម្បីធានាថាស្ថានភាពរស់នៅរបស់ពួកគេមានលក្ខណៈល្អប្រសើរហើយឬនៅ ឬម្ចាស់គម្រោងវិនិយោគត្រូវធ្វើអ្វីបន្ថែមទៀតក្នុងរយៈពេលកំណត់ណាមួយក្នុងការជួយជ្រោមជ្រែងការរស់នៅរបស់ប្រជាពលរដ្ឋដែលទទួលយកដំណោះស្រាយរួច។

រូបភាពទី៥៖ សកម្មភាពជួបពិភាក្សាជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់អំពីសំណង និងផែនការរុះរើលំនៅដ្ឋាន



# ជំពូកទី៤



## អនុសាសន៍សម្រាប់បញ្ចូលព័ត៌មានសំខាន់ៗអំពីយន្តការដោះស្រាយលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម

## ផ្នែកទី៤៖ អនុសាសន៍សម្រាប់បញ្ចូលព័ត៌មានបន្ថែមអំពីយន្តការដោះស្រាយ ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត

នៅក្នុងបរិបទនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមក្នុងប្រទេសកម្ពុជា ដំណើរការវាយតម្លៃ និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាយន្តការ និងជាឧបករណ៍សំខាន់ណាស់ក្នុងការគ្រប់គ្រងហេតុប៉ះពាល់ និងហានិភ័យទាំងឡាយពីគម្រោងអភិវឌ្ឍន៍ ឬគម្រោងវិនិយោគឯកជនណាមួយ និងជាព័ត៌មានសំខាន់សម្រាប់ការសេចក្ដីសម្រេចចិត្តនៅលើការឯកភាពទៅលើរបាយការណ៍ និងផែនការគ្រប់គ្រងបរិស្ថានផ្សេងៗទៀត។ ជាចាំបាច់ដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវមានព័ត៌មាន ឬទិន្នន័យគ្រប់គ្រាន់ និងត្រឹមត្រូវអំពីស្ថានភាពនៃហេតុប៉ះពាល់ពីគម្រោងដែលអាចបង្កឱ្យមានការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងផលប៉ះពាល់ទៅលើជីវភាពរស់ប្រជាពលរដ្ឋនៅតាមតំបន់មូលដ្ឋាន។ ព្រមជាមួយគ្នានេះដែរ យន្តការដោះស្រាយ និងផែនការសកម្មភាពសម្រាប់ការចូលរួមពីសាធារណជននៅក្នុងកិច្ចដំណើរការចរចា និងសម្របសម្រួលលើបញ្ហានៃការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តត្រូវតែរៀបចំចេញឱ្យបានច្បាស់ និងអាចអនុវត្តបានដែលស្របទៅតាមបទដ្ឋានគតិយុត្ត និងយន្តការរដ្ឋបាលដែលមានស្រាប់នៅតាមតំបន់មូលដ្ឋានក្នុងប្រទេសកម្ពុជា។

អនុសាសន៍ខាងក្រោមនេះកំណត់នូវលក្ខខណ្ឌព័ត៌មានចាំបាច់មួយចំនួនអំពីហេតុ និងផលប៉ះពាល់ និងការងារដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋដែលបណ្ដាលមកពីគម្រោងវិនិយោគឯកជនតែប៉ុណ្ណោះ ហើយសម្រាប់តែក្របខ័ណ្ឌការងារនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់ក្រសួងបរិស្ថាន។

ម្ចាស់គម្រោងវិនិយោគឯកជន និងក្រុមហ៊ុនទីប្រឹក្សាត្រូវរៀបចំនូវផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តនិងជីវភាពរបស់ប្រជាពលរដ្ឋ (Resettlement Action Plan) ដែលត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម (ដំបូងឬពេញលេញ) សម្រាប់ការត្រួតពិនិត្យនិងជាឯកសារយោងបន្ថែម។ ដើម្បីឱ្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមមានព័ត៌មានគ្រប់គ្រាន់ និងត្រឹមត្រូវស្ដីអំពីផលប៉ះពាល់ និងការងារដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋ ជំពូកសំខាន់ៗនៃរបាយការណ៍ត្រូវផ្អែកទៅលើអនុសាសន៍ចាំបាច់ដូចខាងក្រោម៖

- **សេចក្ដីសង្ខេប**
- **ជំពូកទី១ សេចក្ដីផ្ដើម៖** ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវរៀបរាប់យ៉ាងខ្លីអំពីសក្ដានុពលដែលគម្រោងអាចបង្កជាហានិភ័យទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋ។

- **ជំពូកទី២ វិធីសាស្ត្រសិក្សាវាយតម្លៃ៖** ម្ចាស់គម្រោងត្រូវបញ្ចូលបន្ថែមនូវវិធីសាស្ត្រ ឬនីតិវិធីក្នុងការសិក្សាចងក្រងនូវព័ត៌មាន និងការវិភាគទាំងឡាយដែលពាក់ព័ន្ធទៅលើផលប៉ះពាល់លើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់គម្រោង។ ម្ចាស់គម្រោងត្រូវបង្ហាញនូវផែនទីអំពីទីតាំងជាក់លាក់ដែលត្រូវធ្វើការសិក្សាជាមួយប្រជាពលរដ្ឋដែលរងគ្រោះ។ នីតិវិធីមួយចំនួនដូចជា៖
  - *ការផ្សព្វផ្សាយជូនដំណឹងអំពីគម្រោងវិនិយោគឯកជន និងការងារសិក្សាវាយតម្លៃផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋ និងការកំណត់នូវកាល*

*បរិច្ឆេទចុងក្រោយ (Cut-of-Date) សម្រាប់ការចុះអង្កេតវាស់វែងលម្អិត (DMS) និងការធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិដែលប៉ះពាល់ (IOL) ជាក់ស្តែង។*

- *វិធីសាស្ត្រក្នុងការអនុវត្តនូវការងារអង្កេតវាស់វែងលម្អិត និងការធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិដែលប៉ះពាល់ (រួមបញ្ចូលទាំងសមាសភាពក្រុមការងារ កម្មវិធីការងារ បច្ចេកទេសនិងឧបករណ៍វាស់វែង ឧ.បញ្ជីសំណួរជាដើម)។*
- *វិធីសាស្ត្រក្នុងការសិក្សាតម្លៃជំនួស (RCS) ដោយបញ្ចូលវិធីសាស្ត្រគណនាតម្លៃជំនួសនានា។*
- *វិធីសាស្ត្រក្នុងការគណនាប្រាក់សំណង។*
- *នីតិវិធីក្នុងការពិគ្រោះយោបល់ និងពិភាក្សាជាចំដោយឡែកជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់។*

- **ជំពូកទី៣ ក្របខ័ណ្ឌច្បាប់៖** ម្ចាស់គម្រោងត្រូវបញ្ចូលនូវច្បាប់ និងបទបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងការងារដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ក្របខ័ណ្ឌគតិយុត្តមួយចំនួនដូចជា៖
  - *រដ្ឋធម្មនុញ្ញ (ឆ្នាំ១៩៩៣)*
  - *ច្បាប់ភូមិបាល (ឆ្នាំ២០០១)*
  - *អនុក្រឹត្យលេខ១៩ អនក្រ.បក ស្តីពីសម្បទានដីសង្គមកិច្ច (ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣) បានលើកឡើងអំពីការរៀបចំទីតាំងសម្រាប់ការតាំងទីលំនៅថ្មីឡើងវិញរបស់ប្រជាពលរដ្ឋ។*
  - *អនុក្រឹត្យលេខ១៩៧ អនក្រ.បក ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិ និងផ្លូវដែកនៃព្រះរាជាណាចក្រកម្ពុជា (ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩) បានលើកឡើងនូវតារាងកំណត់លក្ខណៈសម្បត្តិទទួលបានសំណង ឬប្រាក់ឧបត្ថម្ភគោលនយោបាយ។*
  - *សេចក្តីប្រកាសលេខ០៦ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី (ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩) បានលើកឡើងនូវតារាងកំណត់លក្ខណៈសម្បត្តិទទួលបានសំណង ឬប្រាក់ឧបត្ថម្ភគោលនយោបាយ។*
  - *សារាចរលេខ០៣ ស្តីពីការដោះស្រាយសំណង់មិនស្របច្បាប់លើដីរដ្ឋក្នុងទីក្រុង និងតំបន់ជាយក្រុង (ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០) បានលើកឡើងនូវតារាងកំណត់លក្ខណៈសម្បត្តិទទួលបានសំណង ឬប្រាក់ឧបត្ថម្ភគោលនយោបាយ។*
  - *សារាចរលេខ០២ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ (ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧) បានលើកឡើងនូវតារាងកំណត់លក្ខណៈសម្បត្តិទទួលបានសំណង ឬប្រាក់ឧបត្ថម្ភគោលនយោបាយ*
  - *លិខិតលេខ៩៦១ សហវ ស្តីពីការអនុវត្តគោលនយោបាយដីចំណីផ្លូវ ចំពោះផ្លូវជាតិ ផ្លូវខេត្ត ផ្លូវឃុំ និងផ្លូវដែក (ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០០) បានលើកឡើងនូវតារាងកំណត់លក្ខណៈសម្បត្តិទទួលបានសំណង ឬប្រាក់ឧបត្ថម្ភគោលនយោបាយ។*
  - *សេចក្តីណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ០០៤ ស្តីពីតួនាទី និងភារកិច្ចរបស់គណៈកម្មការដោះស្រាយបណ្តឹងតវ៉ាក្រោមគម្រោងអភិវឌ្ឍន៍ (ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៦) បានលើកឡើងនូវយន្តការដោះស្រាយបណ្តឹងតវ៉ា។*

- **ជំពូកទី៤ ការពិពណ៌នាអំពីគម្រោង៖** ម្ចាស់គម្រោងត្រូវរៀបរាប់លំអិតនូវគោលការណ៍ និងគោលជំហររបស់ខ្លួនក្នុងការចូលរួមដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និង

ជីវភាពរបស់ប្រជាពលរដ្ឋ។ ម្ចាស់គម្រោងអាចលើកឡើងនូវរចនាសម្ព័ន្ធផ្ទៃក្នុងរបស់ខ្លួន (ដោយមានផ្នែក និងបុគ្គលិកទទួលខុសត្រូវច្បាស់លាស់ក្នុងការជួយដោះស្រាយនូវផលប៉ះពាល់)។

- **ជំពូកទី៥ ការពិពណ៌នាអំពីបរិស្ថានដែលមានស្រាប់៖** ម្ចាស់គម្រោងត្រូវបន្ថែមនូវផ្នែកដាច់ដោយឡែកស្តីអំពី *"ផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋ"* នៅក្នុងជំពូកនេះ។ នៅក្នុងផ្នែកដាច់ដោយឡែកនេះ ម្ចាស់គម្រោងត្រូវលើកឡើងដោយសង្ខេបខ្លី និងមានខ្លឹមសារល្អនូវចំណុចដូចខាងក្រោម៖
  - *ប្រវត្តិនៃការតាំងទីលំនៅដ្ឋាន៖ ម្ចាស់គម្រោងត្រូវរៀបរាប់នូវប្រវត្តិនៃការចូលមករស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋានដោយលើកឡើងនូវឆ្នាំ ឬពេលវេលាដែលមានការកកើតភូមិ ឬទីតាំងរស់នៅ ឈ្មោះភូមិ និងរឿងរ៉ាវនានាដែលពាក់ព័ន្ធ។*
  - *បច្ចុប្បន្នភាពនៃប្រជាសាស្ត្រ៖ ម្ចាស់គម្រោងត្រូវលើកឡើងនូវចំនួនគ្រួសារសរុប ចំនួនមនុស្សសរុប (បុរសនិងស្ត្រី) និងប្រជាពលរដ្ឋដែលងាយរងគ្រោះដូចជា ចំនួនឬភាគរយនៃក្មេង មនុស្សចាស់ ស្ត្រីមេម៉ាយ និងជនពិការដែលមាននៅក្នុងតំបន់។*
  - *បញ្ជីទ្រព្យសម្បត្តិ (ឧ. ដីលំនៅដ្ឋាន ដីកសិកម្ម សំណង់ផ្ទះ រោងចិញ្ចឹមសត្វ ជង្រុកស្រូវ ដំណាំ ដើមឈើ ទីសក្ការៈ ព្រះភូមិ អណ្តូង បង្គន់ ឬផ្នូរដោរដើម) ដែលជារបស់កម្មសិទ្ធិនៃគ្រួសារនីមួយៗដែលត្រូវរងផលប៉ះពាល់។*
  - *សង្ខេបនូវស្ថានភាពជីវភាព ឬសេដ្ឋកិច្ច-សង្គមសម្រាប់តែប្រជាពលរដ្ឋដែលរងផលប៉ះពាល់ (ឧ. មុខរបរសំខាន់ៗ ប្រាក់ចំណូល ការប្រើប្រាស់ទឹកនិងថាមពល ស្ថានភាពសុខភាពនិងមណ្ឌលសុខភាព កម្រិតអប់រំនិងសាលារៀន ការប្រើប្រាស់ធនធានធម្មជាតិ ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងតំបន់រងផលប៉ះពាល់ ។ល។)។*
  - *លើកឡើងនូវជម្រើសសំណងនានា (ឧ. សំណងជាថវិកាសុទ្ធ ឬការផ្លាស់ទីទៅតាំងទីលំនៅដ្ឋានថ្មី) ដែលបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ឬលើកឡើងនូវការមិនទាន់សម្រេចចិត្តណាមួយរបស់ប្រជាពលរដ្ឋ ព្រមទាំងបញ្ជាក់នូវនីតិវិធីពិគ្រោះយោបល់បន្តទៀត។*
  - *លើកឡើងនូវផែនការស្តារជីវភាពរបស់ប្រជាពលរដ្ឋដោយបញ្ជាក់នូវផែនការសកម្មភាព និងពេលវេលាអនុវត្តន៍ជាក់លាក់ក្រោយពីការផ្លាស់ទីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់។*
  - *លើកឡើងនូវផែនការត្រួតពិនិត្យ និងតាមដានការងារដោះស្រាយផលប៉ះពាល់ និងស្តារជីវភាពឡើងវិញរបស់ប្រជាពលរដ្ឋដោយបញ្ជាក់នូវភ្នាក់ងារត្រួតពិនិត្យ កម្មវិធីនិងវិធីសាស្ត្រត្រួតពិនិត្យជាដើម។*

- **ជំពូកទី៦ ការចូលរួមពីសាធារណជន៖** ម្ចាស់គម្រោងត្រូវពិពណ៌នាបន្ថែមអំពីសកម្មភាពទាំងឡាយ ក៏ដូចជាទិដ្ឋភាពរួមក្នុងការផ្សព្វផ្សាយ ពិគ្រោះយោបល់ និងលទ្ធផល ឬសេចក្តីសម្រេចនានាដែលមានការឯកភាពគ្នា ឬមិនមានការឯកភាពគ្នាក្នុងការងារចងក្រងទិន្នន័យ និងដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋ។ កំណត់ហេតុនៃកិច្ចជំនួបនានា និងបញ្ជីវត្តមានរបស់ប្រជាពលរដ្ឋដែលបានចូលរួមត្រូវភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធរបស់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលកំពុងត្រួតពិនិត្យ។

- **ជំពូកទី៧ ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ៖** ម្ចាស់គម្រោងត្រូវបន្ថែមការវិភាគហេតុប៉ះពាល់ដោយបញ្ចូលហេតុប៉ះពាល់ *"ការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត និងជីវភាព*

*របស់ប្រជាពលរដ្ឋ"* ទៅក្នុងបញ្ជី ឬតារាងម៉ាទ្រីសនៃហេតុប៉ះពាល់ដែលបានវិភាគ ហើយកំណត់កម្រិតប៉ះពាល់ទៅតាមស្ថានភាពជាក់ស្តែង ព្រមទាំងលើកឡើងនូវវិធានសមស្របទៅតាមការពិគ្រោះយោបល់ និងឯកភាពគ្នាជាមួយភាគីពាក់ព័ន្ធ។

- **ជំពូកទី៨ ផែនការគ្រប់គ្រងបរិស្ថាន៖** ម្ចាស់គម្រោងត្រូវលើកឡើងនូវផែនការគ្រប់គ្រង និងតាមដានលើការងារដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋរហូតទាល់តែបញ្ចប់បានជោគជ័យ។ ម្ចាស់គម្រោងត្រូវបញ្ជាក់នូវវិធីសាស្ត្រតាមដាន សូចនាករណ៍តាមដាន និងកម្រិតនៃការតាមដាន (ភាពញឹកញាប់) ស្ថាប័នអនុវត្តន៍ និងតាមដាន ព្រមទាំងវិលេចនូវបរិមាណថវិកាដែលត្រូវការចាំបាច់ក្នុងការតាមដានត្រួតពិនិត្យការអនុវត្តការងារដោះស្រាយផលប៉ះពាល់ផងដែរ។

- **ជំពូកទី៩ ការវិភាគសេដ្ឋកិច្ចនិងតម្លៃបរិស្ថាន៖** ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវបញ្ចូលនូវតម្លៃជាថវិកានៃការងារដោះស្រាយផលប៉ះពាល់ទៅក្នុងការវិភាគតម្លៃខូចខាតបរិស្ថាន (សម្រាប់ធនធានសេដ្ឋកិច្ច-សង្គម)។

- **ជំពូកទី១០ សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវបន្ថែមនូវសេចក្តីសន្និដ្ឋាន និងអនុសាសន៍ដោយខ្លីអំពីផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋ។

- **ឧបសម្ព័ន្ធ៖** ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវភ្ជាប់មកជាមួយនូវ ១). របាយការណ៍សិក្សាផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តនិងជីវភាពរបស់ប្រជាពលរដ្ឋ ២). ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ទៅលើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋ ៣). របាយការណ៍សិក្សាតម្លៃជំនួស ៤). បញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ ៥). កំណត់ហេតុប្រជុំពិគ្រោះយោបល់នានាដែលបានរៀបចំឡើង និង ៦). ឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងជីវភាពរបស់ប្រជាពលរដ្ឋ។

# សន្ទានុក្រមពាក្យគន្លឹះ

- *ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមៈ* គឺជាការសិក្សាព្យាករនូវហេតុប៉ះពាល់នានាពីគម្រោងវិនិយោគ ឬគម្រោងអភិវឌ្ឍន៍ទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គមនៅក្នុង និងជុំវិញតំបន់គម្រោង ព្រមទាំងលើកឡើងនូវវិធានការទប់ស្កាត់ និងកាត់បន្ថយសំដៅជានាឱ្យមាននូវហេតុប៉ះពាល់អវិជ្ជមានតិចតួច លើកកម្ពស់កិច្ចការពារបរិស្ថាន និងបង្កើនអត្ថប្រយោជន៍សម្រាប់សហគមន៍ និងប្រទេសទាំងមូល។

- *ការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានៈ* ការចូលរួមពីសាធារណជនក្នុងការចូលរួមពិគ្រោះយោបល់របស់អ្នកពាក់ព័ន្ធទៅនឹងគម្រោងអភិវឌ្ឍន៍ និងការព្រួយបារម្ភនានាទៅលើធនធានបរិស្ថានធម្មជាតិ ជីវសាស្ត្រ និងសេដ្ឋកិច្ចសង្គម។

- *តំបន់ងាយរងគ្រោះៈ* នៅក្នុងបរិបទនៃផលប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តនេះ តំបន់ដែលងាយរងគ្រោះគឺជាតំបន់ ឬទីតាំងដែល (១). មានដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់ (២). តំបន់ដែលសម្បូរណ៍ធនធានព្រៃឈើ និង (៣). ជាតំបន់ទាំងឡាយណា ដែលត្រូវបានចាត់ទុកថាជាតំបន់ដែលងាយប្រឈមទៅនឹងហានិភ័យនៃគ្រោះមហន្តរាយធម្មជាតិ។

- *ក្រុមប្រជាពលរដ្ឋងាយរងគ្រោះៈ* ប្រជាពលរដ្ឋដែលងាយរងគ្រោះ គឺសំដៅទៅលើក្រុមប្រជាពលរដ្ឋដែលមិនមានសមត្ថភាព ឬលទ្ធភាពក្នុងការទ្រទ្រង់ជីវភាពដោយខ្លួនឯងមិនមានឱកាសក្នុងចូលរួមជីវភាពសង្គម និងមិនមានធនធានក្នុងការទប់ទល់ ឬស្តារឡើងវិញជាមួយហេតុការណ៍អាក្រក់ៗដែលអាចនឹងកើតមានឡើង

- *ផលប៉ះពាល់ទៅលើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តៈ* ផលប៉ះពាល់នេះសំដៅទៅលើឥទ្ធិពលអាក្រក់ ឬផលប៉ះពាល់អវិជ្ជមានពីគម្រោងអភិវឌ្ឍន៍ ឬគម្រោងវិនិយោគនានាទៅលើការតាំងទីលំនៅដោយតម្រូវឱ្យមានការផ្លាស់ប្តូរទីលំនៅដ្ឋានជារូបវន្តរបស់ប្រជាជនដោយមិនស្ម័គ្រចិត្ត ដែលត្រូវចាកចេញពីផ្ទះសម្បែង អាជីវកម្មរបស់ខ្លួន និងឬការកាន់កាប់ទ្រព្យសម្បត្តិទាំងឡាយ មុនពេលគម្រោងត្រូវបានអនុវត្តន៍។ ផលប៉ះពាល់នេះផ្តោតទៅលើការខាតបង់ដោយផ្ទាល់ និងប្រយោលផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលប្រជាជនធ្លាប់ទទួលផល និងប្រតិបត្តិដោយស្របច្បាប់។

- *ផែនការដោះស្រាយផលប៉ះពាល់ៈ* ផែនការនេះជារបាយការណ៍ដែលមានផែនការសកម្មភាពតាមពេលវេលាជាក់លាក់មួយ ជាមួយនឹងការរៀបចំថវិកា ការកំណត់នូវគោលបំណង និងយុទ្ធសាស្ត្រនៃការរុះរើលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត ការកំណត់សិទ្ធិទទួលបានសំណង សកម្មភាពនិងការទទួលខុសត្រូវ ការត្រួតពិនិត្យការតាំងទីលំនៅឡើងវិញ និងការវាយតម្លៃនៃការតាំងទីលំនៅឡើងវិញជាដើម។

- *សំណងៈ* សំណងជាការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុសម្រាប់ទ្រព្យសម្បត្តិ ឬធនធានដែលត្រូវបានផ្តល់ឱ្យ ឬត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោងមួយ នៅស្របពេលដែលទ្រព្យសម្បត្តិនោះត្រូវធ្វើការផ្លាស់ទី។

- *កាលបរិច្ឆេទចុងក្រោយៈ* ជាពេលវេលាកំណត់ចុងក្រោយក្នុងការបញ្ចប់ការងារជំរឿនទៅលើជនទាំងឡាយដែលត្រូវធ្វើការផ្លាស់ទីលំនៅដោយសារគម្រោង។

- *ការស្តារប្រាក់ចំណូលឡើងវិញ៖* ជាការស្តារឡើងវិញនូវផលិតភាពនៃជីវភាពរបស់ជនទាំងឡាយដែលត្រូវផ្លាស់ទីក្នុងការបង្កើតឱ្យមាននូវការបង្កើតប្រាក់ចំណូលឱ្យដូច ឬប្រសើរជាង (ប្រសិនបើអាចធ្វើបាន) ស្ថានភាពប្រាក់ចំណូលដែលមានមុនពេលធ្វើការផ្លាស់ទីលំនៅ។

- *ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ៖* ជាដំណើរការដែល (១). រៀបចំឡើងតាំងពីដំណាក់កាលដំបូងនៃការរៀបចំគម្រោង និងត្រូវបានបន្តអនុវត្តន៍ជាប់ជាប្រចាំនៅក្នុងវដ្តនៃគម្រោង (២). ផ្តល់នូវព័ត៌មានគ្រប់គ្រាន់ ពាក់ព័ន្ធនិងទាន់ពេលដែលអាចងាយយល់ និងអាចស្វែងរកបានពីសំណាក់ប្រជាពលរដ្ឋរងផលប៉ះពាល់ (៣) រៀបចំឡើងនៅក្នុងបរិយាកាសដែលមិនមានការបំភិតបំភ័យ ឬការបង្ខិតបង្ខំ (៤). ឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ និងតម្រូវការរបស់ក្រុមងាយរងគ្រោះ ឬក្រុមដែលជួបការលំបាក និង (៥). អាចដាក់បញ្ចូលនូវគ្រប់ទិដ្ឋភាពនៃគ្រប់ទស្សនៈទាំងអស់របស់ប្រជាពលរដ្ឋរងផលប៉ះពាល់ និងភាគីពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដូចជានៅក្នុងការរៀបចំរចនាគម្រោង ការលើកឡើងនូវវិធានការកាត់បន្ថយ ការចែករំលែកនូវអត្ថប្រយោជន៍ និងឱកាសពីការអភិវឌ្ឍ និងបញ្ហានានានៃការអនុវត្តគម្រោង។

- *តម្លៃជំនួស៖* តម្លៃជំនួសរួមមានតម្លៃជំនួសទៅលើទ្រព្យសម្បត្តិនៅក្នុងតម្លៃមួយទូទៅនៅក្នុងពេលដែលមានការទិញដូរកើតឡើង។ តម្លៃនេះរួមមាននូវតម្លៃសមស្របតាមទីផ្សារ តម្លៃប្រតិបត្តិការ ការប្រាក់ដែលអាចមានតម្លៃអន្តរកាលឬតម្លៃស្តារឡើងវិញ និងការទូទាត់ផ្សេងៗទៀតដែលចាំបាច់។ ការរំលោះទ្រព្យសម្បត្តិ និងសំណង់នានា មិនត្រូវរាប់បញ្ចូលនៅក្នុងការសិក្សាតម្លៃជំនួសទេ។ នៅពេលណាដែលគ្មានតម្លៃទីផ្សារ តម្លៃជំនួសត្រូវមានតម្លៃស្មើនឹងតម្លៃចំណាយទាំងអស់នៃសម្ភារសំណង់ តម្លៃពលកម្មសម្រាប់ការសាងសង់ ឬតម្លៃប្រតិបត្តិការផ្សេងៗទៀត ឬស្មើនឹងតម្លៃនៃការចំណាយសម្រាប់ការផ្លាស់ទីលំនៅ។

- *ជំនួយសម្រាប់ការផ្លាស់ទីលំនៅ៖* ជាជំនួយដែលត្រូវផ្តល់ឱ្យជនទាំងឡាយណាដែលត្រូវធ្វើការផ្លាស់ទីជារូបវន្តដោយសារគម្រោងមួយ។ ជំនួយនេះរួមមានការជួយឧបត្ថម្ភការធ្វើដំណើរ អាហារ ទីជម្រក និងសេវាសង្គមផ្សេងៗដែលត្រូវផ្តល់ជូនជនដែលត្រូវផ្លាស់ទី នៅក្នុងកំឡុងពេលនៃការផ្លាស់ទីលំនៅរបស់ពួកគេ។ ជំនួយនេះក៏រួមបញ្ចូលផងដែរនូវប្រាក់ឧបត្ថម្ភ ដែលជាសំណងដល់ជនផ្លាស់ទីសម្រាប់ការខកខាននានាដោយសារការផ្លាស់ទីលំនៅ និងជាជំនួយក្នុងការរៀបចំទីតាំងថ្មីដូចជាចំណាយលើការដឹកជញ្ជូន និងការបាត់បង់ថ្ងៃធ្វើការជាដើម។

- *គោលការណ៍ស្បែកខ្លា៖* គោលការណ៍នេះសង្កត់ធ្ងន់ថាពល់គម្រោងអភិវឌ្ឍន៍សាធារណៈ ឬវិនិយោគឯកជនក្តីត្រូវតែកាត់ ឬចៀសចេញនូវដី ទីតាំង ឬទ្រព្យសម្បត្តិដែលអាចប៉ះពាល់ដល់ការកាន់កាប់ស្របច្បាប់របស់ប្រជាពលរដ្ឋនៅតាមតំបន់មូលដ្ឋាន។